ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# យុទ្ធសាស្ត្រ

# អនុវិស័យ

# ការអប់រំមធ្យមសិក្សា

# ២០២១-២០៣០

ខែឧសភា ឆ្នាំ ២០២១

# អារម្ភកថា

យុទ្ធសាស្ត្រអនុវិស័យការអប់រំមធ្យមសិក្សា ក្នុងបរិបទ១០ឆ្នាំ ២០២១-២០៣០ កើតចេញពីឧត្តមានុវត្តន៍នៃការអនុវត្តវិមជ្ឈការអប់រំរយៈពេលបីឆ្នាំ នៃការអនុវត្តកម្មវិធីការគ្រប់គ្រងតាមសាលារៀន គាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រស្នូលនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ សម្រាប់ពន្លឿនអភិបាលកិច្ច តាមរយៈវិមជ្ឈការអំណាចទៅមូលដ្ឋាន ដើម្បីជួយឱ្យសេវាសាធារណៈបម្រើផលប្រយោជន៍ប្រសើរបំផុតសម្រាប់ប្រជាជន និងកសាងប្រទេសជាតិ។ យុទ្ធសាស្ត្រនេះគាំទ្រការអនុវត្តកិច្ចការចំនួន៣ នៃយុទ្ធសាស្ត្រស្នូលរបស់យុទ្ធសាស្ត្រចតុកោណ រួមមាន៖ ១)ការធ្វើទំនើបកម្មស្ថាប័ន ២)ការពង្រឹងប្រសិទ្ធភាពការងារ និង ៣)ការរក្សាភាពស្អាតស្អំនៅក្នុងសេវាសាធារណៈ។

ជាងនេះទៅទៀត យុទ្ធសាស្ត្រនេះបានរួមចំណែកអនុវត្តគោលនយោបាយនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ (២០១៩-២០២៣) ពោលគឺ ១)ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ២)ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ និងក៏បានគាំទ្រដល់កំណែទម្រង់ឧត្តមសិក្សាដែលបានរៀបរាប់នៅក្នុងផែនទីបង្ហាញផ្លូវការអប់រំកម្ពុជា ឆ្នាំ២០៣០។

ជារួម ក្រសួងអប់រំ យុវជន និងកីឡាបានរៀនសូត្ររយៈពេលជាង២០ឆ្នាំ ក្នុងការអនុវត្តវិមជ្ឈការ ហើយយកការរៀនសូត្រនេះមកអនុវត្ត ជាមួយនឹងការបូកផ្សំការងារកំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ តាំងពីឆ្នាំ២០១៤ ដែលធ្វើឱ្យកិច្ចការមួយនេះមានប្រសិទ្ធភាព ដូចមានចែងលម្អិតនៅក្នុងផែនការសកម្មភាពនេះ។

គោលដៅនៃការរៀបចំឯកសារនេះ ដើម្បីដោះស្រាយបញ្ហាប្រឈមគន្លឹះចំនួនបី ក្នុងចំណោមបញ្ហាគន្លឹះប្រាំ ដែលបានលើកឡើងនៅក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥ គឺ៖ ១)កង្វះភាពជាអ្នកដឹកនាំ ការសម្របសម្រួល និងការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាពក្នុងគ្រប់កម្រិត ជាពិសេសបញ្ហាធនធានមនុស្ស និងជំនាញ ២)ការអភិវឌ្ឍមូលដ្ឋានចំណេះដឹងផ្នែកបច្ចេកទេស និងជំនាញ ដែលជាអាទិភាពសំខាន់ ដើម្បីប្រែក្លាយកម្លាំងពលកម្មឱ្យមានជំនាញនិងមានសមត្ថភាពឈោងចាប់យកបច្ចេកទេស និងបច្ចេកវិទ្យាខ្ពស់ ៣)បញ្ហាទីផ្សារការងារ និងទំនាក់ទំនងវិជ្ជាជីវៈ ដែលជាគន្លឹះធានាស្ថិរភាពទីផ្សារការងារ និងការផ្គត់ផ្គង់កម្លាំងពលកម្ម ក៏ដូចជាការលើកកម្ពស់ផលិតភាព និងជីវភាពរបស់ប្រជាពលរដ្ឋ។

ម៉្យាងវិញទៀត រាជរដ្ឋាភិបាលបានកំណត់យ៉ាងច្បាស់នូវចក្ខុវិស័យរបស់ខ្លួន ដោយត្រូវជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា ពីឧស្សាហកម្មអតិពលកម្ម ឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥ តាមរយៈការតភ្ជាប់ទៅនឹងខ្សែចង្វាក់តម្លៃសកល សមាហរណកម្មទៅក្នុងបណ្តាញផលិតកម្មតំបន់ និងការអភិវឌ្ឍកន្សោមផលិតកម្មប្រទាក់ក្រឡា ទន្ទឹមនឹងការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាពឧស្សាហកម្មក្នុងស្រុក ហើយបន្តឈានទៅអភិវឌ្ឍឧស្សាហកម្មទំនើប ដោយផ្អែកជាសំខាន់លើមូលដ្ឋានបច្ចេកវិទ្យានិងចំណេះដឹង។ ឆ្លើយតបទៅនឹងយុទ្ធសាស្ត្រគន្លឹះទី៤ របស់រាជរដ្ឋាភិបាលក្នុងការសម្រេចបាននូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ដែលតម្រូវឱ្យមានការសម្របសម្រួល

គោលនយោបាយគាំទ្រ (រួមមាន៖ ការអភិវឌ្ឍធនធានមនុស្ស/បណ្តុះបណ្តាលជំនាញ ការកែលម្អទំនាក់ទំនងវិជ្ជាជីវៈ) តាមរយៈ (ក)ការផ្សារភ្ជាប់តម្រូវការជំនាញ និងបំណិន សម្រាប់អភិវឌ្ឍសង្គមជាមួយឯកទេសសិក្សា (ខ) ការផ្តល់ជំនាញទន់បន្ថែមលើជំនាញឯកទេស។

តាមរយៈការអនុវត្តគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា បានធ្វើឱ្យមានការផ្សារភ្ជាប់រវាងអនុវិស័យពាក់ព័ន្ធ។ ដូច្នេះដើម្បីសម្រេចគោលបំណងខាងលើ គឺតម្រូវឱ្យធ្វើសុខដុមនីយកម្មរវាងអនុវិស័យមធ្យមសិក្សា និងឧត្តមសិក្សា ដោយបញ្ចូលកម្មវិធីប្រឹក្សាអាជីព កម្មវិធីសហគ្រិនភាព វិធីសាស្ត្របង្រៀនតាមបែបចម្រុះ ការលើកកម្ពស់ការសិក្សា មុខវិជ្ជាស្ទែម (STEM) ការរៀបចំពិព័រណ៍វិទ្យាសាស្ត្រ និងការរៀបចំគោលនយោបាយគាំទ្រ ដើម្បីជានាសង្គតិភាពគោលនយោបាយនិងថវិកា។

ក្រសួងអប់រំ យុវជន និងកីឡាសូមសំដែងនូវការកោតសរសើរដ៏ស្មោះ ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដែលបានចូលរួមគាំទ្រ និងរួមចំណែកដល់ការរៀបចំយុទ្ធសាស្ត្រអនុវិស័យការអប់រំមធ្យមសិក្សា ២០២១-២០៣០ ឱ្យសម្រេចជាស្ថាពរ។ ក្រសួងសង្ឃឹមថាអ្នកពាក់ព័ន្ធទាំងអស់នឹងបន្តគាំទ្រគ្រប់ធនធាន និងចូលរួមអនុវត្តយុទ្ធសាស្ត្រនេះឱ្យទទួលបានលទ្ធផលជាផ្លែផ្កា ដើម្បីអនាគតរបស់កុមារ និងយុវជនកម្ពុជា និងការអភិវឌ្ឍប្រទេស។

ថ្ងៃសុក្រ [illegible] ខែ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# មាតិកា


ទំព័រ

**ជំពូក១ ៖ សេចក្តីផ្តើម** ........ 1

**ជំពូក២៖ ចក្ខុវិស័យការអប់រំមធ្យមសិក្សា** ........ 4

**ជំពូក៣៖ ប្រព័ន្ធផ្តល់លទ្ធភាពអនុវត្តកំណត់ព្រំដែនអំណាចដើម្បីអនុវត្តកិច្ចការត្រូវធ្វើ** ........ 8

ក. អំពីរចនាសម្ព័ន្ធ ........ 8

១. អនុវិស័យ ........ 8

២. រចនាសម្ព័ន្ធនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ........ 8

៣. រចនាសម្ព័ន្ធគ្រប់គ្រងតំបន់ ........ 9

៤. គំរូរចនាសម្ព័ន្ធគ្រប់គ្រងការិយាល័យ ........ 9

ង. ស្តង់ដាសហគមន៍សាលារៀន ........ 13

ច. ការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សា ........ 17

**ជំពូក៤ ៖ ប្រព័ន្ធផ្តល់អំណាចធានា សម្រេចផលសម្រេចដើម្បី កសាងគណនេយ្យភាព** ........ 28

ក. ក្របខ័ណ្ឌលទ្ធផល ........ 28

ខ. ការពិនិត្យតាមដាននិងការរាយការណ៍ផ្អែកលើលទ្ធផល ........ 32

គ. ការធ្វើកម្មវិធីវិនិយោគ និងផែនការអនុវត្ត ........ 32

ឃ. ការអភិវឌ្ឍធនធានមនុស្ស ........ 44

**ជំពូក៥ ៖ ប្រព័ន្ធផ្តល់ថាមពលការងារកសាងនិងរក្សាគុណតម្លៃដើម្បីធានានិរន្តរភាព** ........ 47

ក. ប្រព័ន្ធគ្រប់គ្រងការអនុវត្តការងារមន្ត្រី ........ 47

ខ. ការវាយតម្លៃការងារមន្ត្រី ........ 53

# ជំពូក១
# សេចក្តីផ្តើម

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ បានកំណត់ទិសដៅធ្វើឱ្យប្រទេសកម្ពុជាឈានទៅសម្រេចបានឋានៈ ជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និង ជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដោយហេតុនេះហើយ បានជាការកសាងធនធានមនុស្សត្រូវបានចាត់ទុកជា យុទ្ធសាស្ត្រទីមួយនៃយុទ្ធសាស្ត្រចតុកោណ។ ក្រសួងអប់រំ យុវជន និងកីឡា រៀបចំយុទ្ធសាស្ត្រការអប់រំមធ្យមសិក្សានេះក្នុងគោលបំណងអនុវត្តនូវការកំណត់ទិសខាងលើ។ យុទ្ធសាស្ត្រនេះនឹងផ្តល់លទ្ធភាពដល់សិស្សមធ្យមសិក្សាភាគច្រើនទទួលបានសមត្ថភាពបញ្ញាមានកម្រិតល្អប្រសើរ និងល្អ សមត្ថភាពបំណិនរកចំណូល និងសមត្ថភាពចិត្តសង្គម ដែលនៅពេលអនាគត គេនឹងអាចមានលទ្ធភាពបន្តការរៀនសូត្រនៅឧត្តមសិក្សា ឬ អាចចូលទៅក្នុងទីផ្សារការងារ ហើយក៏នឹងអាចចាកចេញ ពីភាពក្រីក្របាន។

ក្រសួងអប់រំ យុវជន និងកីឡា បានបញ្ជាក់ច្បាស់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំថា គុណភាពអប់រំ ជាអាទិភាពតែមួយគត់ ដែលក្រសួងនឹងត្រូវចំណាយថាមពល និងធនធានកែលម្អគុណភាពសិក្សារៀនសូត្ររបស់សិស្ស។ នៅពេលដែលគុណភាពសិក្សារបស់សិស្សកើនឡើង នោះនឹងទាញការចូលរៀននៅមធ្យមសិក្សាកើនឡើងផងដែរ។ ដូចនេះក្រសួងនឹងផ្តោតការយកចិត្តទុកដាក់លើការរៀបចំយុទ្ធសាស្ត្រដែលមានភាពជាក់ស្តែង និងដែលអាចអនុវត្តបានដើម្បីផ្សារភ្ជាប់គ្នារវាងគោលនយោបាយរបស់ក្រសួង ទៅនឹងការបណ្តុះបណ្តាលធនធានគ្រូបង្រៀន និងមន្ត្រីអប់រំ ជាមួយនឹងការផ្លាស់ប្តូរឱ្យមានការរីកចម្រើននៅសាលារៀននិងការសិក្សារៀនសូត្ររបស់សិស្ស។ ការអនុវត្តបែបនេះនឹងមានចែងនៅក្នុងយុទ្ធសាស្ត្រការអប់រំមធ្យមសិក្សា រួមផ្សំជាមួយសេចក្តីណែនាំប្រតិបត្តិយុទ្ធសាស្ត្រសហគមន៍សាលារៀន និងផែនការសកម្មភាពកសាងសមត្ថភាពអនុវិស័យមធ្យមសិក្សា ដែលនឹងនាំឱ្យអនុវិស័យអាចសម្រេចបាននូវវត្ថុបំណងគោលនយោបាយ កែលម្អគុណភាពមធ្យមសិក្សា និងការកសាងសមត្ថភាពដឹកនាំ និងគ្រប់គ្រងអនុវិស័យ ដែលជាវត្ថុបំណងមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣។ ដើម្បីអាចសម្រេចបាននូវវត្ថុបំណងគោលនយោបាយទាំងពីរ អនុវិស័យការអប់រំមធ្យមសិក្សា ត្រូវដោះស្រាយនូវចំណោទទាំងនេះ គឺ ១) ការផ្តល់ធាតុចូលដល់សាលាមធ្យមសិក្សា ២) ការកែលម្អគុណភាពមធ្យមសិក្សា ៣) ការកែលម្អសមធម៌នៅមធ្យមសិក្សា និង ៤) ការជួយសិស្សមធ្យមសិក្សាត្រៀមចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សា ឬ ចូលក្នុងទីផ្សារការងារ។

***ការដោះស្រាយចំណោទនៃការចូលរៀន*** ក្រសួងអប់រំ យុវជន និងកីឡា បានប្រឹងប្រែងបង្កើនការចូលរៀននៅមធ្យមសិក្សា ពិសេសនៅកម្រិតមធ្យមសិក្សាបឋមភូមិ។ ការកើនឡើងការចូលរៀននៅមធ្យមសិក្សាបឋមភូមិ បានកើនឡើងពី ៥៥,១០ភាគរយ ដល់៦០,៧០ភាគរយ និងសម្រាប់មធ្យមសិក្សាទុតិយភូមិពី ២៥,៣ ភាគរយ ដល់៣២,២០ ភាគរយ នៅចន្លោះឆ្នាំ ២០១៤ ដល់ ២០២០។ ការចូលរៀននៅមធ្យមសិក្សាពិសេស មធ្យមសិក្សាទុតិយភូមិនៅមានគម្លាតច្រើនបើធៀបជាមួយប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់។ អនុវិស័យអប់រំមធ្យមសិក្សា នឹងប្រើយុទ្ធសាស្ត្រដែលមានចែងក្នុងយុទ្ធសាស្ត្រនេះសម្រាប់បង្កើនការចូលរៀននៅមធ្យមសិក្សា។ មូលហេតុសំខាន់ដែលនឹងអាចបង្កើនការចូលរៀននៅមធ្យមសិក្សាបានគឺ ការកែលម្អគុណភាពសិក្សារបស់សិស្សទាំងលើសមត្ថភាពបញ្ញា និងសមត្ថភាពបំណិនរកចំណូល។ ប្រសិនបើមាតាបិតានិងសិស្សនៅបឋមសិក្សាឃើញជាក់ស្តែងថា សិស្សដែលបានសិក្សានៅមធ្យមសិក្សារៀនចេះទាំងសមត្ថភាពបញ្ញា និងមានសមត្ថភាពរកចំណូលបាន នោះមាតាបិតានឹងប្រឹងប្រែងអស់លទ្ធភាពឱ្យ

កូនបានចូលរៀននៅសាលាមធ្យមសិក្សា។ អ្វីដែលក្រសួងនឹងត្រូវផ្ដោតដើម្បីទទួលនូវបរិមាណសិស្សកើនឡើង បន្ថែមលើការកែលម្អគុណភាពគឺ ការផ្ដល់ធាតុចូលមានគុណភាពសំខាន់ៗដូចជា បន្ទប់រៀន បន្ទប់និងឧបករណ៍ពិសោធន៍ បន្ទប់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន បណ្ណាល័យ និងឧបករណ៍ព័ត៌មានមានវិទ្យា កុំព្យូទ័រសម្រាប់បង្រៀន និងរៀនឌីជីថល គ្រូបង្រៀន នាយករង និងនាយកសាលារៀន ដែលបានទទួលការបណ្ដុះបណ្ដាលពីគ្រឹះស្ថានបណ្ដុះបណ្ដាលដែលមានស្ដង់ដាជាដើម។

***ការដោះស្រាយចំណោទពីប្រសិទ្ធភាពសិក្សារបស់សិស្ស*** ការធ្វើតេស្តវាយតម្លៃថ្នាក់ជាតិ និងអន្តរជាតិបង្ហាញថាកម្រិតលទ្ធផលសិក្សារបស់សិស្សនៅទាប។ លទ្ធផលពីការធ្វើតេស្តថ្នាក់ជាតិសិស្សថ្នាក់ទី១១ បង្ហាញថាបរិមាណសិស្សលើ៧០ ភាគរយ មានសមត្ថភាពទាបជាងសមត្ថភាពកម្រិតមូលដ្ឋានលើមុខវិជ្ជាគណិតវិទ្យា និងស្មើតែ៦០ ភាគរយ មានសមត្ថភាពទាបលើការសរសេរភាសាខ្មែរ។ សិស្សមានសមត្ថភាពទាបមុខវិជ្ជាគណិតវិទ្យានិងសរសេរភាសាខ្មែរ មិនអាចរៀនមុខវិជ្ជាវិទ្យាសាស្ត្រពិតដូចជា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យាបានទេ។ ដូចគ្នានេះដែរ សិស្សក៏មិនអាចរៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គមបានដែរ។ ដើម្បីដោះស្រាយចំណោទពាក់ព័ន្ធនឹងប្រសិទ្ធភាពសិក្សារបស់សិស្ស សាកលលោកបានប្រាប់នូវពិសោធន៍មួយចំនួនដូចជា ១) ត្រូវអនុវត្តវិមជ្ឈការអប់រំ តាមរយៈការផ្ដល់អំណាចដល់សាលារៀន និងសហគមន៍ ២) ការផ្សារភ្ជាប់សាកលវិទ្យាល័យជាមួយសាលារៀនក្នុងការបណ្ដុះបណ្ដាលគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន និង ៣) ការផ្ដោតលើការធ្វើឱ្យថ្នាក់រៀនមានដំណើរការ តាមរយៈការធ្វើផែនការ ដែលផ្ដល់លទ្ធភាពដល់គ្រូបង្រៀននិងសិស្សក្នុងការអនុវត្តការបង្រៀននិងរៀនផ្ដោតលើមេរៀននីមួយៗ ហើយលទ្ធភាពទាំងនេះគឺ ការធ្វើឱ្យមានការផ្សារភ្ជាប់គ្នារវាងវត្ថុបំណងមេរៀន សំណុំសំណួរតេស្តស្តង់ដាតាមកម្រិតសំណួរតេស្តអន្តរជាតិសម្រាប់មេរៀន (មាននៅក្នុងឌីជីថល) សន្លឹកកិច្ចការសិក្សារបស់សិស្សតាមកម្រិតសំណួរតេស្តស្តង់ដា មេរៀនពីសៀវភៅសិក្សាគោល ការណែនាំពីវិធីបង្រៀនមេរៀន សម្រាប់គ្រូបង្រៀន។ល។ ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តកិច្ចការទាំងបីខាងលើនេះរយៈពេលបីឆ្នាំកន្លងមក ហើយធ្វើឱ្យមានការប្រែប្រួលវិជ្ជមាន ទាំងលើដំណើរការសាលារៀនបំពេញបាននូវស្តង់ដាសាលារៀនមានប្រសិទ្ធភាព ទាំងដំណើរការធ្វើតេស្តស្តង់ដា ទាំងដំណើរការបង្រៀន និងរៀន ដែលធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សកើនឡើង ហើយបរិមាណសិស្សធ្លាក់បានថយចុះយ៉ាងច្រើន។ ព្រមជាមួយគ្នានោះ សហគមន៍និងរដ្ឋអំណាចមូលដ្ឋានបានចូលរួមយ៉ាងសកម្មជាមួយសាលារៀន។ បើទោះបីជាមានការប្រែប្រួលវិជ្ជមានទាំងនេះក៏ដោយ សហគមន៍មានការប្តេជ្ញាចិត្តជាមួយសាលារៀន បន្តធ្វើកិច្ចការនេះ ដើម្បីសិស្សសាងសង់សមត្ថភាពរៀនមុខវិជ្ជាបានល្អប្រសើរនិងល្អ សមត្ថភាពបំណិនកសិកម្មឬបច្ចេកទេសសម្រាប់រកចំណូល និងសមត្ថភាពចិត្តសង្គមសម្រាប់កសាងខ្លួននិងគ្រួសាររស់មានសុខមាលភាព។

***ចំណោទក្នុងការកែលម្អសមធម៌អប់រំមធ្យមសិក្សានៅមានដូចជា*** សមធម៌សម្រាប់សិស្សក្រីក្រ យុវជនគ្រួសារយ៉ាប់យ៉ឺន ពិសេសជនជាតិ យេនឌ័រ ពិការភាព ។ល។ ក្រសួងបន្តអនុវត្តវិមជ្ឈការអប់រំក្នុងការដោះស្រាយបញ្ហាទាំងនេះ ជាមួយនឹងការផ្ដល់ធាតុចូលជាតម្រូវការដល់សិស្សទាំងអស់។ អាហារូបករណ៍ថ្នាក់ជាតិនិងត្រូវអនុវត្តបន្ត រួមជាមួយការជួយដល់សាលារៀនអប់រំពិសេស និងការអនុវត្តសុខភាពសិក្សាសិស្សនៅតាមសាលារៀនតាមបរិបទមាននិរន្តរភាពនៅសហគមន៍សាលារៀន។ ក្រសួងអប់រំនឹងវិនិយោគលើ ការបង្រៀន និងរៀនតាមបែបឌីជីថល ព្រោះថាកិច្ចការនេះជាវិធីសាស្ត្រមួយជួយដល់ការកែលម្អការអប់រំមានសមធម៌សម្រាប់សិស្សដែលជួបប្រទះ ការលំបាក។

***ចំណោទនៃការបន្តការសិក្សានៅឧត្តមសិក្សានៅតែបន្ត*** ព្រោះថាការចូលរៀននៅឧត្តមសិក្សាបច្ចុប្បន្នមានតែ១០ ភាគរយប៉ុណ្ណោះ។ មូលហេតុនាំឱ្យមានការចូលរៀនទាបនេះមាន ១) សមត្ថភាពសិក្សានៅមធ្យមសិក្សាទាបដែលសិស្សពិបាកនឹងរៀននៅឧត្តមសិក្សាបាន និង២) បញ្ហាកង្វះហិរញ្ញវត្ថុ។ សម្រាប់មូលហេតុគុណភាពនឹងត្រូវដោះស្រាយបានដូចមានលើកឡើងខាងលើ តែត្រូវដោះស្រាយនៅទីនេះនូវបញ្ហា កង្វះហិរញ្ញវត្ថុ ។ ក្រសួងអប់រំ យុវជន និងកីឡានឹងបន្តរៀបចំគម្រោងវិនិយោគ ផ្សារភ្ជាប់គ្នារវាងគ្រឹះស្ថានឧត្តមសិក្សាជាមួយសាលាមធ្យមសិក្សា ដើម្បីបង្រៀនបំណិនកសិកម្ម និងបច្ចេកទេសដល់សិស្សសាលាមធ្យមសិក្សា។ ពេលសិក្សានិងអនុវត្តបំណិននេះ សិស្សនឹងត្រូវរៀនតាមរបៀបចម្រុះមុខវិជ្ជា រួមជាមួយការរកចំណូល និងសន្សំប្រាក់សម្រាប់ចូលរៀននៅឧត្តមសិក្សា។ ការអនុវត្តបំណិនរកចំណូលនេះមានចែងនៅក្នុងសៀវភៅប្រតិបត្តិយុទ្ធសាស្ត្រសហគមន៍សាលារៀន ដែលជាសៀវភៅកែលម្អថ្មីដោយសារបានពិសោធន៍រៀនសូត្រពីការអនុវត្តសៀវភៅប្រតិបត្តិការគ្រប់គ្រងតាមសាលារៀន។ យុទ្ធសាស្ត្រអនុវិស័យអប់រំមធ្យមសិក្សានឹងរៀបចំឡើងបន្សីគ្នាជាមួយយុទ្ធសាស្ត្រអនុវិស័យឧត្តមសិក្សា ដើម្បីឱ្យអនុវិស័យទាំងពីរសហការ និងសហប្រតិបត្តិការជាមួយគ្នា។

***ការធ្វើឱ្យខ្លួនជាមន្ត្រីក្លាយជាមនុស្សថ្មី*** តែអ្វីដែលមានតម្លៃបន្ថែមពីកិច្ចការត្រូវធ្វើខាងលើគឺ មន្ត្រីម្នាក់ត្រូវរៀនសូត្រក្លាយជាមនុស្សថ្មីដែលស្របគ្នាជាមួយនឹងការធ្វើកិច្ចការតាមរបត់ថ្មី។ មន្ត្រីត្រូវរៀនស្វែងស្គាល់ការពិតពីខ្លួនឯង តាមរយៈការគិតយ៉ាងសាមញ្ញថា បើធ្វើកិច្ចការមួយត្រូវតែទទួលបាននូវលទ្ធផលមួយ។ លទ្ធផលដែលបង្ហាញថា សាលារៀនមានការប្រែប្រួល ថ្នាក់រៀនមានការប្រែប្រួល សិស្សចូលរៀនកើនឡើង បន្តការសិក្សារហូតចប់ភូមិសិក្សា រៀនទទួលបាននូវសមត្ថភាពបញ្ញា ចិត្តសង្គម និងបច្ចេកទេសសម្រាប់រកចំណូល។ សូមចៀសវាងនូវ អត្តចរិត មិនរវល់ធ្វើដឹងចោល។ ប្រសិនបើមន្ត្រីម្នាក់ៗនៅបន្តធ្វើកិច្ចការដែលមិនទទួលបានលទ្ធផល តែបានត្រឹមទទួលបាននូវក្រដាសបោះពុម្ពនោះគឺជាការខាតបង់ទាំងមូលនិធិ និងពេលវេលាហើយ។ ចំណោទតែមួយគត់ដែលមន្ត្រីម្នាក់ៗត្រូវស្វែងរកចម្លើយគឺ តើបុគ្គលម្នាក់ៗត្រូវចំណាយ ថវិការដ្ឋប្រចាំឆ្នាំជាង១០ ភាគរយ ដែលមិនមែនជា បៀវត្សរ៍ តាមរបៀបយ៉ាងណាដើម្បីធ្វើឱ្យការចំណាយ បៀវត្សរ៍ជាង៨០ ភាគរយ មានប្រសិទ្ធភាព និងប្រសិទ្ធផល ព្រមជាមួយគ្នានូវការអភិវឌ្ឍ ដែលមាននិរន្តរភាពកសាងបាននូវធនធានមនុស្សសម្រាប់ប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់បាន។

ជាចម្លើយសរុប ដើម្បីដោះស្រាយចំណោទខាងលើ ក្រសួងអប់រំបានរៀបចំសៀវភៅប្រតិបត្តិ យុទ្ធសាស្ត្រអនុវិស័យអប់រំមធ្យមសិក្សានេះ។ គោលបំណងនិងកិច្ចការដែលមានកំណត់នៅក្នុងយុទ្ធសាស្ត្រស្នូលនៃយុទ្ធសាស្ត្រចតុ-កោណដំណាក់ការទី៤ វត្ថុបំណងនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងផែនការយុទ្ធសាស្ត្រអប់រំ ត្រូវបានយកជាក្របខ័ណ្ឌក្នុងការកសាងយុទ្ធសាស្ត្រអនុវិស័យនេះ។ ខ្លឹមសារយុទ្ធសាស្ត្រអនុវិស័យអប់រំមធ្យមសិក្សាមានបួនធំៗគឺ ១) ចក្ខុវិស័យអនុវិស័យជាការកំណត់កិច្ចការត្រូវធ្វើ ដែលមានខ្លឹមសារតូចៗដូចជា បេសកកម្ម គោលបំណងយុទ្ធសាស្ត្រ និងការផ្លាស់ប្តូរវប្បធម៌អង្គភាព និងគុណតម្លៃ ២) ផ្តល់លទ្ធភាពអនុវត្តកិច្ចការត្រូវធ្វើ ដល់អនុវិស័យដែលមានខ្លឹមសារតូចៗដូចជា រចនាសម្ព័ន្ធ តួនាទីនិងភារៈកិច្ច ស្តង់ដាសហគមន៍សាលារៀន និងការវាយតម្លៃ ៣) ផ្តល់អំណាចដើម្បីសម្រេចលទ្ធផល ដែលមានខ្លឹមសារតូចៗដូចជា តារាងក្របខ័ណ្ឌលទ្ធផលរយៈពេល១០ឆ្នាំ ការកសាងធនធានមនុស្ស ការពិនិត្យតាមដាននិងវាយតម្លៃ និងការកសាងកម្មវិធីវិនិយោគ និង ៤) ផ្តល់ថាមពលធ្វើការងារដល់មន្ត្រី ដែលមានខ្លឹមសារតូចៗដូចជា ការអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់មន្ត្រី ការផ្តល់រង្វាន់ការអភិវឌ្ឍគន្លងអាជីព ការដឹកនាំផ្អែកលើលទ្ធផល និងនិរន្តរភាពអនុវិស័យ។

# ជំពូក២
# ចក្ខុវិស័យការអប់រំមធ្យមសិក្សា

ចក្ខុវិស័យអប់រំមធ្យមសិក្សាផ្តោតលើ កិច្ចការដែលជាតួនាទីអនុវិស័យត្រូវធ្វើ (បេសកកម្ម) តួលេខកំណត់នូវភាពជោគជ័យនៃបេសកកម្មអនុវិស័យក្នុងរយៈពេលមួយកំណត់ (គោលបំណង) ជម្រើសប្រសើរបំផុតត្រូវអនុវត្តដើម្បីសម្រេចគោលបំណង(យុទ្ធសាស្រ្ត) របៀបដែលអង្គភាពត្រូវដំណើរការតាមបែបរិមជ្ឈការ (វប្បធម៌អង្គភាព) និងគុណតម្លៃដែលគ្រប់ថ្នាក់ដឹកនាំ ថ្នាក់គ្រប់គ្រង និងមន្រ្តីមានជំនឿថាជាគំនិតល្អដែលត្រូវប្រតិបត្តិតាម។

## ១. បេសកកម្មអនុវិស័យ

(១) បង្កើនការចូលរៀននៅមធ្យមសិក្សា

(២) ជួយសិស្សរៀនមានសមត្ថភាពបញ្ញាល្អប្រសើរនិងល្អ រៀនចប់មធ្យមសិក្សា រកចំណូលបានសមរម្យ និងអាចបន្តទៅរៀននៅឧត្តមសិក្សាបាន។

## ២. គោលបំណង

(១) បង្កើនការចូលរៀននៅមធ្យមសិក្សាដល់ ៧៦ ភាគរយ មុនឆ្នាំ២០៣០

(២) ជួយសិស្សរៀនមានសមត្ថភាព ល្អប្រសើរនិងល្អ ៨០ ភាគរយ មុនឆ្នាំ២០៣០

## ៣. សូចនាករផលសម្រេចអនុវិស័យ

(១) ភាគរយសិស្សចូលរៀននៅមធ្យមសិក្សា (៧៦ ភាគរយ) មុនឆ្នាំ២០៣០

(២) ភាគរយសិស្សរៀនមានសមត្ថភាពល្អនិងល្អប្រសើរ (៨០ ភាគរយ) មុនឆ្នាំ២០៣០ សូចនាករផលសម្រេច

(៣) សូចនាករគន្លឹះនាំសម្រេច សូចនាករផលសម្រេច

(៤) ចំនួនសាលាមធ្យមសិក្សាបំពេញបានស្តង់ដាអប្បបរមាស្តង់ដាសាលារៀនមានប្រសិទ្ធភាព

(៥) ចំនួនគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនបានរៀបចប់វគ្គបង្កើនគុណវុឌ្ឍិគ្រូបង្រៀន និងគុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន

(៦) ចំនួនសាលារៀនដែលថ្នាក់រៀនទាំងអស់អនុវត្តផែនការបង្រៀនជួយសិស្សរៀនទាន់កម្មវិធីសិក្សា

## ៤. យុទ្ធសាស្រ្ត និងការផ្លាស់ប្តូរ

(១) ផ្តល់ស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុដល់សហគមន៍សាលារៀន។ យុទ្ធសាស្រ្តនេះនាំឱ្យសហគមន៍សាលារៀនក្លាយជាម្ចាស់សាលារៀន មានអំណាចសម្រេចចិត្តដោះស្រាយបញ្ហាទាន់ពេលវេលា និងចូលរួមគ្រប់ប្រភេទធនធានសម្រាប់អភិវឌ្ឍសាលារៀន។

(២) សហការជាមួយមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញបង្កើនគុណវុឌ្ឍិគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនដែលធានាថាថ្នាក់រៀនមានដំណើរការសម្រាប់ការសិក្សាសិស្សម្នាក់ៗ។ យុទ្ធសាស្ត្រផ្សារភ្ជាប់គោលនយោបាយគ្រូបង្រៀន ជាមួយការបណ្តុះបណ្តាលគ្រូ និងនាំទៅរកការផ្លាស់ប្តូរវិជ្ជមាននៅសាលារៀននិងថ្នាក់រៀន។

(៣) អនុវត្តកម្មវិធីបំណិនរកចំណូលដើម្បីធានាឱ្យសិស្សរៀនមានសមត្ថភាពសម្រាប់ជីវិត រកចំណូល និងការសិក្សានៅឧត្តមសិក្សា។ យុទ្ធសាស្ត្រនាំសិស្សរៀនមានការរីករាយ កសាងបាន សមត្ថភាពបញ្ញាឬមុខវិជ្ជា ចិត្តសង្គម និងសមត្ថភាពរកចំណូល។

(៤) បង្កើតនិងអនុវត្តកម្មវិធីធានារ៉ាប់រងសង្គម និងអភិវឌ្ឍសមត្ថភាពជាប្រចាំសម្រាប់គ្រូបង្រៀននិងនាយកសាលារៀន។ យុទ្ធសាស្ត្រនាំសាលារៀនកសាងបាននូវទឹកចិត្តធ្វើការងាររបស់មន្ត្រី នាំមន្ត្រីអនុវត្តបាននូវការរៀនសូត្រជាប់ជាប្រចាំនិងការពារសិស្សនិងគ្រួសារសិស្ស និងមន្ត្រីចៀសផុតពីភាពក្រីក្រ។

(៥) បង្កើតកម្មវិធីប្រកួតប្រជែងសមត្ថភាពសិស្សសាលារដ្ឋ និងសាលាឯកជន។ យុទ្ធសាស្ត្រនេះនាំឱ្យសាលារដ្ឋ និងសាលាឯកជនប្រឹងប្រែងកែលម្អគុណភាពបង្រៀននិងរៀន បើពុំដូច្នោះទេសាលារៀននឹងឈានទៅដល់ដំណាក់កាលគ្មានសិស្សចូលរៀន។ ចំពោះសាលារៀនឯកជនដែលខ្សោយ ការប្រឹងប្រែងនេះគឺការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនឯកជនឱ្យរៀនសូត្រពីកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀននិងគណៈ គ្រប់គ្រងសាលារៀនដូចជាសាលារដ្ឋដែរ។

## ៦. ល្បិចអនុវត្តយុទ្ធសាស្ត្រ

| យុទ្ធសាស្ត្រ | ល្បិចឬរបៀបអនុវត្តយុទ្ធសាស្ត្រ |
|---|---|
| ផ្តល់ស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុដល់សាលារៀនសហគមន៍ | ១. រៀបចំនូវការធានាគុណភាព លើដំណើរការរដ្ឋបាល សេវា និងប្រព័ន្ធ |
| | ២. អនុវត្តការវាយតម្លៃគុណភាពសាលារៀន លើដំណើរការរដ្ឋបាល សេវា និងប្រព័ន្ធ |
| | ៣. បង្ហាញគណនេយ្យភាព ជាភស្តុតាងពីគុណភាព |
| សហការណ៍ជាមួយមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញបង្កើនគុណវុឌ្ឍិគ្រូបង្រៀននិងគណៈគ្រប់គ្រងសាលារៀនដែលធានាថាថ្នាក់រៀនមានដំណើរការសម្រាប់ការសិក្សា | ១. កែសម្រួលកម្មវិធីសិក្សាសម្រាប់ការបង្កើនគុណវុឌ្ឍិគ្រូបង្រៀន និងនាយកសាលារៀន |
| | ២. កម្មវិធីលើកកម្ពស់គុណវុឌ្ឍិត្រូវតែផ្តោតជាអាទិភាពលើការដឹកដៃគ្រូធ្វើការអនុវត្តដើម្បីសម្រេចស្តង់ដាទី២ ការធ្វើឱ្យថ្នាក់រៀនមានដំណើរការសម្រាប់ការបង្រៀននិងរៀននៃសិស្សម្នាក់ៗ |
| | ៣. ការបញ្ចប់ការសិក្សាគឺមានលក្ខខណ្ឌថាស្តង់ដាទី២ គឺសម្រេចបាននូវពិន្ទុអប្បបរមានៃស្តង់ដា |

| | |
|---|---|
| របស់សិស្ស ម្នាក់ៗ | |
| អនុវត្តកម្មវិធីបំណិនរកចំណូលធានាសិស្សរៀនមានសមត្ថភាពសម្រាប់ជីវិត រកចំណូល និងការសិក្សានៅមហាវិទ្យាល័យ | ១. សហការការណ៍ជាមួយសាកលវិទ្យាល័យឯកទេសកសិកម្មនិងបច្ចេកទេសរៀបចំ និងអនុវត្តកម្មវិធីបំណិនរកចំណូលនៅសាលារៀន និងតាមផ្ទះសិស្ស |
| | ២. ពិនិត្យតាមដាននិងវាយតម្លៃកម្មវិធីធានាថាកម្មវិធីបំពេញបាននូវស្តង់ដាកម្មវិធី |
| | ៣. ផ្តល់ការឧបត្ថម្ភដល់គ្រូបង្រៀន សិស្ស គណៈគ្រប់គ្រង និងរក្សាមូលនិធិសម្រាប់ការពង្រីកកម្មវិធី |
| បង្កើតនិងអនុវត្តកម្មវិធីធានារ៉ាប់រងសង្គម និងអភិវឌ្ឍសមត្ថភាពជាប្រចាំសម្រាប់គ្រូបង្រៀននិងនាយកសាលារៀន | ១. ពិភាក្សាជាមួយគ្រូបង្រៀន សិស្ស និងមាតាបិតាពីការរៀបចំនិងអនុវត្តកម្មវិធីធានារ៉ាប់រងសង្គមនិងអភិវឌ្ឍសមត្ថភាពជាប្រចាំរបស់គ្រូបង្រៀននិងគណៈគ្រប់គ្រងសាលារៀន |
| | ២. អនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងារសម្រាប់គ្រូបង្រៀននិងគណៈគ្រប់គ្រងសាលារៀន |
| | ៣. ផ្តល់ប្រាក់កម្ចីដល់សិស្សដើម្បីរៀននៅឧត្តមសិក្សា |
| **បង្កើតកម្មវិធីប្រកួតប្រជែងសមត្ថភាពសិស្សសាលារដ្ឋ និងសាលាឯកជន** | ១. រៀបចំការប្រកួតប្រជែងជាប់ជាប្រចាំនៅក្នុងសាលារៀន ដើម្បីបង្កើនសមត្ថភាពរៀនសូត្រកម្រិតសាលារៀន |
| | ២. រៀបចំការប្រកួតប្រជែងជាប់ជាប្រចាំរវាងសាលារដ្ឋនិងសាលារដ្ឋ ដើម្បីបង្កើនសមត្ថភាពរៀនសូត្រកម្រិតរាជធានីឬខេត្ត និងប្រទេស |
| | ៣. រៀបចំការប្រកួតប្រជែងជាប់ជាប្រចាំរវាងសាលារដ្ឋនិងសាលាឯកជន ដើម្បីកែលម្អគុណភាពនិងបង្កើនសមត្ថភាពរៀនសូត្រនៃសិស្សសាលាឯកជន |

**៧. វប្បធម៌អង្គភាព**

វប្បធម៌អង្គភាពជារបៀបធ្វើការងារក្នុងអនុវិស័យ ពោលគឺ ជាវប្បធម៌ធ្វើការតាមបែបវិមជ្ឈការ ផ្តោតលើលទ្ធផល និងស្តង់ដា។ ខាងក្រោមនេះជាទិដ្ឋភាពវប្បធម៌ជារួមដែលអនុវិស័យបានកំណត់សម្រាប់អនុវត្តយុទ្ធសាស្ត្រ៖

១) រចនាសម្ព័ន្ធមានគម្លាតអំណាចទាប

២) អនុវត្តការងារមានស្តង់ដា និងសុវត្ថិភាពការងារ

៣) កសាងនិងរក្សាប្រយោជន៍រួម

៤) កសាងនិងរក្សាទំនាក់ទំនងជាមួយមនុស្សនិងគុណភាពជីវិត

៥) គោរពទំនៀមទម្លាប់ ឬ ផ្តោតការងាររយៈពេលវែងនាំឱ្យមានការផ្លាស់ប្តូរ

## ៨. គុណតម្លៃ

ជាជំនឿរបស់មន្ត្រីថាខាងក្រោមនេះសុទ្ធតែជាគំនិតល្អដែលមន្ត្រីបានព្រមព្រៀងគ្នាអនុវត្តក្នុងរយៈពេលយុទ្ធសាស្ត្រនេះ ហើយគំនិតល្អទាំងនេះនឹងក្លាយទៅជាគុណតម្លៃរបស់អនុវិស័យហើយ៖

- ផ្តោតលើលទ្ធផល សិស្សរៀនចេះ និងប្រយោជន៍រួម
- សុច្ចរិតភាព ជួយនាយកសាលានិងគ្រូបង្រៀន
- គោរពវិន័យនិងវិជ្ជាជីវៈ ទទួលខុសត្រូវ សីលធម៌រៀនសូត្ររហូត គណនេយ្យភាព
- តម្លាភាព ភាពស្មោះត្រង់
- ធ្វើការជាក្រុម ចែករំលែកពិសោធន៍ គោរពគ្នា សហប្រតិបត្តិការ។

# ជំពូក៣
# ប្រព័ន្ធផ្តល់លទ្ធភាពអនុវត្តកំណត់ព្រំដែនអំណាចដើម្បីអនុវត្តកិច្ចការគ្រូវធ្វើ

## ក. អំពីរចនាសម្ព័ន្ធ

### ១. អនុវិស័យ

រចនាសម្ព័ន្ធអនុវិស័យខាងក្រោមនេះ ជួយដល់អនុវិស័យមានទំនាក់ទំនងការងារប្រចាំថ្ងៃមានប្រសិទ្ធភាព ដោយសារតម្រូវការពេលខ្លីសម្រាប់ធ្វើការសម្រេចចិត្ត ភាពច្បាស់លាស់នៃកិច្ចការរបស់តួនាទីនីមួយៗ ភាពច្បាស់លាស់នៃការបែងចែកកិច្ចការ រវាងមន្ត្រីទាំងអស់តាមការិយាល័យ និងថ្នាក់ក្រោមជាតិ និងសាលារៀន។




### ២. រចនាសម្ព័ន្ធនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ



៣. រចនាសម្ព័ន្ធគ្រប់គ្រងតំបន់




៤. គំរូរចនាសម្ព័ន្ធគ្រប់គ្រងការិយាល័យ



### ខ. អំពីតួនាទី និងមុខងារធំៗតាមរចនាសម្ព័ន្ធ

| **រចនាសម្ព័ន្ធ** | **មុខងារធំៗ** |
|---|---|
| គណៈកម្មការគ្រប់គ្រងអនុវិស័យ | សម្រេចយុទ្ធសាស្ត្រ និងរកមូលនិធិ |
| អគ្គនាយកដ្ឋានអប់រំ | អនុវត្តយុទ្ធសាស្ត្រ |
| នាយកដ្ឋានមធ្យមសិក្សា | អនុវត្តកម្មវិធីវិនិយោគ |
| ការិយាល័យ | អនុវត្តស្គង់ដាកម្មវិធីវិនិយោគ |
| មន្ទីរអប់រំ យុវជន និងកីឡា រាជធានីឬខេត្ត | អនុវត្តការផ្តល់ធាតុចូល និងពង្រីកការអនុវត្តយុទ្ធសាស្ត្រសាលារៀន |
| ការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុកខណ្ឌ | សម្របសម្រួលការផ្តល់ធាតុចូល និងការអនុវត្តយុទ្ធសាស្ត្រសាលារៀន |
| សាលាមធ្យមសិក្សា | អនុវត្តយុទ្ធសាស្ត្រសាលារៀន |

### គ. អំពីតួនាទី និងការអនុវត្តយុទ្ធសាស្ត្រ

| **យុទ្ធសាស្ត្រ** | **តួនាទី** |
|---|---|
| ផ្តល់ស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុដល់សាលារៀនសហគមន៍ | អគ្គនាយករង អគ្គនាយកដ្ឋានអប់រំ |
| បង្កើតនិងអនុវត្តកម្មវិធីធានារ៉ាប់រងសង្គម និងអភិវឌ្ឍសមត្ថភាពជាប្រចាំសម្រាប់គ្រូបង្រៀននិងគណៈគ្រប់គ្រងសាលារៀន | |
| សហការណ៍ជាមួយមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញបង្កើនគុណវុឌ្ឍិគ្រូបង្រៀននិងគណៈគ្រប់គ្រងសាលារៀនដែលធានាថាថ្នាក់រៀនមានដំណើរការសម្រាប់ការសិក្សាសិស្សម្នាក់ៗ | អគ្គនាយករង នៃអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ |
| អនុវត្តកម្មវិធីបំណិនរកចំណូលធានាសិស្សរៀនមានសមត្ថភាពសម្រាប់ជីវិត រកចំណូល និងការសិក្សានៅឧត្តមសិក្សា | |
| បង្កើតកម្មវិធីប្រកួតប្រជែងសមត្ថភាពសិស្សសាលារដ្ឋ និងសាលាឯកជន | ប្រធាននាយកដ្ឋានមធ្យមសិក្សា |

ឃ. អំពីកិច្ចការធំៗរបស់ការិយាល័យនិងស្តង់ដាសហគមន៍សាលារៀន (មន្ត្រី តួនាទី និងបញ្ជីការងារ)

| ស្តង់ដាសាលារៀន និងផលសម្រេច | រចនាសម្ព័ន្ធ |
|---|---|
| ស្តង់ដាទី១៖ សាលាមានដំណើរការសម្រាប់ផលសម្រេចការអប់រំនិងការសិក្សារបស់សិស្ស | ការិយាល័យផែនការនិងស្រាវជ្រាវ |
| ស្តង់ដាទី២៖ ថ្នាក់រៀនមានដំណើរការសម្រាប់ការសិក្សារបស់សិស្សម្នាក់ៗ | ការិយាល័យបច្ចេកទេស និងការិយាល័យថ្នាក់ពីរភាសា |
| ស្តង់ដាទី៣៖ ភាពជាម្ចាស់នៃសាលាសហគមន៍ | ការិយាល័យមធ្យមសិក្សាចំណេះទូទៅ និងការិយាល័យអាហារូបករណ៍ |
| ស្តង់ដាទី៤៖ ដំណើរការរដ្ឋបាលនិងប្រតិបត្តិការសាលារៀន | ការិយាល័យរដ្ឋបាល និងការិយាល័យមធ្យមសិក្សា |
| ស្តង់ដាទី៥៖ គណនេយ្យភាពថ្នាក់ក្រោមជាតិនិងថ្នាក់ជាតិ | នាយកដ្ឋាន និងអគ្គនាយកដ្ឋាន |

១. កិច្ចការជាក់លាក់របស់គណៈកម្មការគ្រប់គ្រងអនុវិស័យ

- អនុម័តយុទ្ធសាស្ត្រអនុវិស័យ និងសេចក្តីណែនាំ
- សម្រេចចិត្តលើកម្មវិធីវិនិយោគរយៈពេល៥ឆ្នាំ
- សម្រេចចិត្តលើផែនការយុទ្ធសាស្ត្រថវិកា ផែនការប្រតិបត្តិប្រចាំឆ្នាំ និងថវិកាប្រចាំឆ្នាំ
- ប្រជុំប្រចាំឆមាសនិងប្រចាំឆ្នាំដើម្បីពិនិត្យការរីកចម្រើនការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងថវិកាប្រចាំឆ្នាំ និងយុទ្ធសាស្ត្រអនុវិស័យ
- រកមូលនិធិវិនិយោគដល់អនុវិស័យ និងទំនាក់ទំនងសាធារណៈ

២. កិច្ចការជាក់លាក់របស់អគ្គនាយកដ្ឋានអប់រំ

- ចូលរួមរៀបចំ និងពិនិត្យចុងបញ្ចប់លើសេចក្តីព្រៀងយុទ្ធសាស្ត្រអនុវិស័យ និងសេចក្តីណែនាំ
- ចូលរួមរៀបចំ និងពិនិត្យចុងបញ្ចប់លើសេចក្តីព្រាងកម្មវិធីវិនិយោគរយៈពេល៥ឆ្នាំ
- ផ្តល់យោបល់ដល់ការរៀបចំ និងពិនិត្យចុងបញ្ចប់លើផែនការយុទ្ធសាស្ត្រថវិកា ផែនការប្រតិបត្តិប្រចាំឆ្នាំ និងថវិកាប្រចាំឆ្នាំ
- រៀបចំការបង្ហាញ និងបង្ហាញការរីកចម្រើនពីការរីកចម្រើនការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងថវិកាប្រចាំឆ្នាំ និងយុទ្ធសាស្ត្រអនុវិស័យនៅក្នុងការប្រជុំប្រចាំឆមាសនិងប្រចាំឆ្នាំរបស់អនុវិស័យ
- ចូលរួម និងជួយដល់នាយកដ្ឋានក្នុងការអនុវត្តកម្មវិធីវិនិយោគ និងទំនាក់ទំនងសាធារណៈ

៣. កិច្ចការជាក់លាក់របស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

- រៀបចំ និងដាក់ស្នើសេចក្តីព្រាងយុទ្ធសាស្រ្ត និងសេចក្តីណែនាំដល់អគ្គនាយកដ្ឋានអប់រំ និងអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ ទទួលការព្រមព្រៀង
- រៀបចំកម្មវិធីវិនិយោគរយៈពេល៥ឆ្នាំ
- រៀបចំ និងដាក់ស្នើផែនការយុទ្ធសាស្រ្តថវិកា ផែនការប្រតិបត្តិឆ្នាំ និងថវិកាដល់អគ្គនាយកដ្ឋានអប់រំទទួលការព្រមព្រៀង
- អនុវត្តផែនការប្រតិបត្តិ និងសេចក្តីណែនាំ ស្របតាមផែនការយុទ្ធសាស្រ្តថវិកានិងកម្មវិធីវិនិយោគ
- ជ្រើសរើស ថែរក្សា និងគ្រប់គ្រងធនធានមនុស្សរបស់នាយកដ្ឋាន
- អនុវត្តអធិការកិច្ចគាំទ្រដល់កម្មវិធីបំណិនរកចំណូលរបស់សាលាមធ្យមសិក្សា និងទំនាក់ទំនងសាធារណៈ

៤. កិច្ចការជាក់លាក់របស់របស់ក្រុមការងារតំបន់

- ជួយសាលារៀនរៀបចំ ផែនការកែលម្អសាលារៀនតាមដំណាក់កាលនៃការគ្រប់គ្រងតាមសាលារៀន
- ជួយសាលារៀនអនុវត្តកិច្ចការបង្រៀននិងរៀនស្របតាមបច្ចេកទេសកំណត់ពីកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀននិងគ្រូបង្រៀន
- ជួយសាលារៀនអនុវត្តកម្មវិធីបំណិនរកចំណូលដែលធានាឈានដល់កម្រិតមាននិរន្តរភាព
- ជួយសាលារៀនផលិត ចងក្រង និងប្រើប្រាស់ទិន្នន័យដែលជឿជាក់បាន
- ជួយដល់មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡាក្នុងការរៀបចំ និងអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ
- ពិនិត្យតាមដានដំណើរការរីកចម្រើនក្នុងការអនុវត្តផែនការ និងវាយតម្លៃពីការសម្រេចលទ្ធផលគ្រោងរបស់មន្ទីរអប់រំ យុវជន និងកីឡា និងការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុងស្រុកខណ្ឌ

៥. កិច្ចការជាក់លាក់របស់របស់ការិយាល័យ(អាចបំបែកតាមការិយាល័យនីមួយៗ)

- រៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ និងគ្រោងថវិការបស់ការិយាល័យសម្រាប់អនុវត្តមុខងាររបស់ខ្លួន
- អនុវត្តកិច្ចការរបស់ខ្លួនទៅតាមមុខងាររបស់ការិយាល័យ
- អនុវត្តអធិការកិច្ចផ្តល់ការគាំទ្រក្នុងនាមជាសមាជិកតំបន់ដើម្បីធានាថាសាលារៀនអាចអនុវត្តយុទ្ធសាស្រ្តរបស់សាលារៀនបាន
- ប្រមូលទិន្នន័យដែលទាក់ទងនឹងមុខងារនិងសម្រាប់អនុវត្តកិច្ចការរបស់ខ្លួន
- ពិនិត្យតាមដានដំណើរការរីកចម្រើនក្នុងការអនុវត្តផែនការ និងពិនិត្យឡើងវិញពីការសម្រេចលទ្ធផលគ្រោង

ឃ-បរិមាណមន្ត្រី

| មន្ត្រីគ្រប់គ្រង និងការិយាល័យ | បរិមាណមន្ត្រីមានសមត្ថភាពតាមតម្រូវការ | បរិមាណមន្ត្រីមានសមត្ថភាពបច្ចុប្បន្ន | បរិមាណមន្ត្រីមានសមត្ថភាពខ្វះ |
|---|---|---|---|
| អនុប្រធាននាយកដ្ឋាន | ៥ | ២ | ពិសោធន៍ការប្តេជ្ញាចិត្តរៀនសូត្រមានសក្តានុពល |
| ការិយាល័យផែនការនិងស្រាវជ្រាវ | ៥ | ២ | |
| ការិយាល័យអាហារូបករណ៍ | ៥ | ១ | |
| ការិយាល័យមធ្យមសិក្សា | ៥ | ២ | |
| ការិយាល័យបច្ចេកទេស | ១០ | ២ | |
| ការិយាល័យថ្នាក់ពីរភាសា | ៥ | ០ | |
| ការិយាល័យរដ្ឋបាល | ៥ | ១ | |
| សរុប | ៤០ | ១០ | |

ង. ស្តង់ដាសហគមន៍សាលារៀន

**ថាមពលនៃព័ត៌មាន**

មន្ត្រីត្រូវមានចរិយារៀនសូត្ររហូត ដើម្បីកសាងបាននូវចំណេះដឹងពិតប្រាកដ ទើបអាចអនុវត្តកិច្ចការប្រកបដោយវិជ្ជាជីវៈបាន។ ចំណេះដឹងអាចត្រូវបានកសាងឡើងដោយការផ្តុំនូវព័ត៌មានមានជាច្រើនចូលគ្នា បង្ហាញនូវហេតុនិងផល នាំឱ្យអាចយល់នូវរឿងរ៉ាវមួយ ឬកិច្ចការមួយបាន។ ឧទាហរណ៍ ព័ត៌មានពីគុណភាព (ដំណើរនៃកិច្ចការរដ្ឋបាល សេវា និងប្រព័ន្ធ) បូកជាមួយផលសម្រេចនៃឆ្នាំសិក្សាឆ្នាំនេះនិងឆ្នាំកន្លងមក ឬ ៣ ទៅ ៥ឆ្នាំ កន្លងទៅ។

ព័ត៌មានមានគឺត្រូវបានកសាងឡើងដោយការផ្តុំទិន្នន័យជាច្រើនចូលគ្នា ដែល អាចនាំឱ្យដឹងបាននូវរឿងរ៉ាវមួយ តែមិនអាចនាំឱ្យយល់រឿងរ៉ាវមួយបានឡើយ។ ឧទាហរណ៍ សិស្សចូលរៀន៤០% ឆ្នាំសិក្សា២០២១ កើនឡើង ៥% បើធៀបជាមួយនឹងឆ្នាំសិក្សា២០២០ ដែលមានតែ៣៥%។ ដូចនេះដើម្បីអាចកសាងចំណេះដឹងបាន លុះណាការអនុវត្តការងារត្រូវផលិត ចងក្រង និងប្រើប្រាស់នូវទិន្នន័យពិត មានបច្ចុប្បន្នភាព និងអាចជឿជាក់បាន។

## ស្តង់ដាសហគមន៍សាលារៀន

| ស្តង់ដា | សូចនាករ |
|---|---|
| ស្តង់ដាទី១៖ សាលារៀនដំណើរការសម្រាប់ផលសម្រេចការអប់រំនិងការសិក្សារបស់សិស្ស ( ទិន្នន័យយេនឌ័រនៅគ្រប់សូចនាករ ) | |
| ១ | ចំនួននិងភាគរយសិស្សចូលរៀន |
| ២ | ចំនួននិងភាគរយសិស្សបោះបង់ការសិក្សា |
| ៣ | ចំនួននិងភាគរយសិស្សឡើងថ្នាក់ |
| ៤ | ចំនួននិងភាគរយសិស្សមាននិទ្ទេសល្អនិងល្អប្រសើរមុខវិជ្ជាភាសាខ្មែរ |
| ៥ | ចំនួននិងភាគរយសិស្សមាននិទ្ទេសល្អនិងល្អប្រសើរមុខវិជ្ជាគណិតវិទ្យា |
| ៦ | ចំនួននិងភាគរយសិស្សមាននិទ្ទេសមធ្យមឡើងមុខវិជ្ជារូបវិទ្យា |
| ៧ | ចំនួននិងភាគរយសិស្សមាននិទ្ទេសមធ្យមឡើងមុខវិជ្ជាគីមីវិទ្យា |
| ៨ | ចំនួននិងភាគរយសិស្សមាននិទ្ទេសមធ្យមឡើងមុខវិជ្ជាជីវវិទ្យា |
| ៩ | ចំនួននិងភាគរយសិស្សមាននិទ្ទេសមធ្យមឡើងមុខវិជ្ជាប្រវត្តិវិទ្យា |
| ១០ | ចំនួននិងភាគរយសិស្សថ្នាក់ទី៧មានសមត្ថភាពអានតាមស្តង់ដា(១០០ទៅ១២០ពាក្យក្នុងមួយនាទី) |
| ១១ | ចំនួននិងភាគរយសិស្សថ្នាក់ទី៩មានសមត្ថភាពអានតាមស្តង់ដា (២០០ទៅ២៥០ពាក្យក្នុងមួយនាទី) |
| ១២ | ចំនួននិងភាគរយសិស្សប្រឡងជាប់មធ្យមសិក្សាបឋមភូមិ |
| ១៣ | ចំនួននិងភាគរយសិស្សប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ |
| ស្តង់ដាទី២៖ ថ្នាក់រៀនដំណើរការសម្រាប់ការបង្រៀន និងរៀននៃសិស្សម្នាក់ៗ | |
| ១ | ចំនួនថ្នាក់រៀនមានផែនការបង្រៀន៣ឆ្នាំតាមមុខវិជ្ជា |
| ២ | ចំនួនថ្នាក់រៀនមានផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជា |
| ៣ | ចំនួនមុខវិជ្ជាមានកាលវិភាគបង្រៀនលម្អិតតាមមេរៀន |
| ៤ | ចំនួនមុខវិជ្ជាមានប្លង់មេរៀនតាមគ្រប់មេរៀន |
| ៥ | ចំនួនថ្នាក់រៀនមានផែនការបង្រៀន៣ខែ |
| ៦ | ចំនួនថ្នាក់រៀនមានការប្រជុំពិនិត្យតាមដានការរៀនសូត្រទៀងទាត់ |

| | |
|---|---|
| ៧ | ចំនួននិងភាគរយសិស្សមាននិងអនុវត្តការតាមដានផែនការសិក្សារៀនសូត្រប្រចាំឆ្នាំសិក្សា |
| ៨ | ចំនួននិងភាគរយសិស្សរៀនសូត្របំណិនកសិកម្មនិងបច្ចេកទេសដើម្បីរកចំណូល |
| ៩ | ចំនួននិងភាគរយសិស្សបានធ្វើកិច្ចការគម្រោង |
| ១០ | ចំនួនដងប្រកួតប្រជែងការអានអក្សរ |
| ១១ | ចំនួនដងប្រកួតប្រជែងការធ្វើលំហាត់គណិតវិទ្យា |
| ១២ | ចំនួននិងភាគរយសិស្សអវត្តមានលើសដង |
| ១៣ | ចំនួនដងគ្រូអវត្តមានមិនមានគ្រូជំនួស |
| ១៤ | ចំនួនថ្ងៃសាលាបិទទ្វារមិនតាមប្រតិទិន ឈប់សម្រាកប្រចាំឆ្នាំរបស់រដ្ឋ |
| ១៥ | ចំនួននិងភាគរយ សិស្សទទួលរងចរិយាហិង្សាពីគ្រូថយចុះរហូតដល់គ្មាននៅឆ្នាំទី១ |
| ១៦ | ចំនួនសិស្សបានសន្សំប្រាក់និងឬសម្រេចចិត្តទៅរៀននៅឧត្តមសិក្សាតាមបំណងប្រាថ្នា |
| **ស្តង់ដាទី៣៖ ភាពជាម្ចាស់នៃសាលារៀនសហគមន៍** | |
| ១ | ចំនួននិងភាគរយគ្រួសារមានហិង្សា |
| ២ | ចំនួនសមាសភាពគណៈកម្មការគ្រប់គ្រងសាលារៀន (គ.គ.ស) ឬក្រុមប្រឹក្សាសាលារៀន(ក.ប.ស) |
| ៣ | ការប្រជុំប្រចាំត្រីមាស ឆមាស និងឆ្នាំដែលដឹកនាំដោយគ.គ.ស. ឬក.ប.ស |
| ៤ | ចំនួនគ្រូបង្រៀនបានទទួលការសម្រេចចិត្តពីគ.គ.ស.ឬក.ប.សលើការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ |
| ៥ | ចំនួននាយកនិងនាយករងបានទទួលការសម្រេចចិត្តពីគ.គ.ស.លើការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ |
| ៦ | ចំនួនសិស្សបោះបង់បានមករៀនវិញទៀងទាត់ |
| ៧ | បរិមាណចំណូលមូលនិធិបង់ចូលសាលារៀន |
| ៨ | ទិន្នន័យតេស្តវាយតម្លៃស្តង់ដាលើសមត្ថភាពសិស្សត្រូវបានអនុម័តនិងបិទផ្សាយ |
| ៩ | ផែនការសកម្មភាពអនុវត្តសូចនាករគន្លឹះបានអនុម័តដោយគ.គ.ស.ឬក.ប.ស |
| ១០ | ផែនការកែលម្អសាលារៀននិងថវិកាប្រចាំឆ្នាំបានអនុម័តដោយគ.គ.ស.ឬក.ប.ស |
| ១១ | របាយការណ៍វាយតម្លៃស្តង់ដាសាលារៀនត្រូវបានអនុម័តដោយគ.គ.ស.ឬក.ប.ស |
| ១២ | របាយការណ៍ឆ្នាំត្រូវបានអនុម័តដោយគ.គ.ស.ឬក.ប.ស |
| ១៣ | ទិន្នន័យបិទផ្សាយជាសាធារណៈត្រូវបានអនុម័តដោយគ.ក.ប.សឬក.ប.ស និងបិទផ្សាយ |

| | |
|---|---|
| ១៤ | ចំនួនបន្ទប់អនាម័យបានសាងសង់និងជួសជុលតាមផែនការ |
| ១៥ | មានកម្មវិធីបំណិនរកចំណូលតាមស្តង់ដា |
| ១៦ | មានកម្មវិធីធានាគាំពារប់រងសង្គមនិងអភិវឌ្ឍសមត្ថភាពមន្ត្រី |

| **ស្តង់ដាទី៤៖ ដំណើរប្រតិបត្តិការសាលារៀន** | |
|---|---|
| ១ | ផែនការសកម្មភាពអនុវត្តសូចនាករគន្លឹះរយៈពេលមធ្យមបានរៀបចំតាមការណែនាំ |
| ២ | ផលសម្រេចរយៈពេល៣ឆ្នាំ និងផែនការបង្រៀនរយៈពេល៣ឆ្នាំបានរៀបចំតាមការណែនាំ |
| ៣ | ផែនការកែលម្អសាលារៀនបានរៀបចំតាមការណែនាំ |
| ៤ | ការធ្វើតេស្តស្តង់ដាប្រចាំខែ និងត្រីមាសបានរៀបចំទៀងទាត់ |
| ៥ | លទ្ធផលតេស្តស្តង់ដាប្រចាំខែត្រូវបានយកប្រើប្រាស់ជួយដល់ការសិក្សារៀនសូត្ររបស់សិស្សរៀនយឺត |
| ៦ | លទ្ធផលតេស្តចុងត្រីមាសបានយកប្រើប្រាស់ក្នុងការរៀបចំផែនការបង្រៀន៣ខែតាមថ្នាក់រៀន |
| ៧ | ការប្រជុំប្រចាំខែ ត្រីមាស និងឆមាសបានប្រជុំតាមការណែនាំ |
| ៨ | ចំនួនដងអធិការកិច្ចផ្ទៃក្នុង និងការប្រជុំបច្ចេកទេសបានអនុវត្តតាមផែនការ |
| ៩ | ចំនួនគ្រូបង្រៀនបានចូលរៀនវគ្គអភិវឌ្ឍសមត្ថភាពជាប្រចាំ |
| ១០ | ចំនួនគ្រូបង្រៀនបានចូលរួមអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀន |
| ១១ | ចំនួននាយកសាលានិងនាយករងបានចូលរួមអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់នាយកសាលា |
| ១២ | ស្វ័យវាយតម្លៃសាលារៀននៅចុងឆ្នាំសិក្សាបានអនុវត្ត និងរបាយការណ៍ហិរញ្ញវត្ថុបានផលិតតាមការណែនាំ |
| ១៣ | ចំនួនដងប្រកួតប្រជែងអំណានភាសាខ្មែរ និងលំហាត់គណិតវិទ្យាជាមួយសាលាផ្សេងបានរៀបចំតាមការគ្រោង |
| ១៤ | ទិន្នន័យជឿជាក់បានត្រូវបានផលិត ចងក្រង ប្រើប្រាស់ និងបិទផ្សាយសាធារណៈតាមការណែនាំ |
| ១៥ | កម្មវិធីអប់រំមាតាបិតា និងគ្រូបង្រៀនទប់ស្កាត់អំពើហិង្សានៅផ្ទះនិងសាលារៀនបានរៀបចំតាមការណែនាំ |
| ១៦ | ការពិនិត្យស្វែងរកសិស្សខ្សោយគំហើញ និងស្តាប់បានអនុវត្តទៀងទាត់រៀងរាល់ដើមឆ្នាំសិក្សា |

| ស្តង់ដាទី៥៖ គណនេយ្យភាពថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ | |
|---|---|
| ១ | ចំនួនដងនាយកសាលានិងនាយករងបានទទួលការហ្វឹកហាត់អនុវត្តការគ្រប់គ្រងតាមសាលារៀន |
| ២ | ចំនួនដងគ្រូបង្រៀនបានទទួលការហ្វឹកហាត់ការបង្រៀនចម្រុះមុខវិជ្ជាតាមផែនការ |
| ៣ | ចំនួនដងទស្សនៈកិច្ចផ្តល់ការគាំទ្រពីក្រុមការងារតំបន់បានអនុវត្តតាមផែនការ |
| ៤ | ចំនួនដងទស្សនៈកិច្ចផ្តល់ការគាំទ្រពីមន្ទីរអប់រំ យុវជន និងកីឡា បានអនុវត្តតាមផែនការ |
| ៥ | ចំនួនដងទស្សនៈកិច្ចផ្តល់ការគាំទ្រពីការិយាល័យអប់រំ យុវជន និងកីឡា បានអនុវត្តតាមផែនការ |
| ៦ | ការបង្រៀនបំណិនកសិកម្ម និងបច្ចេកទេសបានអនុវត្តតាមផែនការ |
| ៧ | ចំនួនគ្រូបង្រៀនខ្វះតាមមុខវិជ្ជាថយចុះតាមផែនការ |
| ៨ | ចំនួននាយកសាលានិងនាយករងសាលា មានជាផ្លូវការតាមបទដ្ឋាន |
| ៩ | កាតរបាយការណ៍សាលារៀនបានផលិត និងបិទផ្សាយ |

### ច. ការវាយតម្លៃស្តង់ដាសាលាមធ្យមសិក្សា

ការផ្តល់ពិន្ទុនិងការកំណត់ស្តង់ដាអប្បបរមា៖

សាលារៀនមួយអាចចាត់ទុកថាបំពេញបាននូវស្តង់ដាអប្បបរមានៃស្តង់ដាសហគមន៍សាលារៀន លុះណាសាលារៀនមួយមានពិន្ទុសរុបយ៉ាងតិច ២១០ ពិន្ទុ ហើយស្តង់ដានីមួយៗត្រូវបំពេញបាននូវពិន្ទុអប្បបរមារបស់ខ្លួនដូចតារាងខាងក្រោម។ បើទោះជាសាលាមានពិន្ទុសរុប ២១០ ឬលើសក៏ដោយ តែបើស្តង់ដាណាមួយមិនមានពិន្ទុអប្បបរមាទេ នោះមិនអាចចាត់ទុកថាសាលារៀនមាន ស្តង់ដាអប្បបរមានោះទេ។

| | ស្តង់ដាទី១ | ស្តង់ដាទី២ | ស្តង់ដាទី៣ | ស្តង់ដាទី៤ | ស្តង់ដាទី៥ | សរុបពិន្ទុ |
|---|---|---|---|---|---|---|
| ពិន្ទុអប្បបរមា | ៣៩ | ៤៨ | ៤៨ | ៤៨ | ២៧ | ២១០ |

| លេខ | ស្តង់ដានិងសូចនាករ | ពិន្ទុ១ | ពិន្ទុ២ | ពិន្ទុ៣ | ពិន្ទុ៤ |
|---|---|---|---|---|---|
| **ស្តងដាទី១៖ សាលារៀនដំណើរការសម្រាប់ផលសម្រេចការអប់រំនិងការសិក្សារបស់សិស្ស ( ទិន្នន័យយេនឌ័រនៅគ្រប់សូចនាករ )** | | | | | |
| ១ | ចំនួននិងភាគរយសិស្សចូលរៀន | >៩០% | >៩៥% | >៩៧% | >៩៩% |
| ២ | ចំនួននិងភាគរយសិស្សបោះបង់ការសិក្សា | >៣% | ៣% | ១-២% | <១% |
| ៣ | ចំនួននិងភាគរយសិស្សឡើងថ្នាក់ | <៩៥% | <៩៦% | =<៩៨% | >៩៨% |
| ៤ | ចំនួននិងភាគរយសិស្សមាននិទ្ទេសល្អនិងល្អប្រសើរមុខវិជ្ជាភាសាខ្មែរ | =<១៩% | ២០%-២៩% | ៣០%-៣៩% | ៤០%-៥០% (៣០=២០) |
| ៥ | ចំនួននិងភាគរយសិស្សមាននិទ្ទេសល្អ និងល្អប្រសើរមុខវិជ្ជាគណិតវិទ្យា | =<១៩% | ២០%-២៩% | ៣០%-៣៩% | ៤០%-៥០% (៣០=២០) |
| ៦ | ចំនួននិងភាគរយសិស្សមាននិទ្ទេសមធ្យមឡើងមុខវិជ្ជារូបវិទ្យា (A, B, C) | <១៩% | ២០%-៣៩% | ៤០%-៥៩% | ៦០%-៨០% |
| ៧ | ចំនួននិងភាគរយសិស្សមាននិទ្ទេសមធ្យមឡើងមុខវិជ្ជាគីមីវិទ្យា (A, B, C) | <១៩% | ២០%-៣៩% | ៤០%-៥៩% | ៦០%-៨០% |
| ៨ | ចំនួននិងភាគរយសិស្សមាននិទ្ទេសមធ្យមឡើងមុខវិជ្ជាជីវវិទ្យា(A, B, C) | <១៩% | ២០%-៣៩% | ៤០%-៥៩% | ៦០%-៨០% |
| ៩ | ចំនួននិងភាគរយសិស្សមាននិទ្ទេសមធ្យមឡើងមុខវិជ្ជាផែនដី-បរិស្ថានវិទ្យា (A, B, C) | <១៩% | ២០%-៣៩% | ៤០%-៥៩% | ៦០%-៨០% |
| ១០ | ចំនួននិងភាគរយសិស្សថ្នាក់ទី៧មានសមត្ថភាពអានតាមស្តង់ដា (១០០ទៅ១២០ពាក្យក្នុងមួយនាទី) | >៤៥% | >៦០% | >៧៥% | >៨០% |
| ១១ | ចំនួននិងភាគរយសិស្សថ្នាក់ទី៩មានសមត្ថភាពអានតាមស្តង់ដា | >៤៥% | >៦០% | >៧៥% | >៨០% |

| | | | | | |
|---|---|---|---|---|---|
| | (២០០ ទៅ ២៥០ពាក្យក្នុងមួយនាទី) | | | | |
| ១២ | ចំនួននិងភាគរយសិស្សប្រឡងជាប់ការប្រឡងថ្នាក់ជាតិទី៩ | >៦០% | >៧០% | >៨០% | >៩០% |
| ១៣ | ចំនួននិងភាគរយសិស្សប្រឡងជាប់ការប្រឡងថ្នាក់ជាតិទី១២ | >៦០% | >៧០% | >៨០% | >៩០% |
| **សរុបពិន្ទុស្តង់ដាទី១** | | ១៣ | ២៦ | ៣៩ | ៤២ |

| **លេខ** | **ស្តង់ដានិងសូចនាករ** | **ពិន្ទុ១** | **ពិន្ទុ២** | **ពិន្ទុ៣** | **ពិន្ទុ៤** |
|---|---|---|---|---|---|
| **ស្តង់ដាទី២៖ ថ្នាក់រៀនដំណើរការសម្រាប់ការបង្រៀន និងរៀននៃសិស្សម្នាក់ៗ** | | | | | |
| ១ | ចំនួនថ្នាក់រៀនមានផែនការបង្រៀន៣ឆ្នាំតាមមុខវិជ្ជា | <៨៥% | <៩០% | <៩៥% | =/<១០០% |
| ២ | ចំនួនថ្នាក់រៀនមានផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជា | <៨៥% | <៩០% | <៩៥% | =/<១០០% |
| ៣ | ចំនួនមុខវិជ្ជាមានកាលវិភាគបង្រៀនលម្អិតតាមមេរៀន | =/<៦ | ៧-៨ | ៩-១០ | ១១-១២ |
| ៤ | ចំនួនមុខវិជ្ជាថ្នាក់ទី៧ដល់ទី១២មានប្លង់មេរៀនតាមគ្រប់មេរៀន | ៦ | ៧-៨ | ៩-១០ | ១១-១២ |
| ៥ | ចំនួនថ្នាក់រៀនមានផែនការបង្រៀន៣ខែ | >៨៥% | >៩០% | >៩៥% | =/<១០០% |
| ៦ | ចំនួនថ្នាក់រៀនមានការប្រជុំពិនិត្យតាមដានការរៀនសូត្រទៀងទាត់ | >៨៥% | >៩០% | >៩៥% | ១០០% |
| ៧ | ចំនួននិងភាគរយសិស្សមាននិងអនុវត្តការតាមដានផែនការសិក្សារៀនសូត្រប្រចាំឆ្នាំសិក្សា | >៨៥% | >៩០% | >៩៥% | ១០០% |
| ៨ | ចំនួននិងភាគរយសិស្សរៀនសូត្របំណិនកសិកម្មនិងបច្ចេកទេសដើម្បីរកចំណូល | >៥០% | >៦០% | >៧០% | =/>៨០% |
| ៩ | ចំនួនសិស្សបានធ្វើកិច្ចការគម្រោងទាំងអស់ | <៨៥% | <៩០% | <៩៥% | =/<១០០% |
| ១០ | ចំនួនដងប្រកួតប្រជែងការអានអក្សរ | =/<៦ | ៦-៧ | ៨-៩ | >១០ |

| | | | | | |
|---|---|---|---|---|---|
| ១១ | ចំនួនដងប្រកួតប្រជែងការធ្វើលំហាត់គណិតវិទ្យា | =/<៦ | ៦-៧ | ៨-៩ | >១០ |
| ១២ | ចំនួននិងភាគរយសិស្សអវត្តមានលើស៤ដង | ២% | ១.៥% | ១.0% | 0.៥% |
| ១៣ | ចំនួនដងគ្រូអវត្តមានមិនមានគ្រូជំនួស | <២0 | <១៥ | <១0 | <៥ |
| ១៤ | ចំនួនថ្ងៃសាលាបិទទ្វារមិនតាមការឈប់សម្រាកប្រចាំឆ្នាំរបស់រដ្ឋ | ៥ | ៣-៤ | ២ | ១ |
| ១៥ | ចំនួននិងភាគរយសិស្សទទួលរងចរិយាហិង្សាពីគ្រូថយចុះរហូតដល់គ្មាននៅឆ្នាំទី១ | ១.៥% | ១.0% | 0.៥% | 0% |
| ១៦ | ចំនួននិងភាគរយសិស្សបានសន្យាប្រាក់និងឬសម្រេចចិត្តទៅរៀននៅឧត្តមសិក្សាតាមបំណងប្រាថ្នា | >៣0% | >៤0% | >៥0% | >៦0% |
| **សរុបពិន្ទុស្តង់ដាទី២** | | ១៦ | ៣២ | ៤៨ | ៦៤ |

| លេខ | ស្តង់ដានិងសូចនាករ | ពិន្ទុ១ | ពិន្ទុ២ | ពិន្ទុ៣ | ពិន្ទុ៤ |
|---|---|---|---|---|---|
| **ស្តង់ដាទី៣៖ ភាពជាម្ចាស់នៃសាលារៀនសហគមន៍** | | | | | |
| **១** | ចំនួននិងភាគរយគ្រួសារមានហិង្សា | ១.៥% | ១.0% | 0.៥% | 0% |
| **២** | ចំនួនសមាសភាពគណៈកម្មការគ្រប់គ្រងសាលារៀន (គ.គ.ស.) ឬក្រុមប្រឹក្សាសាលារៀន (ក.ប.ស) | <៧ | ៧-៨ | ៩-១0 | >១0 |
| **៣** | ការប្រជុំប្រចាំត្រីមាស ឆមាស និងឆ្នាំដែលដឹកនាំដោយគ.គ.ស. ឬក.ប.ស | ខែទៀងទាត់ | ត្រីមាសទៀងទាត់ | ឆ្នាំទៀងទាត់ | ទាំងអស់ |
| **៤** | ចំនួនគ្រូបង្រៀនបានទទួលការសម្រេចចិត្តពីគ.គ.ស .ឬក.ប.ស លើការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ | >៨0% | >៨៥% | >៩0% | =>៩0% |
| **៥** | ចំនួននាយកនិងនាយករងបានទទួលការសម្រេចចិត្តពីគ.គ.ស. ឬក.ប.ស លើការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ | 0 | ១ | ២-៣ | ទាំងអស់ |
| ៦ | ចំនួនសិស្សត្រៀមនឹងបោះបង់ឬបោះបង់បានមករៀនវិញទៀងទាត់ | <៩0% | ៩0%-៩៤% | ៩៥%-៩៩% | ទាំងអស់ |

| | | | | | |
|---|---|---|---|---|---|
| ៧ | បរិមាណចំណូលមូលនិធិបង់ចូលសាលារៀន | ២០,០០០ ដុល្លារ | កើន២ ទៅ៣ដង | កើន៤ ដល់៦ ដង | កើន លើស ១០ដង |
| ៨ | ទិន្នន័យតេស្តវាយតម្លៃស្តង់ដាលើសមត្ថភាពសិស្សត្រូវបានអនុម័តនិងបិទផ្សាយ | តេស្តខែ | បូកត្រីមាស | បូក ឆមាស | ទាំង អស់ |
| ៩ | ផែនការសកម្មភាពអនុវត្តសូចនាករគន្លឹះបានអនុម័តដោយគ.គ.ស. ឬក.ប.ស | ផលិត | អនុម័ត ឆ្នាំទី១ | អនុម័ត ឆ្នាំទី២ | អនុម័ត ឆ្នាំទី៣ |
| ១០ | ផែនការកែលម្អសាលារៀននិងថវិកាប្រចាំឆ្នាំបានអនុម័តដោយគ.គ.ស. ឬក.ប.ស | ផលិត | អនុម័ត ឆ្នាំទី១ | អនុម័ត ឆ្នាំទី២ | អនុម័ត ឆ្នាំទី៣ |
| ១១ | របាយការណ៍វាយតម្លៃស្តង់ដាសាលារៀនត្រូវបានអនុម័តដោយគ.គ.ស. ឬក.ប.ស | ផលិត | អនុម័ត ឆ្នាំទី១ | អនុម័ត ឆ្នាំទី២ | អនុម័ត ឆ្នាំទី៣ |
| ១២ | របាយការណ៍ប្រចាំឆ្នាំត្រូវបានអនុម័តដោយគ.គ.ស. ឬក.ប.ស | ផលិត | អនុម័ត ឆ្នាំទី១ | អនុម័ត ឆ្នាំទី២ | អនុម័ត ឆ្នាំទី៣ |
| ១៣ | ទិន្នន័យបិទផ្សាយជាសាធារណៈត្រូវបានអនុម័តដោយគ.គ.សឬក.ប.ស និងបិទផ្សាយ | ផលិត | អនុវត្តឆ្នាំ ទី១ | អនុវត្តឆ្នាំ ទី២ | អនុវត្ត ឆ្នាំទី៣ |
| ១៤ | ចំនួនបន្ទប់អនាម័យបានសាងសង់និងជួសជុលតាមផែនការ | គ្រោង | តាម ផែនការ ឆ្នាំទី១ | តាម ផែនការ ឆ្នាំទី២ | តាម ផែនការ ឆ្នាំទី៣ |
| ១៥ | មានកម្មវិធីបំណិនរកចំណូលតាមស្តង់ដា | គ្រោង | សម្រេច តាម ផែនការ ឆ្នាំទី១ | សម្រេច តាម ផែនការ ឆ្នាំទី២ | សម្រេច តាម ផែនការ ឆ្នាំទី៣ |
| ១៦ | មានកម្មវិធីធានារ៉ាប់រងសង្គមនិងអភិវឌ្ឍសមត្ថភាព | | គ្រោង | សម្រេច តាម ផែនការ ឆ្នាំទី១ | សម្រេច តាម ផែនការ ឆ្នាំទី២ |
| **សរុបពិន្ទុស្តង់ដាទី៣** | | ១៥ | ៣២ | ៤៨ | ៦៤ |

| លេខ | ស្តង់ដានិងសូចនាករ | ពិន្ទុ១ | ពិន្ទុ២ | ពិន្ទុ៣ | ពិន្ទុ៤ |
|---|---|---|---|---|---|
| **ស្តង់ដាទី៤៖ ដំណើរប្រតិបត្តិការសាលារៀន** | | | | | |
| ១ | ផែនការសកម្មភាពអនុវត្តសូចនាករគន្លឹះរយៈពេលមធ្យមបានរៀបចំតាមការណែនាំ | រៀបចំឆ្នាំទី១ | រៀបចំឆ្នាំទី២ | រៀបចំឆ្នាំទី៣ | រៀបចំឆ្នាំទី៤ |
| ២ | ផលសម្រេចរយៈពេល៣ឆ្នាំ និងផែនការបង្រៀនរយៈពេល៣ឆ្នាំបានរៀបចំតាមការណែនាំ | រៀបចំឆ្នាំទី១ | រៀបចំឆ្នាំទី២ | រៀបចំឆ្នាំទី៣ | រៀបចំឆ្នាំទី៤ |
| ៣ | ផែនការកែលម្អសាលារៀនបានរៀបចំតាមការណែនាំ | រៀបចំឆ្នាំទី១ | រៀបចំឆ្នាំទី២ | រៀបចំឆ្នាំទី៣ | រៀបចំឆ្នាំទី៤ |
| ៤ | ការធ្វើតេស្តស្តង់ដាប្រចាំខែ និងត្រីមាសបានរៀបចំទៀងទាត់ | តេស្តខែ | បូកត្រីមាស | បូកត្រីមាស | បូកត្រីមាស |
| ៥ | លទ្ធផលតេស្តស្តង់ដាប្រចាំខែត្រូវបានយកប្រើប្រាស់ជួយដល់ការសិក្សារៀនសូត្ររបស់សិស្សរៀនយឺត | ទៀងទាត់ឆ្នាំទី១ | ទៀងទាត់ឆ្នាំទី២ | ទៀងទាត់ឆ្នាំទី៣ | ទៀងទាត់ឆ្នាំទី៤ |
| ៦ | លទ្ធផលតេស្តចុងត្រីមាសបានយកប្រើប្រាស់ក្នុងការរៀបចំផែនការបង្រៀន៣ខែតាមថ្នាក់រៀន | ទៀងទាត់ឆ្នាំទី១ | ទៀងទាត់ឆ្នាំទី២ | ទៀងទាត់ឆ្នាំទី៣ | ទៀងទាត់ឆ្នាំទី៤ |
| ៧ | ការប្រជុំប្រចាំខែ ត្រីមាស និងឆមាសបានប្រជុំតាមការណែនាំ | ប្រចាំខែ | បូកត្រីមាស | បូកឆមាស | បូកឆមាស |
| ៨ | ចំនួនដងអធិការកិច្ចផ្ទៃក្នុង និងការប្រជុំបច្ចេកទេសបានអនុវត្តតាមផែនការ | ៧-៧ | ៨-៨ | ៩-៩ | ១០-១០ |
| ៩ | ចំនួនគ្រូបង្រៀនបានចូលរៀនវគ្គអភិវឌ្ឍសមត្ថភាពជាប្រចាំ | គ្រោង | តាមគ្រោងឆ្នាំទី១ | តាមគ្រោងឆ្នាំទី២ | តាមគ្រោងឆ្នាំទី៣ |
| ១០ | ចំនួនគ្រូបង្រៀនបានចូលរួមអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀន | >៨០% | >៨៥% | >៩០% | =>៩០% |
| ១១ | ចំនួននាយកសាលានិងនាយករងបានចូលរួមអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់នាយកសាលា | ០ | ១ | ២-៣ | ទាំងអស់ |

| | | | | | |
|---|---|---|---|---|---|
| ១២ | ស្វ័យវាយតម្លៃសាលារៀននៅចុងឆ្នាំសិក្សាបានអនុវត្ត និងរបាយការណ៍ហិរញ្ញវត្ថុបានផលិតតាមការណែនាំ | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ | អនុវត្តឆ្នាំទី៤ |
| ១៣ | ចំនួនដងប្រកួតប្រជែងអំណានភាសាខ្មែរ និងលំហាត់គណិតវិទ្យាជាមួយសាលាផ្សេងបានរៀបចំតាមការគ្រោង | គ្រោង | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ |
| ១៤ | ទិន្នន័យជឿជាក់បានត្រូវបានផលិត ចងក្រង ប្រើប្រាស់ និងបិទផ្សាយសាធារណៈតាមការណែនាំ | ចងក្រងទិន្នន័យ | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ |
| ១៥ | កម្មវិធីអប់រំមាតាបិតា និងគ្រូបង្រៀនទប់អំពើហិង្សានៅផ្ទះនិងសាលារៀនបានរៀបចំតាមការណែនាំ | ប្រមូលទិន្នន័យ | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ |
| ១៦ | ការពិនិត្យស្វែងរកសិស្សខ្សោយគំហើញ និងស្តាប់បានអនុវត្តទៀងទាត់រាល់ដើមឆ្នាំសិក្សា | គ្រោង | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ |
| **សរុបពិន្ទុស្តង់ដាទី៤** | | ១៦ | ៣២ | ៤៨ | ៦៤ |

| លេខ | ស្តង់ដានិងសូចនាករ | ពិន្ទុ១ | ពិន្ទុ២ | ពិន្ទុ៣ | ពិន្ទុ៤ |
|---|---|---|---|---|---|
| **ស្តង់ដាទី៥៖ គណនេយ្យភាពថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ** | | | | | |
| **១** | ចំនួនដងនាយកសាលានិងនាយកសាលារងបានទទួលការហ្វឹកហាត់អនុវត្តការគ្រប់គ្រងតាមសាលារៀន | ១-២ | ៣-៤ | ៥-៦ | ៧-៨ |
| **២** | ចំនួនដងគ្រូបង្រៀនបានទទួលការហ្វឹកហាត់ការបង្រៀនចម្រុះមុខវិជ្ជាតាមផែនការ | គ្រោង | តាមគ្រោងឆ្នាំទី១ | តាមគ្រោងឆ្នាំទី២ | តាមគ្រោងឆ្នាំទី៣ |
| **៣** | ចំនួនដងទស្សនៈកិច្ចផ្តល់ការគាំទ្រពីក្រុមការងារតំបន់បានអនុវត្តតាមផែនការ | ១-២ | ៣-៤ | ៥-៦ | ៧-៨ |
| **៤** | ចំនួនដងទស្សនៈកិច្ចផ្តល់ការគាំទ្រពីមន្ទីរ អ.យ.ក. បានអនុវត្តតាមផែនការ | ១-២ | ៣-៤ | ៥-៦ | ៧-៨ |

| | | | | | |
|---|---|---|---|---|---|
| ៥ | ចំនួនដងទស្សនៈកិច្ចផ្តល់ការគាំទ្រពីការិយាល័យ អ.យ.ក. នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានអនុវត្តតាមផែនការ | ១-២ | ៣-៤ | ៥-៦ | ៧-៨ |
| ៦ | ការបង្រៀនបំណិនកសិកម្មនិងបច្ចេកទេសបានអនុវត្ត | គ្រោង | តាមគ្រោង ឆ្នាំទី១ | តាមគ្រោង ឆ្នាំទី២ | តាមគ្រោង ឆ្នាំទី៣ |
| ៧ | ចំនួនគ្រូបង្រៀនខ្វះតាមមុខវិជ្ជាឯកទេសថយចុះតាមផែនការ | ≥១០ | ៦-៩ | ២-៥ | ០ |
| ៨ | ចំនួននាយក និងនាយករងបានតែងតាំងត្រឹមត្រូវតាមនិយាម | ខ្វះ៣ | ខ្វះ២ | ខ្វះ១ | ត្រឹមត្រូវតាមនិយាម |
| ៩ | កាតរបាយការណ៍សាលារៀនបានផលិតនិងបិទផ្សាយជាសាធារណៈ | គ្រោង | ផលិតនិងបិទផ្សាយ ឆ្នាំទី១ | ផលិតនិងបិទផ្សាយឆ្នាំទី២ | ផលិតនិងបិទផ្សាយឆ្នាំទី៣ |
| | ពិន្ទុសរុបស្តង់ដាទី៥ | ៩ | ១៨ | ២៧ | ៣៦ |
| | *ពិន្ទុសរុបស្តង់ដាសហគមន៍សាលារៀន* | *៧០* | *១៤០* | *២១០* | *២៨០* |

ឆ. ការផ្តល់ថាមពលធ្វើការងារ



១. ការភ្ញាក់ដឹង Awareness

**ប្រុងប្រយ័ត្ន** Attention **ឬមួយ មិនរវល់តែម្តងឬខ្ជិលតែម្តង៖** ធ្វើកិច្ចការនីមួយៗប្រកបដោយវិជ្ជាជីវៈ ធ្វើកិច្ចការឱ្យបានចប់ចុងចប់ដើម និងផ្តោតសម្រេចវត្ថុបំណងនៃកិច្ចការ។ ធ្វើកិច្ចការដោយផ្អែកតែលើទ្រឹស្តី និងឃ្លាតចាកពីការពិត គឺ មានន័យថាធ្វើកិច្ចការស្មើរៗគ្មានការប្រុងប្រយ័ត្ន។

**ភ្ញាក់ដឹង** Self-awareness **ឬមួយ ដេកលក់ជាមួយអតីតកាល៖** សិក្សាពីអ្វីកើតឡើងនៅក្នុងសាកលលោក ទាក់ទងនឹងតួនាទីរបស់ខ្លួន ហើយយកចំណេះដឹងនេះមកឆ្លុះបញ្ចាំងថាខ្លួនកំពុងស្ថិតនៅទីណា ហើយរាល់ពេលនិយាយ ឬធ្វើកិច្ចការគប្បីផ្តោតលើអ្វីដែលខ្លួនត្រូវធ្វើដើម្បីបំពេញតួនាទីដែលខ្លួនកំពុងទទួល ជាជាងចំណាយពេលគិត និងត្អូញត្អែរពីអ្នកដទៃ។

**ចិត្តមេត្តា** Meta-awareness **ឬមួយ ពេលណាក៏ហិង្សា៖** បណ្តុះចិត្តអនុគ្រោះនិងអាណិតអាសូរដល់គ្រប់មនុស្ស ដោយការជឿជាក់ថាមនុស្សមិនមែនជាបញ្ហាទេ តែចរិយារបស់គេទេដែលម្តងម្កាលជាបញ្ហា និងស្វែងយល់ថារាល់ពេលបង្កើតកំហឹងនៅក្នុងខ្លួន ជានិច្ចកាលជាការធ្វើបាបខ្លួនឯង។ ការយល់ដឹងពីមូលហេតុដែលនាំឱ្យមនុស្សមានចរិយាជាបញ្ហានឹងនាំឱ្យអ្នកអាចបណ្តុះចិត្តអនុគ្រោះនិងអាណិតអាសូរ ហើយឈានដល់ការជួយមនុស្សជាជាងការបន្ទោសមនុស្ស។

**ផ្តោត** □□□□□ **ឬមួយ អញចេះជាងគេនិយាយរហូត និយាយតែទ្រឹស្តី៖** ជានិច្ចកាលសួរខ្លួនអ្នកថា «ខ្ញុំអាចធ្វើអ្វីបាននៅថ្ងៃនេះ ដែលនាំឱ្យមានប្រយោជន៍ដល់សិស្សនិងមន្ត្រីខ្ញុំ?» គប្បីចៀសវាងការត្អូញត្អែរពីអតីតកាល តែជំនួសវិញដោយការគិតពីការរស់នៅថ្ងៃនេះជាមួយអនាគតកាល។ ប្រើពេលដែលអ្នកមានធ្វើកិច្ចការថ្ងៃនេះជាមួយតួនាទីរបស់អ្នកក្នុងបរិបទសាកលលោក។

២. ផ្សារភ្ជាប់សង្គម Connection

**ចិត្តល្អ** Kindness **ឬមួយ ក្រឡិចក្រឡុច៖** បង្ហាញដោយអំពើល្អជួយមនុស្ស អំពើអាចជាសម្តី ឬសកម្មភាព។ បើអ្នកជួយមនុស្សបានកាន់តែច្រើន នោះអ្នកនឹងមានមនុស្សច្រើននិយាយជាមួយ ហើយអ្នកនឹងទទួលបាននូវព័ត៌មានពិតជាច្រើនពីមនុស្សទាំងនេះ។ ភាពឯកោនឹងបាត់បង់ អ្នកនឹងរីករាយហើយមានអាយុវែង។

**អត់ឱន** Empathy **ឬមួយ ដេរប្រមាថ៖** អ្នកមិនគប្បីគិតថានិយាយមួយដង មនុស្សគ្រប់គ្នាយល់ហើយធ្វើកិច្ចការបានត្រឹមត្រូវនោះទេ។ អ្នកគប្បីជួយមនុស្សឱ្យគេត្រៀមរួចស្រេចមុនពេលធ្វើកិច្ចការមួយ។ បើមានចន្លោះខ្វះខាត ផ្តល់ការអត់ឱន ហើយបន្តជួយគេរហូតគេធ្វើកិច្ចការបានប្រសើរ។ អ្នកគប្បីជឿថា ការមិនអត់ឱនដល់មនុស្សនឹងបានមកវិញតែការឈឺចាប់ប៉ុណ្ណោះ។

**រក្សាសភាពវិជ្ជមាន** Maintaining a positive outlook **ឬមួយ ប្រើអំណាចខុសបែបបទ៖** នេះជាការគ្រប់គ្រងចិត្តរបស់អ្នក ហើយអ្នកអាចរក្សាបាននូវសភាពវិជ្ជមានបាន លុះណាអ្នកហាត់អនុវត្តនូវរបៀបដែលអ្នកទទួលព័ត៌មាន។ និយាយរួម បើការទទួលព័ត៌មានក្នុងបរិបទអតីតកាលនោះជាការទទួលព័ត៌មានបែបអវិជ្ជមាន តើត្រូវធ្វើដូចម្ដេច ។ តែបើការទទួលព័ត៌មានក្នុងបរិបទអនាគតកាលនោះជាការទទួលព័ត៌មានបែបវិជ្ជមាន តើត្រូវធ្វើយ៉ាងណា។ ឧទាហរណ៍៖ ១) មន្ត្រី«ក» មិនទទួលខុសត្រូវ ធ្វើកិច្ចការមិនបានលទ្ធផល (អតីតកាល) ឬ ២) មន្ត្រី «ក» នេះ ត្រូវការការជួយបំប៉ននិងការដឹកដៃធ្វើកិច្ចការមួយនេះ សង្ឃឹមថាគាត់នឹងមានទឹកចិត្តធ្វើការនៅពេលគាត់ឃើញថាគាត់អាចសម្រេចបាននូវលទ្ធផលពីកិច្ចការមួយនេះ (អនាគត)។ ជាការល្អដែលអ្នកត្រូវរក្សាភាពវិជ្ជមាននេះរហូត ហើយមិនគប្បីបង្ហាញនូវចរិយាអវិជ្ជមានបើទោះបីជាម្ដងក៏ដោយ។ បើមានចរិយាអវិជ្ជមានម្ដង អាចនាំឱ្យមន្ត្រីមានការងឿងឆ្ងល់ថា តើអ្នកប្រាកដជាមនុស្សបែបណា។

៣. យល់ពីខ្លួនឯង Insight

**យល់ពីខ្លួន** Self-knowledge **ឬមួយ បន្តចរិយាអសីលធម៌៖** ជាការកសាងចំណេះដឹងស្វែងយល់ពីខ្លួនឯងរហូត។ ចំណេះដឹងនេះវាទាក់ទងនឹងគ្រប់ចរិយាដែលបានធ្វើនិងបម្រុងនឹងធ្វើ។ បើចរិយាបានធ្វើនាំឱ្យមានអារម្មណ៍មិនស្រួល ត្រូវឆ្លុះបញ្ចាំងឡើងវិញថាត្រូវប្ដូរយ៉ាងណាវិញនៅពេលធ្វើលើកក្រោយ។ សម្រាប់ចរិយាបម្រុងនឹងធ្វើ ត្រូវគិតច្បាស់ថាវាច្បាស់ជានឹងទទួលបានមកវិញនូវអ្វីដែលអ្នកចង់បានឬទេ តែបើចរិយាបម្រុងនឹងធ្វើនោះវានាំមកនូវអ្វីដែលអវិជ្ជមាន នោះអ្នកពុំគប្បីធ្វើវាឡើយ។

**ថយចុះភាពរឹងកំព្រឹស** Decreased stickiness **ឬមួយ ជាប់សោរខួរក្បាលរហូត៖** អ្នកគប្បីជឿថា អ្នកមិនមែនជាម៉ាស៊ីនដោះស្រាយបញ្ហាទេ បើអ្នកគិតថាអ្នកគិតត្រូវរហូត នោះវានាំឱ្យទំនាក់ទំនងរបស់អ្នកស្ថិតនៅលើតែចម្លើយតែមួយរបស់អ្នកដែលត្រូវ។ របៀបនេះអ្នកនឹងក្លាយទៅជាមនុស្សរឹងកំព្រឹស ហើយអ្នកនឹងជួបការលំបាកសម្រាប់ការដឹកនាំសម្រាប់ការផ្លាស់ប្ដូរហើយ។ អ្នកអាចបន្ថយភាពរឹងកំព្រឹស បើអ្នកអនុវត្តតួនាទីជាអ្នកដឹកនាំដែលជាមនុស្សពូកែស្ដាប់ សម្របសម្រួលឱ្យមនុស្សពិភាក្សា និងធ្វើការជាមួយគ្នាបាន។

**វិញ្ញាណនាំសុខដល់ខ្លួន** Healthy sense of self **ឬមួយអាត្មានិយម៖** អ្នកគប្បីភ្ញាក់ដឹងថា ចិត្តខ្មៅ (darkness) អាចងាយជ្រាបចូលក្នុងខ្លួនអ្នកបន្ថែមលើចិត្តខ្មៅដែលអ្នកបានរស់នៅជាមួយវាក្នុងរយៈកាល៣ទសវត្សរ៍នៃសង្គ្រាម តែការស្វែងរកចិត្តភ្លឺថ្លា (light) ជាការលំបាក។ បើអ្នកចំណាយពេលមួយគ្រប់គ្រាន់ព្យាយាមលុបចិត្តខ្មៅ ហើយជំនួសឱ្យវិញនូវចិត្តភ្លឺថ្លា នោះអ្នកនឹងមានភាពងាយស្រួលក្នុងការរក្សាចិត្តភ្លឺថ្លា ហើយវានឹងនាំឱ្យអ្នកបណ្ដុះបាននូវវិញ្ញាណនាំសុខដល់ខ្លួន។

៤. វត្ថុបំណង Purpose

**មានទិសដៅច្បាស់លាស់** Clear direction **ឬមួយ រស់តាមទម្លាប់៖** ធ្វើកិច្ចការមួយត្រូវសម្រេចលទ្ធផលមួយ មិនមែនធ្វើកិច្ចការមួយបានចប់ទៅវិញដោយបានធ្វើកិច្ចការមួយនោះទេ។ សន្សំលទ្ធផលប្រាកដចំនួនមួយ ឬ ពីរក្នុងមួយឆ្នាំដែលនាំដល់ការសម្រេចផលសិក្សារបស់សិស្សនោះជាការប្រពៃ។ អ្នកគប្បីជឿថាបើធ្វើកិច្ចការច្រើនពេកដដែលៗ

នឹងនាំឱ្យបង្កើតឡើងនូវបញ្ហារាប់មិនអស់ហើយរវល់តែដោះស្រាយវា។ តម្រូវការក្នុងសង្គមមិននៅដដែលទេ ការកំណត់ទិសច្បាស់លាស់ ហើយធ្វើកិច្ចការចាំបាច់ដើម្បីសម្រេចបានដល់ទិសដៅ នោះអ្នកនឹងអាចឆ្លើយតបបាននូវតម្រូវការសង្គមហើយ។

**វិញ្ញាណយល់ថាជីវិតហ្នឹងមានន័យ** Sense that life has meaning **ឬមួយ រស់ក្រោមក្រមជាមួយភាពឯកោះ** អ្នកជាមនុស្សតែម្នាក់គត់ដែលធ្វើឱ្យជីវិតអ្នកមានន័យ។ ជីវិតមានន័យលុះណាអ្នកអាចជួយខ្លួនឯងបាននិងជួយមនុស្សជុំវិញអ្នកបាន។ អ្នកជាមនុស្ស ដូចនេះពេលជួបបរាជ័យក្នុងការងារត្រូវចាត់ទុកថាជារឿងធម្មតា រៀនពីវាហើយចៀសវាងភាពបរាជ័យលើកទី២លើកិច្ចការដដែល។

**គ្រប់ចរិយាប្រចាំថ្ងៃមានវត្ថុបំណងច្បាស់លាស់** Everyday tasks aligned with purpose **ឬមួយគ្រប់គ្រាន់ជាមួយចរិយាអវិជ្ជមាន បើទោះជាកំពុងធ្វើបាបខ្លួនក៏ដោយចុះ៖** នៅពេលជួយចំណោទឬបញ្ហា សំណួរគន្លឹះអ្នកត្រូវសួរខ្លួនឯងគឺ ទី១ តើអ្នកប្រាកដចង់បានអ្វីពីចំណោទឬបញ្ហាមួយនេះ? និងទី២ សួរខ្លួនអ្នកថា តើត្រូវធ្វើអ្វីដើម្បីទទួលនូវអ្វីដែលអ្នកចង់បាន។

**ឧទាហរណ៍ពីចំណោទទី១** មនុស្សម្នាក់ជេរមនុស្សម្នាក់ទៀតមិនឈប់រយៈពេលពីរថ្ងៃកន្លះ មនុស្សដែលត្រូវគេជេរសួរសំណួរទី១ដល់ខ្លួនឯងថា តើចង់បានអ្វីពីចំណោទមួយនេះ ចម្លើយគឺ មិនចង់បានអ្វីទាំងអស់ពីអ្នកជេរនោះដោយសារគាត់នោះមិនមានអ្វីជាផ្លូវការទាក់ទងនិងអ្វីដែលគាត់ជេរ រួចបន្តសួរសំណួរទី២ តើត្រូវធ្វើអ្វីចំពោះការជេរនោះចម្លើយគឺ មិនចាំបាច់ត្រូវធ្វើអ្វីទាំងអស់ ព្រោះអ្នកមិនចង់បានអ្វីពីចំណោទនេះផង។ ប្រាំមួយខែក្រោយអ្នកជេរចង់មកនិយាយជាមួយអ្នកត្រូវគេជេរ តែមិនហ៊ានមកជួបដោយសារខ្លាចអ្នកត្រូវគេជេរខឹង គាត់ស៊ើបសួរគេឯង ហើយទីបំផុតគាត់ដឹងថាអ្នកត្រូវគេជេរមិនបានខឹងជាមួយកាត់ទេ ដូចនេះគាត់ក៏សុំមកជួបអ្នកត្រូវកាត់ជេរ។ ទំនាក់ទំនងរវាងមនុស្សទាំងពីរបានចាប់ផ្តើមជាធម្មតា។

**បន្តឧទាហរណ៍ចំណោទទី២៖** ទាក់ទងនឹងសំណួរសួរថា តើការកុហកជានិច្ចកាលខុសមែនទេ បើមិនមែន តើពេលណាដែលការកុហកអាចទទួលយកបាន? វប្បធម៌ស្តីបន្ទោសនាំឱ្យមនុស្សភ័យខ្លាចនិងមិននិយាយការពិត។ ការកុហកមិនមែនដើម្បីប្រយោជន៍បុគ្គលខ្លួន និងដើម្បីជួយអ្នកដទៃ តើទទួលយកបានទេ? បើវាខុសនឹងច្បាប់ តែវាត្រូវនឹងយុត្តិធម៌សង្គម តើវានឹងទៅជាយ៉ាងណាដែរ? បើវាត្រូវជាមួយមនុស្សមួយក្រុម តែវាធ្វើឱ្យខាតបង់ប្រយោជន៍មនុស្សជាច្រើន តើវាយ៉ាងមេចវិញដែរ? ចុះវាដើម្បីប្រយោជន៍តែសម្រាប់បុគ្គលម្នាក់ នោះវានាំឱ្យក្លាយទៅជាអ្វី? បើការកុហកវាជះឥទ្ធិពលតែក្នុងគ្រួសារ តើគ្រួសារនឹងក្លាយជាយ៉ាងណា? តែបើវាជះឥទ្ធិពលដល់សង្គម តើវានឹងមានអ្វីកើតឡើង?

កត្តាធ្វើឱ្យជីវិតរីករាយ ធ្វើម្តេចទើបបានវា?

ជីវិតដែលមានទំនាក់ទំនងមិត្តភាព

**១. ជាមួយសង្គម គឺ មិនឯកោ**

**២. ដោយមានគុណភាព តែមិនមែនបរិមាណ**

**៣. នាំឱ្យខួរក្បាលរីកចម្រើន**

# ជំពូក៤
# ប្រព័ន្ធផ្តល់អំណាចធានា សម្រេចផលសម្រេចដើម្បី កសាងគណនេយ្យភាព

## ក. ក្របខ័ណ្ឌលទ្ធផល

ក្របខ័ណ្ឌលទ្ធផលឆ្នាំ២០២១ដល់២០៣០ ជាតារាងលម្អិតតួលេខគោលបំណងឱ្យក្លាយជាក្រុមគោលដៅតាមឆ្នាំ។ ក្របខ័ណ្ឌលទ្ធផលមានពីរកម្រិត៖ ១) សូចនាករផលសម្រេច និង២) សូចនាករនាំសម្រេចសូចនាករផលសម្រេច។ ក្រុមគោលដៅបានកំណត់ គឺផ្អែកលើធនធានដែលកំពុងមាននិងអាចរកបាននៅសហគមន៍ អាចកសាងសហគមន៍សាលារៀនបំពេញស្តង់ដាបាន ធនធានមនុស្សនៅថ្នាក់ជាតិនិងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀននិងគណៈគ្រប់គ្រងសាលារៀនដែលកំពុងមាន និងការប្តេជ្ញាចិត្តរបស់ក្រសួង ថ្នាក់ក្រោមជាតិ រដ្ឋអំណាចមូលដ្ឋាន សាលារៀននិងសហគមន៍។

### ក្របខ័ណ្ឌលទ្ធផលអនុវិស័យអប់រំមធ្យមសិក្សាឆ្នាំ២០២១ដល់២០៣០

| សូចនាករ | 2020 | 2021 | 2022 | 2023 | 2024 | 2025 | 2026 | 2027 | 2028 | 2029 | 2030 |
|---|---|---|---|---|---|---|---|---|---|---|---|
| *សូចនាករផលសម្រេច* | | | | | | | | | | | |
| *១ ចំនួនឬភាគរយសិស្សចូលរៀន (Average Lower and Upper)* | 38.86 | 40 | 42 | 44 | 47 | 50 | 55 | 60 | 65 | 70 | 76 |
| *២ ចំនួនឬភាគរយសិស្សមានសមត្ថភាពល្អនិងល្អប្រសើរមុខវិជ្ជាភាសាខ្មែរ* | NA | 10 | 15 | 20 | 25 | 30 | 40 | 50 | 60 | 70 | 80 |
| *៣ ចំនួនឬភាគរយសិស្សមានសមត្ថភាពល្អនិងល្អប្រសើរមុខវិជ្ជាគណិតវិទ្យា* | NA | 10 | 15 | 20 | 25 | 30 | 40 | 50 | 60 | 70 | 80 |
| *៤ ចំនួនសាលាមធ្យមសិក្សាមានស្តង់ដាអប្បបរមានៃស្តង់ដាសាលារៀនមានប្រសិទ្ធភាព* | 35 | 50 | 80 | 150 | 300 | 500 | 600 | 750 | 850 | 1000 | 1190 |
| *៥ ចំនួនគ្រូបានបញ្ចប់កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន* | | 2277 | 3500 | 5000 | 6500 | 8500 | 10000 | 12000 | 15000 | 18000 | 21000 |
| *៦ ចំនួនសាលារៀនដែលគ្រប់ថ្នាក់ទាំងអស់មានដំណើរការសម្រាប់ការសិក្សារបស់សិស្សម្នាក់ៗ* | 35 | 50 | 80 | 150 | 300 | 500 | 600 | 750 | 850 | 1000 | 1190 |

| ***សូចនាករនាំសម្រេចផលសម្រេចសូចនាករផលសម្រេច*** | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| *១. ចំនួនសាលារៀនមានកម្មវិធីបំណិនរកចំណូល* | | 30 | 100 | 200 | 300 | 450 | 600 | 750 | 900 | 1050 | 1190 |
| *២. ចំនួនគណៈគ្រប់គ្រងសាលារៀនចូលរៀននិងបញ្ចប់ការសិក្សាវគ្គបង្កើនគុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀនពីការគ្រប់គ្រងតាមសាលារៀន* | 160 | 594 | 800 | 1200 | 1600 | 2000 | 2600 | 3200 | 3800 | 4400 | 5000 |
| *៣. ចំនួនគ្រូបង្រៀនចូលរៀនវគ្គសិក្សាបង្កើនគុណវុឌ្ឍិគ្រូបង្រៀន* | 194 | 853 | 2277 | 4000 | 6500 | 9000 | 11000 | 14000 | 17000 | 20000 | 23000 |
| *៤. ចំនួនមន្ត្រីអប់រំ តាមសាលារៀន និង គ.គ.ស.បានចូលរួមរៀនសូត្រពីការគ្រប់គ្រងតាមសាលាលារៀន* | 300 | 500 | 700 | 1000 | 1350 | 1785 | 2200 | 2500 | 2800 | 3100 | 3570 |
| *៥. ចំនួនថ្នាក់រៀនបានសាងសង់ថ្មី និងជួសជុល* | 1270 | 2300 | 3500 | 5000 | 6500 | 8000 | 10000 | 12000 | 15000 | 17500 | 20000 |
| *៦. ចំនួនសាលារៀនមានថ្នាក់រៀនប្រើបច្ចេកវិទ្យាក្នុងការបង្រៀននិងរៀន* | NA | 20 | 50 | 100 | 160 | 230 | 280 | 360 | 420 | 500 | 580 |
| *៧. ចំនួនមន្ទីរអប់រំ យុវជន និងកីឡារាជធានីនិងខេត្តមានផែនការប្រតិបត្តិឆ្នាំតាមការណែនាំ* | | 10 | 12 | 14 | 16 | 18 | 20 | 22 | 24 | 25 | 25 |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| *៨. ចំនួនការិយាល័យអប់រំ យុវជន និង កីឡា ស្រុកមានផែនការប្រតិបត្តិឆ្នាំ តាមការណែនាំ* | | 89 | 100 | 110 | 120 | 150 | 170 | 190 | 200 | 200 | 200 |
| *៩. ចំនួនសាលារៀនមានកម្មវិធីធានា រ៉ាប់រងសង្គមនិងអភិវឌ្ឍសមត្ថភាព មន្ត្រី* | | 16 | 50 | 100 | 200 | 300 | 450 | 600 | 750 | 950 | 1190 |
| *១០. ចំនួនសិស្សក្រីក្របានទទួល អាហារូបករណ៍ (គិតជាភាគរយ)* | 10 | 9 | 8 | 7 | 6 | 5 | 4 | 3 | 2 | 1 | 0 |
| *១១. ចំនួនឃុំដែលមានសាលារៀនមធ្យម សិក្សា (គិតជាភាគរយ)* | 93 | 93.5 | 94 | 95 | 95.5 | 96 | 96.5 | 97 | 97.5 | 98.2 | 99 |
| *១២. ភាគរយសិស្សសិក្សាកម្មវិធីបំណិន រកចំណូល* | NA | 4 | 10 | 16 | 24 | 32 | 40 | 48 | 58 | 68 | 80 |
| *១៣. ភាគរយសិស្សបន្តការសិក្សានៅ ឧត្តមសិក្សា* | NA | 4 | 8 | 12 | 16 | 20 | 25 | 30 | 35 | 40 | 50 |
| *១៤. ភាគរយសិស្សអនុវត្តបំណិន រកចំណូលនៅផ្ទះឬសហគ្រាស* | NA | 2 | 4 | 6 | 8 | 12 | 15 | 18 | 21 | 25 | 30 |

## ខ. ការពិនិត្យតាមដាននិងការរាយការណ៍ផ្តោតលើលទ្ធផល

ការពិនិត្យតាមដាននិងការរាយការណ៍មានបីកម្រិតគឺ៖

១) ការពិនិត្យតាមដាននិងការរាយការណ៍ពីការអនុវត្ត (inputs and process) ជាការរាយការណ៍ប្រចាំខែ

២) ការពិនិត្យតាមដាននិងការរាយការណ៍ពីទិន្នផល (process and outputs/intermediate outcome indicators) ជាការរាយការណ៍ប្រចាំត្រីមាសនិងឆមាស និង

៣) ការពិនិត្យឡើងវិញនិងការរាយការណ៍ពីលទ្ធផលឬផលសម្រេចនិងយុទ្ធសាស្ត្រ (outcomes and strategies) ជាការរាយការណ៍ប្រចាំឆ្នាំ។ ការរាយការណ៍ប្រចាំឆ្នាំត្រូវផ្សារភ្ជាប់ជាមួយនឹងការប្រជុំប្រចាំខែ ប្រចាំត្រីមាស និងឆមាស។

**បរិបទនៃការពិនិត្យតាមដានប្រចាំខែ៖** ជាការពិនិត្យការរីកចម្រើនការអនុវត្តសកម្មភាពគ្រោងក្នុងខែ និងការត្រៀមអនុវត្តសកម្មភាពគ្រោងនៅខែបន្ទាប់ ព្រមទាំងវិភាគពីមូលហេតុនៃភាពរីកចម្រើន ឧបសគ្គនិងការរាំងស្កាត់ និងដំណោះស្រាយ។

**ការពិនិត្យតាមដានត្រីមាសនិងឆមាស៖** ជាការពិនិត្យតាមដានពីការរីកចម្រើនក្រុមគោលដៅនៃសូចនាករ និងការឈានឆ្ពោះទៅរកការសម្រេចបាននូវក្រុមគោលដៅនៃសូចនាករផលសម្រេចប្រចាំឆ្នាំ។

**ការពិនិត្យឡើងវិញប្រចាំឆ្នាំ៖** ជាការពិត្យនូវការសម្រេចក្រុមគោលដៅនៃសូចនាករផលសម្រេច និងក្រុមគោលដៅនៃសូចនាករនាំសម្រេចនូវសូចនាករផលសម្រេចប្រចាំឆ្នាំរបស់អនុវិស័យ ការរីកចម្រើនការអនុវត្តយុទ្ធសាស្ត្រ និងការអនុវត្តវប្បធម៌និងគុណតម្លៃរបស់អនុវិស័យ។

**ការពិនិត្យឡើងវិញពាក់កណ្តាលយុទ្ធសាស្ត្រ៖** ជាការពិនិត្យពីការសម្រេចផលសម្រេចរបស់អនុវិស័យក្នុងក្របខ័ណ្ឌលទ្ធផល ១០ឆ្នាំ ការរីកចម្រើនការអនុវត្តយុទ្ធសាស្ត្រ ប្រព័ន្ធផ្តល់លទ្ធភាពអនុវត្ត ប្រព័ន្ធផ្តល់អំណាច និងប្រព័ន្ធផ្តល់ថាមពលធ្វើការងារ និងកែសម្រួលយុទ្ធសាស្ត្រ និងក្របខ័ណ្ឌលទ្ធផល១០ឆ្នាំ។

## គ. ការធ្វើកម្មវិធីវិនិយោគ និងផែនការអនុវត្ត

ក) **ការគ្រោងកម្មវិធីវិនិយោគ**

ខ្លឹមសារកម្មវិធីវិនិយោគនឹងត្រូវរៀបចំឡើងតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ខ្លឹមសារជារួមនឹងអាចមានដូចខាងក្រោម៖

១) បរិបទអនុវិស័យ

២) បេសកកម្ម និងគោលបំណង

៣) យុទ្ធសាស្ត្រអនុវិស័យ និងសមាសសធាតុកម្មវិធីវិនិយោគ

៤) ក្របខ័ណ្ឌលទ្ធផលរយៈពេល៥ឆ្នាំ

៥) រចនាសម្ព័ន្ធគ្រប់គ្រងនិងអនុវត្ត

៦) ប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃ

៧) ការគ្រោងថវិការយៈពេល៥ឆ្នាំ

៨) ហានិភ័យ

១០) សុវត្ថិភាពបរិស្ថាន និងសង្គម

១១) និរន្តរភាព

## ខ-ការគ្រោងផែនការយុទ្ធសាស្ត្រថវិកា

ដូចគ្នានេះដែរ ខ្លឹមសារផែនការយុទ្ធសាស្ត្រថវិកា ត្រូវយកតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការគ្រោងផែនការប្រតិបត្តិប្រចាំឆ្នាំនិងថវិកាមានគ្របដណ្តប់ជាពីរសំណុំសកម្មភាព ដែលត្រូវបញ្ចូលក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ សំណុំទី១ គឺ ក្របខ័ណ្ឌលទ្ធផលរយៈពេល៣ឆ្នាំ (រំកិល៣ឆ្នាំចាប់ពីឆ្នាំទី២ទៅ) និងសំណុំទី២ គឺ យុទ្ធសាស្ត្រអនុវិស័យ និងការចុះជួយសាលារៀនដើម្បីបំពេញស្តង់ដាសហគមន៍សាលារៀន។

### ខ.១. ក្របខ័ណ្ឌលទ្ធផលរយៈពេល៣ឆ្នាំ (រំកិល៣ឆ្នាំចាប់ពីឆ្នាំទី២ទៅ)

| សូចនាករ*ផលសម្រេច* | តួលេខ មូលដ្ឋាន ( ចុងឆ្នាំមុន ) | ក្រុមគោលដៅឆ្នាំ□□ | លទ្ធផល សម្រេចចុងឆ្នាំ □□ |
|---|---|---|---|
| *១. ចំនួនឬភាគរយសិស្សចូលរៀន (Average Lower and Upper)* | | | |
| *២. ចំនួនឬភាគរយសិស្សមានសមត្ថភាពល្អនិងល្អប្រសើរមុខវិជ្ជាភាសាខ្មែរ* | | | |
| *៣. ចំនួនឬភាគរយសិស្សមានសមត្ថភាពល្អនិងល្អប្រសើរមុខវិជ្ជាគណិតវិទ្យា* | | | |
| *៤. ចំនួនសាលាមធ្យមសិក្សាមានស្តង់ដាអប្បបរមានៃស្តង់ដាសាលារៀនមានប្រសិទ្ធភាព* | | | |
| *៥. ចំនួនគ្រូបានបញ្ចប់កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន* | | | |
| *៦. ចំនួនសាលារៀនដែលគ្រប់ថ្នាក់ទាំងអស់មានដំណើរការសម្រាប់ការសិក្សាសិស្សម្នាក់ៗ* | | | |
| ***សូចនាករនាំសម្រេចសូចនាករផលសម្រេច*** | | | |
| *១. ចំនួនសាលារៀនមានកម្មវិធីបំណិនរកចំណូល* | | | |
| *២. ចំនួននាយកសាលារៀនចូលរៀននិងបញ្ចប់ការសិក្សាវគ្គបង្កើនគុណវុឌ្ឍិនាយកសាលាពីការគ្រប់គ្រងតាមសាលារៀន* | | | |
| *៣. ចំនួនគ្រូបង្រៀនចូលរៀនវគ្គសិក្សាបង្កើនគុណវុឌ្ឍិគ្រូបង្រៀន* | | | |
| *៤. ចំនួនមន្ត្រីអប់រំ តាមសាលារៀន និងគ.គ.ស.បានចូលរួមរៀនសូត្រពីការគ្រប់គ្រងតាមសាលាលារៀន* | | | |
| *៥. ចំនួនថ្នាក់រៀនបានសាងសង់ថ្មី និងជួសជុល* | | | |
| *៦. ចំនួនសាលារៀនមានថ្នាក់រៀនប្រើបច្ចេកវិទ្យាក្នុងការបង្រៀននិងរៀន* | | | |
| *៧. ចំនួនមន្ទីរអប់រំ យុវជន និងកីឡា រាជធានីនិងខេត្តមានផែនការប្រតិបត្តិឆ្នាំតាមការណែនាំ* | | | |

| | | | |
|---|---|---|---|
| *៨. ចំនួនការិយាល័យអប់រំ យុវជន និងកីឡា ស្រុកមានផែនការប្រតិបត្តិឆ្នាំ តាមការណែនាំ* | | | |
| *៩. ចំនួនសាលារៀនមានកម្មវិធីធានាគាំប់រងសង្គមនិងអភិវឌ្ឍសមត្ថភាពមន្ត្រី* | | | |
| *១០. ចំនួនសិស្សក្រីក្របានទទួលអាហារូបករណ៍ (គិតជាភាគរយ)* | | | |
| *១១. ចំនួនឃុំដែលមានសាលារៀនមធ្យមសិក្សា (គិតជាភាគរយ)* | | | |
| *១២. ភាគរយសិស្សសិក្សាកម្មវិធីបំណិនរកចំណូល* | | | |
| *១៣. ភាគរយសិស្សបន្តការសិក្សានៅឧត្តមសិក្សា* | | | |
| *១៤. ភាគរយសិស្សអនុវត្តបំណិនរកចំណូលនៅផ្ទះឬសហគ្រាស* | | | |

## ខ.៣. ផែនការប្រតិបត្តិប្រចាំឆ្នាំអនុវត្តយុទ្ធសាស្ត្រអនុវិស័យ និងការចុះជួយសាលារៀន

| ល.រ. | យុទ្ធសាស្ត្រ និងសកម្មភាព | បញ្ចូលថ្ងៃខែ | | | | ថវិកា |
|---|---|---|---|---|---|---|
| | | ត្រី ១ | ត្រី ២ | ត្រី៣ | ត្រី៤ | |
| ១ | ផ្តល់ស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុដល់សហគមន៍សាលារៀន | | | | | |
| ២ | បង្កើតនិងអនុវត្តកម្មវិធីធានារ៉ាប់រងសង្គម និងអភិវឌ្ឍសមត្ថភាពជាប្រចាំសម្រាប់គ្រូបង្រៀននិងនាយកសាលារៀន | | | | | |
| ៣ | សហការណ៍ជាមួយមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បង្កើនគុណវុឌ្ឍិគ្រូបង្រៀននិងនាយកសាលាដែលធានាថាថ្នាក់រៀនមាន ដំណើរការសម្រាប់ការសិក្សារបស់សិស្សម្នាក់ៗ | | | | | |
| ៤ | អនុវត្តកម្មវិធីបំណិនរកចំណូលធានាសិស្សរៀនមានសមត្ថភាពសម្រាប់ជីវិត រកចំណូល និងការសិក្សានៅឧត្តមសិក្សា | | | | | |
| ៥ | បង្កើតកម្មវិធីប្រកួតប្រជែងសមត្ថភាពសិស្សសាលារដ្ឋ និងសាលាឯកជន | | | | | |
| ៦ | ចំនួនដងនាយកសាលានិងនាយកសាលារងបានទទួលការហ្វឹកហាត់អនុវត្តការគ្រប់គ្រងតាមសាលារៀន | | | | | |
| ៧ | ចំនួនដងគ្រូបង្រៀនបានទទួលការហ្វឹកហាត់ការបង្រៀន | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | ចម្រុះមុខវិជ្ជាតាមផែនការ | | | | | |
| ៨ | ចំនួនដងទស្សនៈកិច្ចផ្តល់ការគាំទ្រពីក្រុមការងារតំបន់បាន អនុវត្តតាមផែនការ | | | | | |
| ៩ | ចំនួនដងទស្សនៈកិច្ចផ្តល់ការគាំទ្រពីមន្ទីរអប់រំ យុវជន និង កីឡាបានអនុវត្តតាមផែនការ | | | | | |
| ១០ | ចំនួនដងទស្សនៈកិច្ចផ្តល់ការគាំទ្រពីការិយាល័យអប់រំ យុវជន និងកីឡាបានអនុវត្តតាមផែនការ | | | | | |
| ១១ | ការបង្រៀនបំណិនកសិកម្ម និងបច្ចេកទេសបានអនុវត្ត តាមផែនការ | | | | | |
| ១២ | ចំនួនគ្រូបង្រៀនខ្វះតាមមុខវិជ្ជាថយចុះតាមផែនការ | | | | | |
| ១៣ | ចំនួននាយកសាលានិងនាយកសាលារងមានជាផ្លូវការ តាមបទដ្ឋាន | | | | | |
| ១៤ | កាតរបាយការណ៍សាលារៀនបានផលិត និងបិទផ្សាយ | | | | | |

### ខ.៤. ទំនាក់ទំនងផែនការអនុវិស័យនិងផែនការកែលម្អសាលារៀន

#### បរិបទនៃផែនការអនុវិស័យ

ផលសម្រេចការអប់រំនិងការសិក្សាគឺកើតមានឡើងនៅសាលារៀន ដូចនេះ អនុវិស័យត្រូវធានាថាការធ្វើផែនការរយៈពេលមធ្យមគឺ ជាការកំណត់ឱ្យបានច្បាស់លាស់នូវកិច្ចការត្រូវធ្វើ ក្នុងការអនុវត្តយុទ្ធសាស្ត្រអនុវិស័យ និងអនុវត្តនូវសូនាករផលសម្រេច និងសូចនាករនាំសម្រេចបាននូវផលសម្រេចដែលមាននៅក្នុងក្របខ័ណ្ឌលទ្ធផល១០ឆ្នាំ។

យុទ្ធសាស្ត្រអនុវិស័យនឹងនាំឱ្យសម្រេចបាននូវបេសកកម្មនិងគោលបំណងអនុវិស័យ រីឯក្របខ័ណ្ឌលទ្ធផលនឹងនាំឱ្យសម្រេចបាននូវស្តង់ដាសាលារៀនមានប្រសិទ្ធភាព។ ទាំងយុទ្ធសាស្ត្រនិងក្របខ័ណ្ឌលទ្ធផលគឺ ធានាសម្រេចបានបេសកកម្មនិងគោលបំណងនៅក្នុងវិសាលភាពទូលាយទូទាំងប្រទេស។

កាលបរិច្ឆេទការប្រជុំនិងរាយការណ៍ប្រចាំខែ

| កម្រិតរចនាសម្ព័ន្ធ | ត្រីមាសទី១ | ត្រីមាស ឬ ឆមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ឬ ឆមាសទី២ ឬឆ្នាំ |
|---|---|---|---|---|
| **សាលារៀន** | | | | |
| *ស្វ័យវាយតម្លៃនិងផែនការប្រតិបត្តិឆ្នាំ* | | | | ១០ តុលា |
| *ប្រជុំត្រីមាសនិងរបាយការណ៍ត្រីមាស* | ៣០ មករា | ៣០ មេសា | ៣០ កក្កដា | |
| *របាយការណ៍ឆ្នាំ (តួលេខចូលរៀនឆ្នាំសិក្សាថ្មី)* | | | | ១០ វិច្ឆិកា |
| **ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ** | | | | |
| *ស្វ័យវាយតម្លៃនិងផែនការប្រតិបត្តិឆ្នាំ* | | | | ១៥ តុលា |
| *ប្រជុំត្រីមាសនិងរបាយការណ៍ត្រីមាស* | ៥ កុម្ភៈ | ៥ ឧសភា | ៥ សីហា | |
| *របាយការណ៍ឆ្នាំ* | | | | ១៥ វិច្ឆិកា |
| **មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត** | | | | |
| *ស្វ័យវាយតម្លៃនិងយុទ្ធសាស្ត្រនិងផែនការប្រតិបត្តិប្រចាំឆ្នាំ* | | | | ២០ តុលា |
| *ប្រជុំត្រីមាសនិងរបាយការណ៍ត្រីមាស* | ១០ កុម្ភៈ | ១០ ឧសភា | ១០ សីហា | |
| *របាយការណ៍ឆ្នាំ* | | | | ២០ វិច្ឆិកា |
| **នាយកដ្ឋាន និងអនុវិស័យ** | | | | |
| *យុទ្ធសាស្ត្រនិងផែនការប្រតិបត្តិប្រចាំឆ្នាំ* | | | | ២៥ តុលា |
| *ប្រជុំត្រីមាសនិងរបាយការណ៍ប្រចាំត្រីមាស* | ១៥ កុម្ភៈ | ១៥ ឧសភា | ១៥ សីហា | |
| *របាយការណ៍ប្រចាំឆ្នាំ* | | | | ២៥ វិច្ឆិកា |

## ឃ. ខ្លឹមសារសម្រាប់ការរាយការណ៍ប្រចាំខែពីការអនុវត្ត ( inputs and process )

១) ការរីកចម្រើនការអនុវត្តសកម្មភាព (បានធ្វើ មិនបានធ្វើ)

២) បញ្ហា ឬ ការប្រឈម (មកពីអ្វី៖ ធាតុចូល យន្តការគាំទ្រ អំណាច សមត្ថភាព)

(ក) ធាតុចូលមិនគ្រប់ ផ្តល់មិនទាន់ពេល ហេតុអ្វី?

(ខ) យន្តការគាំទ្រមិនមាន មិនធ្វើ ធ្វើមិនត្រឹមត្រូវ?

(គ) អំណាចមិនមាន មានតែមិនអនុវត្ត មានតែមិនច្បាស់?

(ឃ) សមត្ថភាពខ្វះ មិនធ្វើ ធ្វើមិនឱ្យត្រូវ?

៣) សំណើសកម្មភាពជាដំណោះស្រាយ

(ក) សកម្មភាពដែលដោះស្រាយចំណុចលើកឡើងខាងលើ

### ឃ.១. របៀបពិនិត្យតាមដានប្រចាំខែ៖ កម្មវិធីប្រជុំប្រចាំខែ

**វត្ថុបំណង៖**

ឆ្លុះបញ្ចាំងពីការអនុវត្តសកម្មភាពប្រចាំខែតាមខែនីមួយៗ ពិភាក្សារកមូលហេតុ និងសកម្មភាពដោះស្រាយ

**របៀបពិនិត្យតាមដាន៖**

ប្រជុំប្រចាំខែដែលដឹកនាំការប្រជុំដោយប្រធាននាយកដ្ឋាន

អនុប្រធាននាយកដ្ឋានជាអ្នករាយការណ៍

**កំណត់ហេតុជារបាយការណ៍ពិនិត្យតាមដាន៖**

ផ្តោតខ្លឹមសារថាបានអនុវត្តឬមិនបាន អនុវត្តតាមបច្ចេកទេសឬក្រិត្យក្រមឬទេ ការពិបាកជាមូលហេតុ និង សកម្មភាពជាដំណោះស្រាយ

**គំរូកំណត់ហេតុប្រជុំនៅទំព័រមុន៖**

ចំនួន២ ទំព័រយ៉ាងច្រើន

### ឃ.២ ទម្រង់សម្រាប់បង្ហាញក្នុងការប្រជុំប្រចាំខែ

- សកម្មភាពគ្រោងក្នុងខែនៃផែនការសកម្មភាពត្រីមាសទី១

| យុទ្ធសាស្ត្រនិងសកម្មភាពគ្រោង | បានអនុវត្ត | មិនបានអនុវត្ត | មូលហេតុ |
|---|---|---|---|
| | | | |
| | | | |
| | | | |

- សកម្មភាពជាដំណោះស្រាយ

ឃ.៣. ទម្រង់របាយការណ៍ ប្រចាំខែ

**១) ការរីកចម្រើនការអនុវត្តសកម្មភាព (បានធ្វើ មិនបានធ្វើ)**

| សកម្មភាព | បានធ្វើ | មិនបានធ្វើ | មូលហេតុ (បញ្ហាឬការប្រឈម) |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |

**២) សំណើសកម្មភាពជាដំណោះស្រាយ**

(ក) សកម្មភាពដែលដោះស្រាយចំណុចបញ្ហាឬការប្រឈមលើកឡើងខាងលើ

ថ្ងៃទី.................ខែ..........ឆ្នាំ............. ធ្វើនៅ..............ថ្ងៃទី..............ខែ..........ឆ្នាំ.............

ប្រធាន អ្នកធ្វើរបាយការណ៍

## ង. ការប្រជុំនិងរាយការណ៍ប្រចាំត្រីមាស

ង.១. ទម្រង់របាយការណ៍ប្រចាំត្រីមាសពីទិន្នផល

១) ការរីកចម្រើនប្រចាំត្រីមាស៖ សម្រេចទិន្នផលគ្រោងក្នុងត្រីមាស និង ការអនុវត្តកិច្ចការត្រឹមត្រូវទេ

២) បញ្ហា ឬ ការប្រឈម (មកពីអ្វីបានមិនសម្រេច ឬ ធ្វើមិនត្រឹមត្រូវ៖ គុណភាពទិន្នផល ការទទួលខុសត្រូវ)

ក) គុណភាពទិន្នផល៖ ធ្វើកិច្ចការហើយតែចប់មិនមានអ្វីកើតឡើងបន្ទាប់ ទិន្នផលមួយមិនទាក់ទងជាមួយទិន្នផលមួយទៀតដែលនាំសម្រេចលទ្ធផល បរិមាណទិន្នផលផលិតបាតមិនពេញលេញសម្រាប់សម្រេចលទ្ធផល។
ហេតុអ្វី៖ មិនមានប្រព័ន្ធ មានប្រព័ន្ធតែមានចន្លោះ ឬមិនអនុវត្តប្រព័ន្ធតែម្តង។

ខ. ការទទួលខុសត្រូវតាមកម្រិតរចនាសម្ព័ន្ធ៖ ទិន្នន័យនិងព័ត៌មានមានមិនគ្រប់ មិនពិត និង យកជាការមិនបាន (មានតែទិន្នន័យល្អដែលមិនបង្ហាញភាពជាក់ស្តែង) ឬយកជាការបាន តែមិនមានការដោះស្រាយ ឬដោះស្រាយមិនទាន់ពេល

៣) សកម្មភាពជាដំណោះស្រាយ

ក. សកម្មភាពដោះស្រាយឱ្យចំបញ្ហាលើកឡើងខាងលើ

ង.២. បរិបទពិនិត្យតាមដានប្រចាំត្រីមាសឬឆមាស

១. ត្រីមាសទី១

- សួរថា ការរីកចម្រើននៃក្រុមគោលដៅរបស់សូចនាករនីមួយៗអាចឈានទៅសម្រេចបានតាមគ្រោង ឬទេនៅក្នុងឆ្នាំ?
- តើមូលហេតុអ្វីនាំសម្រេចបាន ឬសម្រេចមិនបាន (យន្តការអង្គភាព យន្តការប្រតិបត្តិ គុណតម្លៃ)?
- តើដំណោះស្រាយជាសកម្មភាពអ្វីត្រូវធ្វើនៅត្រីមាសបន្ទាប់?

២. ត្រីមាសទី២ឬឆមាសទី១

- សួរថា តើក្រុមគោលដៅរបស់សូចនាករនីមួយៗអាចឈានទៅសម្រេចបានតាមគ្រោងឬទេនៅក្នុងឆ្នាំ?
- តើមូលហេតុអ្វីនាំសម្រេចបាន ឬសម្រេចមិនបាន (យុទ្ធសាស្ត្រទាំង៥ យន្តការអង្គភាព យន្តការប្រតិបត្តិ គុណតម្លៃ)?
- តើដំណោះស្រាយជាសកម្មភាពអ្វីត្រូវធ្វើនៅត្រីមាស ឬឆមាសបន្ទាប់បន្ទាប់?

ង.៣. កម្មវិធីប្រជុំត្រីមាស

**វត្ថុបំណង៖**

ពិនិត្យពីស្ថានភាពរីកចម្រើនសម្រេចបាននៃក្រុមគោលដៅសូចនាករ មូលហេតុ និងសកម្មភាពជាដំណោះស្រាយ

**របៀបពិនិត្យតាមដាន៖**

ប្រជុំប្រចាំត្រីមាសដែលដឹកនាំការប្រជុំដោយអគ្គនាយករងអប់រំ
ប្រធាននាយកដ្ឋានជាអ្នករាយការណ៍

**កំណត់ហេតុជារបាយការណ៍ពិនិត្យតាមដាន៖**

ផ្តោតខ្លឹមសារតាមគំរូរបាយការណ៍ត្រីមាស

**ទម្រង់សម្រាប់បង្ហាញប្រជុំប្រចាំត្រីមាសទី១និងទី៣**

| យុទ្ធសាស្ត្រនិងសកម្មភាព | គ្រោង | សម្រេចបានឬមិនបាន | មូលហេតុ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |

- សកម្មភាពជាដំណោះស្រាយផ្តោតលើការសម្រេចបាននូវយុទ្ធសាស្ត្រនិងសកម្មភាពគ្រោងក្នុងត្រីមាស

## ច. ទម្រង់សម្រាប់បង្ហាញប្រជុំប្រចាំឆមាសទី១

- សកម្មភាពជាដំណោះស្រាយដែលផ្តោតសំខាន់លើការសម្រេចបានយុទ្ធសាស្ត្រនិងស្តង់ដាទី៥

| សូចនាករ | ក្រុមគោលដៅគ្រោង | អាចឬមិនអាចសម្រេចបាន | សកម្មភាពផ្តោតលើសូចនាករដែលអាចនឹងមិនសម្រេច |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

ច១. ទំរង់របាយការណ៍ឆមាសទី១

**១) ការរីកចម្រើនប្រចាំឆមាសៈ សម្រេចក្រុមគោលដៅគ្រោងក្នុងឆមាស និង ការអនុវត្តកិច្ចការត្រឹមត្រូវទេ**

| សូចនាករ | ក្រុមគោលដៅគ្រោង | អាចឬមិនអាចសម្រេចបាន | មូលហេតុជាបញ្ហាឬការប្រឈម |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

**២ សកម្មភាពជាដំណោះស្រាយ**

ក. សកម្មភាពដោះស្រាយឱ្យចំបញ្ហាលើកឡើងខាងលើ

## ឆ. ការប្រជុំនិងរាយការណ៍ប្រចាំឆ្នាំ

ឆ.១. គំរូរបាយការណ៍ប្រចាំឆ្នាំ

**១) ការរីកចម្រើនបេសកកម្ម និងគោលបំណង**

- សភាពប្រែប្រួលជាពាក្យ៖ នៅដដែល កម្រិតប្រែប្រួលវិជ្ជមាន ភាពជាម្ចាស់
- សភាពប្រែប្រួលជាចំនួន៖ តួលេខប្រែប្រួលបញ្ជាក់ពីសភាពប្រែប្រួលជាពាក្យខាងលើ

**២) ការរីកចម្រើនការអនុវត្តយុទ្ធសាស្ត្រ**

**យុទ្ធសាស្ត្រ៖ តើអ្វីដែលត្រូវធ្វើបានធ្វើដែរឬទេ?**

- ហេតុផល ឬការបកស្រាយ
- ទ្រឹស្តីផ្លាស់ប្តូរច្បាស់លាស់

**ដំណើរអនុវត្តការងារ៖ តើអ្វីដែលកំពុងធ្វើ ធ្វើបានត្រឹមត្រូវឬទេ?**

- ប្រសិទ្ធភាពនៃការសម្រេចផលសម្រេចគ្រោងទុក
- ប្រសិទ្ធផលនៃការប្រើប្រាស់ធនធាន (លុយតិចបានផលច្រើន)
- ការចូលចិត្តរបស់អតិថិជន

**ការរៀនសូត្រ៖ តើមានវិធីណាដែលប្រសើរជាងនេះឬទេ?**

- មានជម្រើសច្រើនឬទេ
- ការអនុវត្តនូវជម្រើសដែលប្រសើរបំផុត
- ការសិក្សារៀនសូត្រដែលបានទទួល

**៣) ការអនុវត្តគុណតម្លៃ**

**៤) បញ្ហាប្រឈម**

- ការគាំទ្រគោលនយោបាយ និងការទប់ស្កាត់ការផ្លាស់ប្តូរ
- ស្ថានភាពប្រែប្រួលទាក់ទងនិរន្តរភាព (ស្ថាប័ន សមត្ថភាព និងហិរញ្ញប្បទាន)
- ស្ថានភាពរួចស្រេចក្នុងការពង្រីកកម្មវិធីគំរូ (ភាពជាម្ចាស់ ធនធាន)

**៥) ដំណោះស្រាយជាអនុសាសន៍**

- សកម្មភាពដោះស្រាយបញ្ហាប្រឈមខាងលើ

**៦) អាទិភាពសម្រាប់ឆ្នាំបន្ទាប់**

ឆ.២. តារាងផលសម្រេចផលិតបានធៀបជាមួយក្របខ័ណ្ឌលទ្ធផល

| សូចនាករ | តួលេខមូលដ្ឋាន | ក្រុមគោលដៅឆ្នាំ | ក្រុមគោលដៅសម្រេចបានចុងឆ្នាំ |
|---|---|---|---|
| | | | |
| | | | |
| | | | |

ឆ.៣. តារាងការរីកចម្រើនការអនុវត្តយុទ្ធសាស្ត្រ

| យុទ្ធសាស្ត្រ | ផលសម្រេចបាន |
|---|---|
| | |
| | |
| | |
| | |

ឆ.៤. តារាងការរីកចម្រើនការអនុវត្តគណនេយ្យភាពថ្នាក់ជាតិនិងក្រោមជាតិ

| យុទ្ធសាស្ត្រ | ផលសម្រេចបាន |
|---|---|
| | |
| | |
| | |
| | |

ឆ.៥. របៀបពិនិត្យឡើងវិញប្រចាំឆ្នាំពីលទ្ធផលនិងយុទ្ធសាស្ត្រអនុវិស័យ

**១) ការរៀបចំមុនការពិនិត្យឡើងវិញ**

- នាយកដ្ឋានរៀបចំតារាងរីកចម្រើន វិភាគមូលហេតុ និងលើកសំណើរសកម្មភាពជាដំណោះស្រាយ

**២) ការអនុវត្តការពិនិត្យឡើងវិញ និងពេលវេលា**

- អគ្គនាយករងរាយការពីការរីកចម្រើនសូចនាករផលសម្រេចនិងសូចនាករនាំសម្រេចផលសម្រេច
- ថ្នាក់ដឹកនាំក្រសួងពិភាក្សាពីការរីកចម្រើនការអនុវត្តយុទ្ធសាស្ត្រ និងគុណតម្លៃ
- ការសម្រេចអាទិភាពនៃការរកឃើញសម្រាប់នៅឆ្នាំបន្ទាប់

**៣) ការរាយការណ៍ក្រោយការពិនិត្យឡើងវិញ និងពេលវេលា**

**៤) ការប្រើប្រាស់ការរកឃើញសម្រាប់ធ្វើផែនការឆ្នាំបន្ទាប់ក្នុងបរិបទការរៀបចំយុទ្ធសាស្ត្រថវិកា៣ឆ្នាំ និងពេលវេលា**

ឆ.៦. ពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិយុទ្ធសាស្ត្រ

ឆ.៦.១. បរិបទពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិយុទ្ធសាស្ត្រ

- វត្ថុបំណង៖ វាយតម្លៃការរីកចម្រើនក្នុងការសម្រេចបាននូវគោលបំណង ក្រុមគោលដៅនៃឆ្នាំទី៥ ភាពទាក់ទងនៃយុទ្ធសាស្ត្រ ដំណើរការនៃប្រព័ន្ធផ្ដល់លទ្ធភាពធ្វើការងារ ប្រព័ន្ធផ្ដល់អំណាច និង ប្រព័ន្ធផ្ដល់ថាមពលធ្វើការងាររបស់មន្ត្រី

- លទ្ធផល៖ រកឃើញនូវមេរៀនសិក្សាដែលនាំទៅកែសម្រួលយុទ្ធសាស្ត្រអនុវិស័យ ដែលនាំទៅរកការសម្រេចបាននូវគោលបំណងអនុវិស័យទៅតាមការគ្រោង ឬមួយសម្រេចបានលើសពីការគ្រោង។

ឆ.៦.២. របៀបពិនិត្យឡើងវិញពាក់កណ្ដាលយុទ្ធសាស្ត្រ

**១. ការរៀបចំមុនពេលពិនិត្យឡើងវិញ**

- នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ចងក្រងទិន្នន័យពីការសម្រេចក្រុមគោលដៅនៃគ្រប់សូចនាករក្នុងក្របខ័ណ្ឌលទ្ធផល សរុបនូវការវិភាគពីគ្រប់របាយការណ៍ឆ្នាំពីឆ្នាំទី១ដល់ទី៥
- អគ្គនាយករងអប់រំទទួលបន្ទុក សម្របសម្រួលរៀបចំនិងដឹកនាំការប្រជុំជាមួយនាយកដ្ឋានពាក់ព័ន្ធពិនិត្យលើទិន្នន័យ និងការវិភាគដែលបានចងក្រងខាងលើ

**២. ការអនុវត្តការពិនិត្យឡើងវិញ**

- អគ្គរងគោលនយោបាយនិងផែនការ បង្ហាញពីការរីកចម្រើនការអនុវត្តយុទ្ធសាស្ត្រដែលបានត្រៀមខាងលើ
- រដ្ឋមន្ត្រីដឹកនាំការប្រជុំពិនិត្យឡើងវិញពាក់កណ្ដាលយុទ្ធសាស្ត្រ
- កំណត់នូវការសម្រេចចិត្តកែសម្រួលយុទ្ធសាស្ត្រសម្រាប់រយៈពេល៥ឆ្នាំលើកទី២

**៣. ការរាយការណ៍ក្រោយការពិនិត្យឡើងវិញ**

- នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅចងក្រងរបាយការណ៍ពីការពិនិត្យឡើងវិញ និងរាយការណ៍នៅសន្និបាតអប់រំ

**៤. ការប្រើប្រាស់ការរកឃើញក្នុងការកែសម្រួលយុទ្ធសាស្ត្រអនុវិស័យ**

- នាយកដ្ឋានរៀបចំការប្រជុំកែសម្រួលយុទ្ធសាស្ត្រអនុវិស័យទៅតាមការកំណត់សម្រេចនៅក្នុងរបាយការណ៍សរុបនៃការពិនិត្យឡើងវិញពាក់កណ្ដាលយុទ្ធសាស្ត្រ
- អគ្គនាយករងអប់រំទទួលបន្ទុក ដឹកនាំការប្រជុំពិនិត្យកែសម្រួលយុទ្ធសាស្ត្រអនុវិស័យ និងរៀបចំកម្មវិធីវិនិយោគលើកទី២
- ដាក់ស្នើយុទ្ធសាស្ត្រអនុវិស័យដល់រដ្ឋមន្ត្រីដើម្បីសម្រេច

## ៥. ការអភិវឌ្ឍធនធានមនុស្ស

របាយការណ៍ស្រាវជ្រាវអន្តរជាតិពីការបង្រៀន និងរៀនរបស់ប្រទេស OECD

ប្រទេសជាច្រើននៅជុំវិញពិភពលោកបានអនុវត្តការកែទម្រង់លើកម្មវិធីសិក្សា របៀបបង្រៀន និងការវាយតម្លៃសមត្ថភាពសិស្ស ក្នុងបំណងអប់រំឱ្យបានប្រសើរដល់កុមារទាំងអស់សម្រាប់ឆ្លើយតបទៅនឹងការទាមទារយ៉ាងខ្ពស់នៃជីវិតនិងការងារនៅក្នុងសតវត្សទី២១។ ក្របខ័ណ្ឌជាច្រើនត្រូវបានរៀបចំដើម្បីធ្វើឱ្យទៅជាប្រព័ន្ធនៃបំណិនដែលយុវជនត្រូវការសម្រាប់ភាពជោគជ័យនៅក្នុងពិភពលោក ដែលមានការប្រែប្រួលឆាប់រហ័ស និងដើម្បីកំណត់នូវសមត្ថភាពដែលគ្រូបង្រៀនត្រូវការជាការឆ្លើយតបវិញ គ្រូបង្រៀនត្រូវបង្រៀនឱ្យមានប្រសិទ្ធភាពដល់សិស្សរបស់គេ។ សរុបការរកឃើញ៖

### ៥.១. ការទាមទារដែលដាក់បន្ទុកលើគ្រូបង្រៀនសម្រាប់សតវត្សទី២១ខ្ពស់ណាស់

១) គ្រូបង្រៀនត្រូវតែមានចំណេះដឹងលើមុខវិជ្ជាបង្រៀន ដើម្បីអាចសម្របបាននូវការប្រើប្រាស់វិធីបង្រៀនផ្សេងៗគ្នា ប្រសិនចាំបាច់ ផ្លាស់ប្តូរវិធីសាស្ត្រដើម្បីឱ្យការសិក្សាបានផលកាន់តែខ្ពស់។

២) គេត្រូវមានបំណិនសម្បូរបែបពីយុទ្ធសាស្ត្របង្រៀន សមត្ថភាពបញ្ចូលគ្នានូវវិធីសាស្ត្របង្រៀនច្រើនបែប និងចំណេះដឹងពីរបៀបនិងនៅពេលណាដែលត្រូវប្រើវិធី និងយុទ្ធសាស្ត្រច្រើនដែលប្រាកដ។ យុទ្ធសាស្ត្រទាំងនេះមានបង្រៀនផ្ទាល់សិស្សម្នាក់ បង្រៀនសិស្សទាំងក្រុម ការសិក្សាស្រាវជ្រាវ ធ្វើការជាក្រុម និងសម្របសម្រួលជួយសិស្សរៀនខ្លួនឯង និងស្រាវជ្រាវខ្លួនឯង។

៣) គ្រូបង្រៀនត្រូវតែមានសមត្ថភាពធ្វើការតាមរបៀបសហប្រតិបត្តិការប្រសើរ ធ្វើការជាមួយគ្រូបង្រៀន អ្នកមានវិជ្ជាជីវៈ និងអ្នកអមវិជ្ជាជីវៈផ្សេងទៀតនៅក្នុងអង្គភាព ឬ ជាមួយបុគ្គលនៅអង្គភាពផ្សេងៗ បណ្តាញនៃសហគមន៍អ្នកមានវិជ្ជាជីវៈ និងការរៀបចំជាកិច្ចសហប្រតិបត្តិការដៃគូផ្សេងៗ ដែលអាចមានការបង្វិកគ្រូធ្វើការងារ។

៤) ចុងក្រោយ តែមិនមែនមានតែប៉ុណ្ណឹងទេ គ្រូបង្រៀនត្រូវតែមានបំណិនបច្ចេកវិទ្យារឹងមាំ និងការប្រើបច្ចេកវិទ្យាជាឧបករណ៍បង្រៀនឱ្យមានប្រសិទ្ធភាព ដោយការប្រើប្រាស់ធនធានឌីជីថល នៅក្នុងការបង្រៀន និងប្រើប្រព័ន្ធព័ត៌មានវិទ្យាតាមដានការសិក្សារបស់សិស្ស។



ជ.២. បរិបទទូទៅ

- បញ្ញត្តិ៖ ស្វែងរក កសាង និងរក្សាធនធានមនុស្សដែលមានការប្តេជ្ញាចិត្ត និងមានសមត្ថភាពក្នុងផែនការយូរអង្វែង
- តម្រូវការ៖ ចំនួនសិស្ស និងបទដ្ឋានជារង្វាស់បង្ហាញពីបរិមាណធនធានមនុស្សត្រូវការ
- សុខភាពហិរញ្ញវត្ថុសាលារៀន៖ ប្រើភាគរយចំណាយសម្រាប់មន្ត្រីដែលធានានូវការរស់នៅមានស្តង់ដាតាមទីផ្សារ និងក្នុងន័យទទួលខុសត្រូវសង្គម។ ផ្សារភ្ជាប់ការលើកទឹកចិត្តនេះជាមួយការអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀន និងការតំឡើងឋានៈ
- គោរពវប្បធម៌និងគុណតម្លៃអនុវិស័យ៖ ផ្តល់តម្លៃបន្ថែមលើប្រាក់បៀវត្សរ៍រដ្ឋដើម្បីរក្សាមន្ត្រីឱ្យនៅបន្តការងារ

ជ.៣. បរិបទកសាងធនធានគ្រូបង្រៀន

- ជ្រើសយកសិស្សមធ្យមសិក្សាដែលមាននិទ្ទេសល្អប្រសើរតាមមុខវិជ្ជា និងជាអ្នកមានបំណងធ្វើជាគ្រូបង្រៀន ឱ្យទៅរៀននៅមហាវិទ្យាល័យដើម្បីមកធ្វើជាគ្រូបង្រៀននៅសាលារៀន
- បន្តបញ្ជូនគ្រូបង្រៀនចូលវគ្គសិក្សាជាប់ជាប្រចាំឆ្នាំដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា សហការណ៍ជាមួយមហាវិទ្យាល័យឬគ្រឹះស្ថានអប់រំដែលមានការទទួលស្គាល់គុណភាព
- គ្រប់គ្រងទិន្នន័យគ្រូបង្រៀនផ្អែមតាមមុខវិជ្ជានិងតាមភូមិសាស្ត្រ រៀបចំឱ្យមានការជួបគ្នារំលែកពិសោធន៍ពីការបង្រៀន ចងក្រងឯកសារបង្រៀន និងសំណួរតេស្តសិស្សនៅក្នុងប្រព័ន្ធព័ត៌មានមានវិទ្យា
- អនុវត្តតេស្តស្តង់ដាជាតិប្រចាំខែ ត្រីមាស និងឆ្នាំ និងឈានទៅកែទម្រង់សំណួរតេស្តប្រឡងថ្នាក់ជាតិសម្រាប់ថ្នាក់ទី៩ និងទី១២។ ធ្វើសមារហនុកម្មការប្រឡងថ្នាក់ទី១២និងការប្រឡងចូលមហាវិទ្យាល័យ។

ជ.៤. បរិបទកសាងធនធាននាយកសាលារៀន

- សម្រាប់នាយកសាលារៀន ជាការប្រសើរ ត្រូវមានប្រព័ន្ធជ្រើសរើសគ្រូបង្រៀន ឬនាយករងដែលមានសក្តានុពលធ្វើជានាយកសារៀន
- គ្រូបង្រៀន ឬនាយករងណាដែលបានទទួលពិន្ទុ៥ ចំនួន៣ដងពីការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ នឹងត្រូវចាត់ទុកថាមានសក្តានុពលធ្វើជានាយកសាលារៀន។ គ្រូបង្រៀន ឬនាយករងទាំងនេះអាចឆ្លងកាត់ការធ្វើតេស្តពីសមត្ថភាព និងចរិយា ប្រសិនបើជាប់តេស្ត នោះនឹងត្រូវចាត់ឱ្យចូលរៀនវគ្គបរិញ្ញាបត្រពីការគ្រប់គ្រងសាលារៀនដែលផ្តល់ដោយមហាវិទ្យាល័យអប់រំ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- ក្រោយបញ្ចប់វគ្គបរិញ្ញាបត្រ គ្រូបង្រៀន ឬនាយករងនេះអាចនឹងត្រូវបានចាត់តាំងជានាយកសាលារៀនពេញសិទ្ធិ។ នាយកសាលារៀនដែលចាត់តាំងថ្មីត្រូវបន្តរៀនសូត្រពីនាយកសាលារៀនចាស់ និងនាយកសាលាលរៀនដែលឆ្នើមនៃសាលារៀនដែលនៅក្បែរ ក្នុងបបរិបទរក្សាគន្លងអាជីព។

ជ.៥. បរិបទកសាងធនធានមនុស្សគោលនយោបាយ ឬអ្នកដឹកនាំផ្តោតលើលទ្ធផល

- ធនធានមនុស្សកម្រិតជាតិគឺត្រូវការអ្នកគោលនយោបាយ និងអ្នកគ្រប់គ្រង
- អ្នកគោលនយោបាយ គឺជាអ្នកដែលមានពិសោធន៍វិជ្ជាជីវៈកម្រិតខ្ពស់ដែលអាចសិក្សាយកពិសោធន៍ពីសកលលោកមកបកស្រាយក្នុងលក្ខណៈប្រតិបត្តិ សម្របទៅតាមតម្រូវការរបស់ប្រទេស និងបូកផ្សំបទពិសោធន៍

ជាក់ស្តែងរបស់ប្រទេស សម្រាប់កសាងគោលនយោបាយនិងសេចក្តីណែនាំមានលក្ខណៈប្រតិបត្តិ ហើយដែលជួយដល់សាលារៀនអាចយកគោលនយោបាយនិងសេចក្តីណែនាំទៅអនុវត្តបាន។ អ្នកគោលនយោបាយប្រភេទនេះត្រូវឆ្លងកាត់ជាក់ស្តែងក្នុងការអនុវត្តកម្មវិធីកំណែទម្រង់របស់រដ្ឋ បង្ហាញនូវភាពជោគជ័យកើតមាននៅសាលារៀន និងឆ្លងកាត់ការសិក្សាទទួលបាននូវសញ្ញាបត្រក្រោយបរិញ្ញាបត្រ ឬវគ្គសិក្សាក្រោយបរិញ្ញាបត្រពីការធ្វើផែនការនិងការវិភាគគោលនយោបាយ

- របៀបស្វែងរក កសាង និងរក្សាអ្នកគោលនយោបាយ
- អ្នកមានសក្តានុពលក្លាយជាអ្នកគោលនយោបាយត្រូវបានថ្នាក់ដឹកនាំក្រសួងទទួលស្គាល់ហើយ ដូចនេះគប្បីបន្តធ្វើកិច្ចការចំនួនពីរគឺ ១) បន្តរៀនសូត្រពីការអនុវត្តការងារ សិក្សាពីការផ្លាស់ប្តូរនៅលើសកលលោកទាក់ទងនឹងវិស័យអប់រំ និងយកពិសោធន៍របស់ខ្លួនទៅបង្រៀនដល់មន្ត្រីដែលត្រូវការនូវពិសោធន៍នេះ និង ២) រៀននៅសាលាដើម្បីទទួលបាននូវសញ្ញាបត្រកម្រិតបណ្ឌិតដែលពិតប្រាកដ និងព្រមពេលជាមួយគ្នានូវការកសាងគោលនយោបាយ និងសេចក្តីណែនាំប្រតិបត្តិ និងបន្តបង្រៀននិងកសាងសមត្ថភាពមន្ត្រីរហូត។ ពីការធ្វើកិច្ចការទាំងនេះ នាំឱ្យការកំណត់ទិសក្រុមប្រឹក្សាភិបាលស្ថាប័ន អាចក្លាយជាការពិតបាន ពោលគឺជាការនាំឱ្យប្រព័ន្ធគ្រប់គ្រងរដ្ឋបាលទាំងអស់ដើរដោយមានភាពឥតខ្ចោះ។ នេះជាគុណតម្លៃដែលមន្ត្រីប្រភេទនេះនឹងទទួលបានដោយការកសាងវាដោយខ្លួនឯង ហើយវានឹងរក្សាឱ្យមន្ត្រីនេះនៅបន្តការងាររហូត ព្រោះគាត់យល់ថាអ្វីដែលគាត់ធ្វើគឺដើម្បីបម្រើប្រយោជន៍សង្គម។

### ៨.៦. បរិបទកសាងធនធានមនុស្សជាអ្នកគ្រប់គ្រង

អ្នកគ្រប់គ្រងរដ្ឋបាលជាអ្នកដែលមានសមត្ថភាពធ្វើឱ្យប្រព័ន្ធមួយមានដំណើរការ និងធ្វើឱ្យប្រព័ន្ធទាំងអស់មានដំណើរការផ្សារភ្ជាប់គ្នា។ ប្រព័ន្ធគ្រប់គ្រងទាំងនេះមាន ការធ្វើផែនការគោលនយោបាយ ការផលិតនិងអនុវត្តកម្មវិធីវិនិយោគ ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងធនធានមនុស្ស ការពិនិត្យតាមដាននិងវាយតម្លៃ ប្រព័ន្ធធានាគុណភាពអប់រំ ។ល។ អ្នកគ្រប់គ្រងប្រភេទនេះត្រូវមានសមត្ថភាពវិជ្ជាជីវៈកម្រិតខ្ពស់ ឆ្លងកាត់ការសិក្សារៀនសូត្រជារៀងរហូត ការអនុវត្តប្រព័ន្ធតាមភាពជាក់ស្តែង និងការសិក្សាទទួលបាននូវបរិញ្ញាបត្រជំនាញតាមមុខប្រព័ន្ធ។ របៀបកសាង ស្វែងរក កសាងនិងរក្សាអ្នកមានសក្តានុពលក្លាយជាអ្នកគ្រប់គ្រងរដ្ឋបាលវិជ្ជាជីវៈគឺ មាននៅកម្រិតក្រសួង មន្ទីរអប់រំរាជធានីនិងខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក និងខណ្ឌ។ ដូចនេះក្រសួងមានតួនាទី ១) សហការជាមួយសាកលវិទ្យាល័យស្វែងរកនិស្សិតដែលមានសមត្ថភាពគ្រឹះក្លាយជាអ្នកដឹកនាំ និងបង្វឹកគេឱ្យចេះធ្វើកិច្ចការរដ្ឋបាលនិងគ្រប់គ្រង ២) សម្របសម្រួលឱ្យមន្ត្រីមានសក្តានុពលទាំងនេះមករៀនយកបរិញ្ញាបត្រគ្រប់គ្រងសាលារៀនកម្រិតបរិញ្ញាបត្រ និងផ្តល់លទ្ធភាពដល់មន្ត្រីទាំងនេះអាចអនុវត្តនៅមូលដ្ឋានជួយដល់សាលារៀនឱ្យបំពេញបាននូវស្តង់ដាសាលារៀនមានប្រសិទ្ធភាព និងបន្តឱ្យទទួលបានការរៀនសូត្រទទួលបានសញ្ញាបត្រអនុបណ្ឌិតពីការគ្រប់គ្រងសាលារៀន និងផ្តល់លទ្ធភាពឱ្យគាត់ជួយសាលារៀនឱ្យមានស្តង់ដានៅក្នុងរាជធានី ខេត្ត និងប្រទេសបាន និង ៣) សម្របសម្រួលមន្ត្រីមានសក្តានុពលកម្រិតក្រសួងនិងមន្ទីរអប់រំ យុវជន និងកីឡា បានរៀនវគ្គសិក្សានៅសាកលវិទ្យាល័យមានគុណភាពកម្រិតអន្តរជាតិ ដើម្បីមានសមត្ថភាពវិជ្ជាជីវៈលើការអនុវត្តប្រព័ន្ធគ្រប់គ្រងនីមួយៗ និងធានាបាននូវដំណើរការប្រព័ន្ធគ្រប់គ្រងប្រព្រឹត្តទៅមានភាពផ្សារភ្ជាប់គ្នាដោយឥតខ្ចោះ។

# ជំពូក៥
# ប្រព័ន្ធផ្តល់ថាមពលការងារកសាងនិងរក្សាគុណតម្លៃដើម្បីធានានិរន្តរភាព

## ក. ប្រព័ន្ធគ្រប់គ្រងការអនុវត្តការងារមន្ត្រី

ក.១. ទស្សនៈវិស័យ (ការដឹកនាំ)

ប្រសិនបើសកម្មភាពរបស់អ្នកនាំបណ្តុះជំហរអ្នកដ៏ទៃឱ្យមានសុបិនកាន់តែច្រើន រៀនសូត្រកាន់តែច្រើន ធ្វើកាន់តែច្រើន ក្លាយទៅជាមនុស្សដែលថ្មីរហូត ពេលនោះអ្នកគឺជាអ្នកដឹកនាំហើយ។

**វត្ថុបំណងនិងការទទួលខុសត្រូវៈ**

- កម្មវិធីកំណែទម្រង់មានបំណងធ្វើឱ្យមានវឌ្ឍនភាព ដូចនេះការងារត្រូវធ្វើតាមរបៀបថ្មី
- អ្នកដឹកនាំទទួលខុសត្រូវចំពោះតម្រូវការរបស់មន្ត្រី ដូចនេះអ្នកដឹកនាំត្រូវជួយមន្ត្រីបំពេញសមត្ថភាពដែលនៅខ្វះចន្លោះ ដើម្បីធ្វើការងារតាមរបៀបថ្មី
- អ្នកដឹកនាំត្រូវរក្សាថាមពលធ្វើការងាររបស់មន្ត្រី ដូចនេះអ្នកដឹកនាំធានានូវការរក្សាគុណតម្លៃការងាររបស់មន្ត្រីដោយមិនមានភាពលម្អៀងផ្អែកលើលទ្ធផលការងារ
- អ្នកដឹកនាំមិនមានបំណងស្វែងរកកំហុសរបស់មន្ត្រីទេ តែមានបំណងផ្តល់ឱកាសឱ្យមន្ត្រីអភិវឌ្ឍខ្លួន និងបង្កើននូវការទទួលស្គាល់តម្លៃការងាររបស់មន្ត្រី

ក.២. គោលការណ៍និងដំណាក់ការអនុវត្តកិច្ចការនេះ

**គោលការណ៍ៈ** «ការស្ម័គ្រចិត្តចូលរួមរបស់មន្ត្រី» និង «ការរក្សាការសម្ងាត់» នឹងត្រូវរក្សាឱ្យបាន មិនគប្បីបង្ខំឱ្យមន្ត្រីចូលរួមឡើយ។

**ដំណាក់ការអនុវត្តៈ**

១) ការរៀបចំកិច្ចសន្យាលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈ
២) ការវាយតម្លៃការអនុវត្តពាក់កណ្តាល ឆ្នាំ
៣) ការវាយតម្លៃការអនុវត្តចុងឆ្នាំ

| **កិច្ចការជាលំដាប់សម្រាប់អនុវត្តប្រព័ន្ធគ្រប់គ្រងនិងវាយតម្លៃការបំពេញការងាររបស់មន្ត្រី ដំណើរការអនុវត្ត** |
|---|
| ១. មន្ត្រីម្នាក់ៗព្រាងកិច្ចសន្យាលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈ |
| ២. មន្ត្រីម្នាក់ៗ និងប្រធាននាយកដ្ឋានពិភាក្សានិងឯកភាពលើកិច្ចសន្យាលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈ |
| ៣. មន្ត្រីម្នាក់ៗ និងប្រធាននាយកដ្ឋានពិភាក្សាពីការពិនិត្យឡើងវិញពាក់កណ្តាលឆ្នាំ/ឆមាស |
| ៤. មន្ត្រីម្នាក់ៗ និងប្រធាននាយកដ្ឋានពិភាក្សា និងឯកភាពថាតើមន្ត្រីណាជាដៃគូពិនិត្យឡើងវិញ |
| ៥. មន្ត្រីម្នាក់ៗ ព្រាងនូវលទ្ធផលសម្រេចបានប្រចាំឆ្នាំធៀបជាមួយកិច្ចសន្យាលទ្ធផលប្រចាំឆ្នាំនិងផែនការអភិវឌ្ឍវិជ្ជាជីវៈ និងបញ្ជូនវាទៅដៃគូពិនិត្យឡើងវិញ |

| |
|---|
| ៦. ដៃគូពិនិត្យឡើងវិញ និងផ្ដល់នូវការយល់ឃើញជាលាយលក្ខណ៍អក្សរទៅប្រធាននាយកដ្ឋាន តែមិនផ្ដល់ឱ្យមន្ត្រីទេ |
| ៧. ប្រធាននាយកដ្ឋានពិភាក្សាជាមួយមន្ត្រីកំណត់ថ្ងៃប្រជុំ |
| ៨. ប្រធាននាយកដ្ឋានពិភាក្សាជាមួយមន្ត្រីដើម្បីវាយតម្លៃការអនុវត្តរបស់មន្ត្រី ដោយផ្អែកលើការយល់ឃើញដែលបានពីដៃគូពិនិត្យឡើងវិញ និងធ្វើសេចក្ដីព្រាងលទ្ធផលវាយតម្លៃរបស់មន្ត្រី |
| ៩. ប្រធាននាយកដ្ឋានផ្ដល់ពិន្ទុវាយតម្លៃដល់មន្ត្រីម្នាក់ៗ |
| ១០. ប្រធាននាយកដ្ឋានដាក់ស្នើលទ្ធផលពីការវាយតម្លៃដល់អគ្គនាយក ឬ អគ្គនាយករងទទួលបន្ទុកដើម្បីពិនិត្យព្រមព្រៀងនិងសម្រេច |
| ១១. អគ្គនាយកឬអគ្គនាយករងព្រមព្រៀង និងសម្រេច រួចបញ្ជូនទៅរដ្ឋមន្ត្រី ដើម្បីផ្ដល់រង្វាន់ ឬ អនុវត្តវិធានការណ៍រដ្ឋបាល |

**ការស្វែងរកការស្ម័គ្រចិត្តចូលរួម**

- ការប្រជុំនៅក្នុងឆ្នាំ២០២១ ប្រធាននាយកដ្ឋានរៀបចំការប្រជុំជាមួយមន្ត្រីទាំងអស់ ដើម្បីជូនព័ត៌មានពីប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់មន្ត្រី (ការដឹកនាំ វត្ថុបំណងនិងការទទួលខុសត្រូវ គោលការណ៍ ដំណាក់កាលអនុវត្តនិងដំណើរការអនុវត្ត)។
- ប្រធាននាយកដ្ឋានសាកសួរ និងកត់ឈ្មោះមន្ត្រីដែលស្ម័គ្រចិត្តចូលរួមអនុវត្តប្រព័ន្ធ និងសុំមន្ត្រីចុះហត្ថលេខាដើម្បីទុកជាឯកសារ។

**តួនាទី និងកិច្ចការត្រូវធ្វើ**

**មុខងារធំៗតាមរចនាសម្ព័ន្ធ**

| **រចនាសម្ព័ន្ធ** | **មុខងារធំៗ** |
|---|---|
| គណៈកម្មការគ្រប់គ្រងអនុវិស័យ | សម្រេចយុទ្ធសាស្ត្រ និងរកមូលនិធិ |
| អគ្គនាយកដ្ឋានអប់រំ និងអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | អនុវត្តយុទ្ធសាស្ត្រ |
| នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ | អនុវត្តកម្មវិធីវិនិយោគ |
| ការិយាល័យ នៃនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ | អនុវត្តស្តង់ដាកម្មវិធីវិនិយោគ |
| មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត | អនុវត្តការផ្ដល់ធាតុចូល និងពង្រីកការអនុវត្តយុទ្ធសាស្ត្រសាលារៀន |
| ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក ខ័ណ្ឌ | សម្របសម្រួលការផ្ដល់ធាតុចូល និងការអនុវត្តយុទ្ធសាស្ត្រសាលារៀន |
| គ្រឹះស្ថានមធ្យមសិក្សា | អនុវត្តយុទ្ធសាស្ត្រសាលារៀន |

**កិច្ចការត្រូវធ្វើ**

| យុទ្ធសាស្ត្រ | តួនាទី |
|---|---|
| ផ្តល់ស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុដល់សាលារៀនសហគមន៍ | អគ្គនាយករងទទួលបន្ទុក នៃអគ្គនាយកដ្ឋានអប់រំ |
| បង្កើតនិងអនុវត្តកម្មវិធីធានាគាំទ្រសង្គម និងអភិវឌ្ឍសមត្ថភាពជាប្រចាំសម្រាប់គ្រូបង្រៀននិងនាយកសាលារៀន | |
| សហការជាមួយមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងមន្ត្រីអប់រំដែលធានាថាថ្នាក់រៀនមានដំណើរការសម្រាប់ការសិក្សារបស់សិស្សម្នាក់ៗ | អគ្គនាយករង នៃអគ្គនាយកដ្ឋាន គោលនយោបាយ និងផែនការ |
| អនុវត្តកម្មវិធីបំណិនរកចំណូលធានាសិស្សរៀនមានសមត្ថភាពសម្រាប់ជីវិត រកចំណូល និងការសិក្សានៅឧត្តមសិក្សា | |
| បង្កើតកម្មវិធីប្រកួតប្រជែងសមត្ថភាពសិស្សរវាងសាលារដ្ឋ និងសាលាឯកជន | ប្រធាននាយកដ្ឋាន មធ្យមសិក្សាចំណេះទូទៅ |

រដ្ឋមន្ត្រីជាអ្នកសម្រេចលើកិច្ចព្រមព្រៀងលទ្ធផល វាយតម្លៃពាក់កណ្តាលឆ្នាំ និងចុងឆ្នាំសម្រាប់ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន និង ប្រធានមន្ទីរអប់រំ យុវជន និងកីឡា។ ដោយឡែក ប្រធាននាយកដ្ឋាន ជាអ្នកសម្រេចលើកិច្ចព្រមព្រៀងលទ្ធផល វាយតម្លៃពាក់កណ្តាលឆ្នាំ និងចុងឆ្នាំសម្រាប់ អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងមន្ត្រីការិយាល័យទាំងអស់។

ការសម្រេចលើកិច្ចព្រមព្រៀងជាមួយឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី




ការសម្រេចលើកិច្ចព្រមព្រៀងជាមួយប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ



រចនាសម្ព័ន្ធកម្រិតការិយាល័យ




រចនាសម្ព័ន្ធគ្រប់គ្រងក្រុមការងារតំបន់



ក.៣. ការផលិតកិច្ចសន្យាលទ្ធផលប្រចាំឆ្នាំរបស់មន្ត្រី

- ប្រធាននាយកដ្ឋានណែនាំពីការផលិតកិច្ចសន្យាលទ្ធផលប្រចាំឆ្នាំដល់មន្ត្រី។
- បង្ហាញពីស្តង់ដាកម្មវិធី និងតារាងដែលមានកូឡោន ៣ បន្ថែមនៅខាងស្តាំដៃ (មានសមត្ថភាព មិនមានសមត្ថភាព សុំស្នើរៀនសូត្រ) ពន្យល់ពីការបំពេញតាមបន្ទាត់កិច្ចការនីមួយៗ ហើយឱ្យមន្ត្រីបំពេញតារាងក្នុងពេលជាមួយគ្នា។
- មន្ត្រីបំពេញតារាង ដោយគូសសញ្ញា (√) នៅកូឡោនណាមួយនៃកូឡោនទាំង៣ខាងលើ។
- បន្ទាប់មក ប្រធាននាយកដ្ឋានបង្ហាញទម្រង់កិច្ចសន្យាលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈ និងពន្យល់មន្ត្រីពីការបំពេញទម្រង់កិច្ចសន្យា ហើយមន្ត្រីម្នាក់ៗបំពេញទម្រង់ទៅតាមការណែនាំ។ មន្ត្រីអាចសួរពីការបំពេញទម្រង់តាមតម្រូវការរបស់មន្ត្រីម្នាក់ៗ។ ឧទាហរណ៍ពីការសរសេរមាននៅទម្រង់ខាងក្រោម។
- មន្ត្រីម្នាក់ៗ និងប្រធាននាយកដ្ឋានពិភាក្សាគ្នាលើពង្រាងកិច្ចសន្យាលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍសមត្ថភាព។ មន្ត្រីកែតម្រូវកិច្ចសន្យាតាមលទ្ធផលនៃការពិភាក្សាដែលបានឯកភាពគ្នា។
- ប្រធាននាយកដ្ឋានព្រមព្រៀងនិងអនុម័តលើកិច្ចសន្យា ដោយមានការចុះហត្ថលេខាពីមន្ត្រី និងប្រធាននាយកដ្ឋាន។
- ការកំណត់លទ្ធផលត្រូវគិតដោយប្រយ័ត្នប្រយែងដោយផ្អែកលើថា អាចផលិតនិងធ្វើបាន តែមិនតិចពេកដែលនាំឱ្យមិនអាចសម្រេចបាននូវក្រុមគោលដៅសូចនាករ។

**ទម្រង់កិច្ចសន្យាលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់មន្ត្រី**

| |
|---|
| **ឈ្មោះ** .............................................. **ភេទ** ☐ **ប្រុស** ☐ **ស្រី** **មុខវិជ្ជាឯកទេស** ................................<br>**ឈ្មោះប្រធាននាយកដ្ឋានៈ** ................................................. **ថ្ងៃខែឆ្នាំអនុម័ត** ............................................ |
| *សំណុំទី១*<br>**វត្ថុបំណង ( ស្តង់ដាទី១ )៖**<br>**លទ្ធផលៈ**<br>ផលិតបាននូវ<br>**សកម្មភាពៈ**<br>រៀបចំ |
| **សំណុំទី២ៈ**<br>វត្ថុបំណង (ស្តង់ដាទី២)៖<br>**លទ្ធផលៈ**<br>**ផលិតបាននូវ**<br>**សកម្មភាពៈ** |

| |
|---|
| **សំណុំទី៣៖**<br>**វត្ថុបំណង ( ស្តង់ដាទី៣ )៖**<br>**លទ្ធផល៖**<br>**សកម្មភាព៖** |
| សំណុំទី៤៖<br>វត្ថុបំណង (ផែនការអភិវឌ្ឍវិជ្ជាជីវៈ៖ បង្កើនគុណវុឌ្ឍិ ឬបំប៉ន)<br>រៀនបំពេញគម្លាតចំណេះដឹងនិងបំណិន?<br>លទ្ធផល៖<br>សកម្មភាព៖ |

## ខ. ការវាយតម្លៃការងារមន្ត្រី

កិច្ចការវាយតម្លៃនេះមានសារៈសំខាន់ណាស់ ដូចនេះត្រូវអនុវត្តកិច្ចការនេះឱ្យបានត្រឹមត្រូវតាមការណែនាំ។ សារៈសំខាន់ទទួលបានសម្រាប់មន្ត្រីជាបុគ្គលម្នាក់ៗ គឺ រៀនសូត្រកសាងភាពស្មោះត្រង់ជាមួយនឹងការពិតរបស់បុគ្គលខ្លួនឯងក្នុងរយៈពេលបំពេញការងារ ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប់ជាប្រចាំ ការរក្សាបាននូវគុណតម្លៃបុគ្គលដោយសារបានគោរពនូវវប្បធម៌អង្គភាពនិងគុណតម្លៃរួម។ សារៈសំខាន់ទទួលបានសម្រាប់អង្គភាពគឺ ភាពសម្បូរបែបនៃធនធានមនុស្សមានសមត្ថភាព និងសុទ្ធតែជាមន្ត្រីល្អៗ នាំសេវាសាធារណៈបំពេញបាននូវតម្រូវការប្រសើរបំផុតសម្រាប់សិស្សនិងប្រជាជន និងប្រើធនធានគ្រប់ប្រភពមានប្រសិទ្ធភាព។

### ខ.១. ការអនុវត្តការវាយតម្លៃពាក់កណ្តាលឆ្នាំ

*ដំណើរនៃការវាយតម្លៃការអនុវត្តការងារពាក់កណ្តាលឆ្នាំ*

**វត្ថុបំណង៖**

ពិនិត្យនិងព្រមព្រៀងលើលទ្ធផលវាយតម្លៃ និងកំណត់កិច្ចការត្រូវធ្វើពីពាក់កណ្តាល ដល់ចុងឆ្នាំ។ អនុវត្តនៅពេលចប់ឆមាសទី១។

**កិច្ចការមុនពេលវាយតម្លៃ៖**

ប្រធាននាយកដ្ឋាននិងមន្ត្រីកំណត់ថ្ងៃនិងម៉ោងជួបពិភាក្សា មន្ត្រីសរសេរពី៖

១) កិច្ចការបានអនុវត្តនិងលទ្ធផលសម្រេចបានតាមកិច្ចព្រមព្រៀងលទ្ធផលឆ្នាំ

២) កិច្ចការឬលទ្ធផលដែលសម្រេចបានតែមិនមាននៅក្នុងកិច្ចកព្រមព្រៀងលទ្ធផលឆ្នាំ

៣) កិច្ចការឬលទ្ធផលដែលត្រូវផ្តោតពីពាក់កណ្តាលដល់ចុងឆ្នាំ និង

៤) កិច្ចការលំបាកឬត្រូវការប្រធាននាយកដ្ឋានជួយគាំទ្រ។

**ការពិភាក្សាវាយតម្លៃការអនុវត្តការងារពាក់កណ្តាលឆ្នាំ៖**

ប្រធាននាយកដ្ឋានផ្តើមការប្រជុំដោយបញ្ជាក់ពីវត្ថុបំណងនៃការជួបពិភាក្សា មន្ត្រីរាយការណ៍ខ្លឹមសារដែលបានត្រៀមខាងដើម ពិភាក្សាដើម្បីស្វែងរកការព្រមព្រៀងគ្នាលើការរាយការណ៍របស់មន្ត្រី ប្រធាននាយកដ្ឋានកំណត់ធ្វើកិច្ចការជាក់លាក់ជួយដល់កិច្ចការលំបាករបស់មន្ត្រី កិច្ចការ ឬលទ្ធផលត្រូវធ្វើនៅពាក់កណ្តាលចុងឆ្នាំ ប្រធាននាយកដ្ឋានអាចស្នើដល់មន្ត្រីឱ្យជួយកិច្ចការសំខាន់ៗក្នុងអង្គភាពឬការិយាល័យផ្សេងទៀតតាមសមត្ថភាពនិងពិសោធន៍ការងាររបស់មន្ត្រី។ កែសម្រួលកិច្ចព្រមព្រៀងរបស់មន្ត្រី។

**កិច្ចការបញ្ចប់ការវាយតម្លៃ៖**

មន្ត្រីនិងប្រធាននាយកដ្ឋានចុះហត្ថលេខាលើក្រដាសដែលបានព្រាងក្រោយពីការពិភាក្សា។

ទម្រង់កំណត់ហេតុវាយតម្លៃពាក់កណ្តាលឆ្នាំសម្រាប់មន្ត្រី

<table>
<tr><td colspan="2">ឈ្មោះមន្ត្រី ...................................................... ឈ្មោះប្រធាននាយកដ្ឋាន.............................................<br>(ហត្ថលេខា) ...................................................... (ហត្ថលេខា)...............................................................<br>ថ្ងៃខែឆ្នាំប្រជុំ៖...................................................................................................................................</td></tr>
<tr><td colspan="2">ការរីកចម្រើនបញ្ជាក់ថាលទ្ធផលនិងសកម្មភាពដែលបានសម្រេចហើយ៖<br><br>លទ្ធផលនិងសកម្មភាពដែលមិនទាន់បានសម្រេច៖</td></tr>
<tr><td>បញ្ហាដែលត្រូវការនូវការយកចិត្តទុកដាក់ដោយមន្ត្រី៖</td><td>បញ្ហាដែលត្រូវយកចិត្តទុកដាក់ដោយប្រធាននាយកដ្ឋាន៖</td></tr>
<tr><td>សកម្មភាពដែលត្រូវធ្វើដោយមន្ត្រី៖</td><td>សកម្មភាពដែលត្រូវធ្វើដោយប្រធាននាយកដ្ឋាន៖</td></tr>
</table>

ទម្រង់កំណត់ហេតុវាយតម្លៃពាក់កណ្ដាលឆ្នាំសម្រាប់ប្រធាននាយកដ្ឋាន

<table>
<tr><td colspan="2">ឈ្មោះប្រធាននាយកដ្ឋាន........................................ ឈ្មោះឯកឧត្តមរដ្ឋមន្ត្រី..........................................<br>(ហត្ថលេខា) .................................................... (ហត្ថលេខា).........................................................<br>ថ្ងៃខែឆ្នាំប្រជុំ៖..........................................................................................................................</td></tr>
<tr><td colspan="2">ការរីកចម្រើនបញ្ជាក់ថាលទ្ធផលនិងសកម្មភាពដែលបានសម្រេចហើយ៖<br><br>លទ្ធផលនិងសកម្មភាពដែលមិនទាន់បានសម្រេច៖</td></tr>
<tr><td>បញ្ហាដែលត្រូវការនូវការយកចិត្តទុកដាក់ដោយប្រធាននាយកដ្ឋាន៖</td><td>បញ្ហាដែលត្រូវការនូវការយកចិត្តទុកដាក់ដោយរដ្ឋមន្ត្រី៖</td></tr>
<tr><td>សកម្មភាពដែលត្រូវធ្វើដោយប្រធាននាយកដ្ឋាន៖</td><td>សកម្មភាពដែលត្រូវធ្វើដោយរដ្ឋមន្ត្រី៖</td></tr>
</table>

៩.២. ការអនុវត្តការវាយតម្លៃចុងឆ្នាំ

| **ដំណើរការវាយតម្លៃ៖** |
|---|
| ១. មន្ត្រី ព្រមព្រៀងជាមួយប្រធាននាយកដ្ឋាននូវថ្ងៃខែ និង ម៉ោងជួបពិភាក្សា |
| ២. មន្ត្រីស្នើដល់ប្រធាននាយកដ្ឋានពីមន្ត្រីជាអ្នកផ្តល់ចម្លើយត្រឡប់ទៅប្រធាននាយកដ្ឋានពីការអនុវត្តការងាររបស់ខ្លួន ហើយប្រធាននាយកដ្ឋានពិនិត្យ ស្នើសុំប្តូរឬបន្ថែមអ្នកផ្តល់ចម្លើយត្រឡប់ និងព្រមព្រៀងជាមួយមន្ត្រីពីអ្នកដែលត្រូវផ្តល់ចម្លើយត្រឡប់ |
| ៣. មន្ត្រីសរសេរពីលទ្ធផលសម្រេចបានក្នុងឆ្នាំ ប្រសិនបើមានលទ្ធផលផ្សេងទៀតសម្រេចបានលើសពីកិច្ចព្រមព្រៀងត្រូវសរសេរបញ្ចូលដែរ |
| ៤. ប្រធាននាយកដ្ឋាននិង មន្ត្រីជួបពីភាក្សានិងព្រមព្រៀងគ្នាពី ការសម្រេចលទ្ធផលការងាររបស់មន្ត្រីដែលមានសរសេរនៅក្នុងរបាយការណ៍ |
| ៥. ប្រធាននាយកដ្ឋានសរសេរកថាខណ្ឌខ្លីពីការសម្រេចលទ្ធផលការងាររបស់មន្ត្រី ផ្តល់ឱ្យមន្ត្រីពិនិត្យ កែសម្រួលបើត្រូវការ ឬបញ្ជាក់ថាបានព្រមព្រៀងហើយ |
| ៦. ប្រធាននាយកដ្ឋាន និង មន្ត្រីចុះហត្ថលេខាលើកថាខណ្ឌដែលបានព្រមព្រៀងគ្នា |
| ៧. ប្រធាននាយកដ្ឋានបញ្ជូនកថាខណ្ឌ និង របាយការណ៍វាយតម្លៃដែលបានព្រមព្រៀងគ្នាទៅអគ្គនាយកពិនិត្យនិងអនុម័ត |
| ៨. អគ្គនាយកឬរង និង ប្រធាននាយកដ្ឋានពិភាក្សាពីការវាយតម្លៃការអនុវត្តការងាររបស់មន្ត្រី និងកំណត់ពិន្ទុវាយតម្លៃ និង រង្វាន់ដែលត្រូវផ្តល់ |

ទម្រង់កំណាត់ហេតុវាយតម្លៃចុងឆ្នាំសម្រាប់មន្ត្រី

| **ឈ្មោះមន្ត្រី** ................................................... **ឈ្មោះប្រធាននាយកដ្ឋាន**............................................ <br> **ថ្ងៃខែឆ្នាំប្រជុំ៖**.................................................................................................................... |
|---|
| សំណុំទី១ ស្តង់ដាទី១ លទ្ធផលសម្រេចបាន៖ |
| សំណុំទី២ ស្តង់ដាទី១ លទ្ធផលសម្រេចបាន៖ |
| សំណុំទី៣ ស្តង់ដាទី១ លទ្ធផលសម្រេចបាន៖ |

| |
|---|
| សំណុំទី៤ ការអភិវឌ្ឍវិជ្ជាជីវៈ លទ្ធផលសម្រេចបាន៖ |
| លទ្ធផលក្នុងកិច្ចព្រមព្រៀងលទ្ធផលប្រចាំដែលសម្រេចមិនបាន៖<br>លទ្ធផលសម្រេចបានដែលមិនមាននៅក្នុងកិច្ចកព្រមព្រៀង៖ |
| **ហត្ថលេខាប្រធាននាយកដ្ឋាន** ................................................... **ហត្ថលេខាមន្ត្រី** ............................................................. |

**ទម្រង់កំណត់ហេតុវាយតម្លៃចុងឆ្នាំសម្រាប់ប្រធាននាយកដ្ឋាន**

| |
|---|
| **ឈ្មោះប្រធានាយកដ្ឋាន**....................................... **ឈ្មោះឯកឧត្តមរដ្ឋមន្ត្រី**............................................<br>**ថ្ងៃខែឆ្នាំប្រជុំ**:........................................................................................................................................ |
| សំណុំទី១ ស្តង់ដាទីXX៖ លទ្ធផលសម្រេចបាន៖ |
| សំណុំទី២ យុទ្ធសាស្រ្តសម្រេចបាន៖ |
| សំណុំទី៣ យុទ្ធសាស្រ្តសម្រេចបាន៖ |
| សំណុំទី៤ ការអភិវឌ្ឍវិជ្ជាជីវៈ លទ្ធផលសម្រេចបាន៖ |
| លទ្ធផលក្នុងកិច្ចព្រមព្រៀងលទ្ធផលប្រចាំដែលសម្រេចមិនបាន៖ |
| **ហត្ថលេខារដ្ឋមន្ត្រី** .................................................. ...... **ហត្ថលេខា ប្រធាននាយកដ្ឋាន** ............................................................. |

កថាខណ្ឌវាយតម្លៃពីលទ្ធផលសម្រេចបានប្រចាំឆ្នាំព្រមព្រៀងគ្នាសម្រាប់មន្ត្រី

- ឃ្លាមួយឬពីរ ពីការសម្រេចផលសម្រេច
- ឃ្លាមួយឬពីរ ពីការសម្រេចលទ្ធផលក្នុងឆ្នាំ

- ឃ្លាមួយឬពីរ ពីលទ្ធផលនៅសាលារៀនទទួលបន្ទុកដែលខ្លួនបានជួយ
- ឃ្លាមួយឬពីរ ពីការសិក្សារៀនសូត្រជាប់ជាបន្តក្នុងការអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួន និងជួយអភិវឌ្ឍវិជ្ជាជីវៈដល់មន្ត្រីដទៃទៀត

កថាខណ្ឌវាយតម្លៃពីលទ្ធផលសម្រេចបានប្រចាំឆ្នាំព្រមព្រៀងគ្នាសម្រាប់ប្រធាននាយកដ្ឋាន

- ឃ្លាមួយឬពីរ ពីការសម្រេចផលសម្រេចទាក់ទងយុទ្ធសាស្ត្រនិងស្តង់ដាសាលារៀន
- ឃ្លាមួយឬពីរ ពីការដឹកនាំនិងគ្រប់គ្រងនាយកដ្ឋាន និង នាយកដ្ឋានដទៃទៀត
- ឃ្លាមួយឬពីរ ពីការធ្វើឱ្យទទួលបាននូវធាតុចូលពីគ្រប់មជ្ឈដ្ឋានដល់អនុវិស័យនិងនាយកដ្ឋាន
- ឃ្លាមួយឬពីរ ពីការសិក្សារៀនសូត្រជាប់ជាបន្តក្នុងការអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួន និងជួយអភិវឌ្ឍវាជ្ជាជីវៈដល់ប្រធាននាយកដ្ឋានផ្សេងទៀត

ការផ្តល់ពិន្ទុ

| លទ្ធផល | កម្រិតពិន្ទុ |
|---|---|
| សម្រេចផលសម្រេច គ្រប់លទ្ធផលគ្រោង និងលើសផែនការ | ៥ |
| សម្រេចគ្រប់លទ្ធផលគ្រោងទាំងអស់ | ៤ |
| សម្រេចលើ៦០% ដល់ ៨៥%នៃលទ្ធផលគ្រោង | ៣ |
| សម្រេចពី៥០% ទៅត្រឹម ៦០% នៃលទ្ធផលគ្រោង | ២ |
| សម្រេចទាបជាង៥០% នៃលទ្ធផលគ្រោង | ១ |

សម្គាល់

- មន្ត្រីមានពិន្ទុ១ ឬ ២ មិនបង្ហាញគណនេយ្យភាពឡើយ ផ្តល់ឱកាសឱ្យ១ឆ្នាំបន្ត បើមិនមានការរីកចម្រើន ត្រូវស្នើទៅប្រធាននាយកដ្ឋានមានវិធានការណ៍រដ្ឋបាល
- មន្ត្រីមានពិន្ទុ៣ ផ្តល់ឱកាស២ឆ្នាំសម្រាប់កែលម្អ និងឱកាសរៀនសូត្រ
- មន្ត្រីមានពិន្ទុ៤ ជាកម្រិតដែលអាចទទួលរង្វាន់កម្រិតមធ្យម តែមន្ត្រីមានពិន្ទុ៥ ជាមន្ត្រីឆ្នើម ត្រូវទទួលរង្វាន់ដែលប្រសើរ

បរិបទនៃការផ្តល់រង្វាន់

ប្រភេទរង្វាន់ប្រចាំឆ្នាំពីការអនុវត្តប្រព័ន្ធវាយតម្លៃនេះ អាចមានដូចជា៖

- ការដំឡើងបរិមាណប្រាក់ឧបត្ថម្ភពីសាលាលរៀនដែលខ្លួនទទួលបន្ទុក ទៅតាមភាគរយនៃបរិមាណប្រាក់ចំណេញពីការអនុវត្តកម្មវិធីបំណិនរកចំណូលនៅសាលារៀន។ មន្ត្រីដែលអាចត្រូវបានចាត់តាំងឱ្យចុះជួយសាលារៀនត្រូវតែជាអ្នកដែលបានរៀនចប់នូវវគ្គបរិញ្ញាបត្រការគ្រប់គ្រងសាលារៀន ឬបរិញ្ញាបត្របង្រៀនពីមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ឬគ្រឹះស្ថានអប់រំដែលមានការទទួលស្គាល់។

- ការដំឡើងឋានៈមន្ត្រីរាជការ ទៅតាមច្បាប់របស់រដ្ឋ។
- វត្ថុតាងថ្លែងអំណរគុណចំពោះមន្ត្រីបានបំពេញការងាររយៈពេល១០ឆ្នាំ ២០ឆ្នាំ។

## គ. ការអភិវឌ្ឍគន្លងអាជីព

**ដំណើរការនៃការអនុវត្តកិច្ចការនេះ**

គន្លងអាជីពគប្បីមានតែ៣កម្រិតសម្រាប់ឋានានុក្រមនីមួយៗ៖ អ្នកគ្រប់គ្រង មន្ត្រីបច្ចេកទេស មន្ត្រីរដ្ឋបាល។ គន្លងមួយត្រូវការពេល៣ ទៅ៤ឆ្នាំ។

- អ្នកគ្រប់គ្រង៖ ប្រធាន អនុប្រធាន និងមន្ត្រីជំនាញជាន់ខ្ពស់
- មន្ត្រីបច្ចេកទេស៖ មន្ត្រីឯកទេសដំបូង  មន្ត្រីឯកទេស មន្ត្រីឯកទេសជាន់ខ្ពស់
- មន្ត្រីរដ្ឋបាល៖ ប្រធាន អ្នកបច្ចេកទេស មន្ត្រីរដ្ឋបាល

**ការរៀនសូត្រអាចតាមរយៈ:**

- ការរៀននិងអនុវត្តខ្លួនឯង  ឬ ការរៀនតាមរយៈមន្ត្រីផ្សេងទៀតក្នុងនាយកដ្ឋាន ឬ ក្រសួង ការរៀនក្នុងសិក្ខាសាលា វគ្គសិក្សាខ្លី ឬ បង្កើនគុណវុឌ្ឍិ។

**លក្ខខណ្ឌកំណត់សម្រាប់តំឡើងឋាន:**

- ទទួលពិន្ទុ ៥ ចំនួន៣ដង
- ទទួលពិន្ទុ ៤ ឬ ៥ ជាប់ជាបន្តរយៈពេល៤ ឬ ៥ឆ្នាំ
- មិនដែលមានអនុវត្តសកម្មភាពឬចរិយាដែលផ្ទុយនឹង វប្បធម៌អង្គភាព និងគុណតម្លៃ

**ការងារ និងជីវិត**

- ការងារអ្វីក៏ល្អដែរ សំខាន់គឺអ្នកចង់ធ្វើវា ហើយសម្រេចចិត្តប្រើពេលវេលានៃជីវិតធ្វើវាឱ្យវាមានប្រយោជន៍ដល់សង្គម
- បើអ្នកមិនចង់ ចោលវាទៅ កុំចំណាយពេលអត់ប្រយោជន៍ ដោយមិនធ្វើអ្វីទាំងអស់នោះ

## ឃ. និរន្តរភាពប្រព័ន្ធ

សំណួរដឹកនាំផ្ទាក់ទងនឹងការរីកចម្រើនការអនុវត្តយុទ្ធសាស្ត្រ

<table>
<tr><th>យុទ្ធសាស្ត្រ៖ តើអ្វីដែលត្រូវធ្វើបានធ្វើដែរឬទេ?</th><th>ការរៀនសូត្រ៖ តើមានវិធីណាដែលប្រសើរជាងនេះឬទេ?</th></tr>
<tr><td>១. ហេតុផល ឬការបកស្រាយ<br>២. ទ្រឹស្តីផ្លាស់ប្តូរច្បាស់លាស់</td><td rowspan="3">៦. មានជម្រើសច្រើនឬទេ<br>៧. ការអនុវត្តនូវជម្រើសដែលប្រសើរបំផុត<br>៨. ការសិក្សារៀនសូត្រដែលបានទទួល</td></tr>
<tr><td>ដំណើរអនុវត្តការងារ៖ តើអ្វីដែលកំពុងធ្វើ ធ្វើបានត្រឹមត្រូវឬទេ?</td></tr>
<tr><td>៣. ប្រសិទ្ធភាពនៃការសម្រេចផលសម្រេចគ្រោងទុក<br>៤. ប្រសិទ្ធផលនៃការប្រើប្រាស់ធនធាន (លុយតិចបានផលច្រើន)<br>៥. ការចូលចិត្តរបស់អតិថិជន</td></tr>
</table>

ចរិយាដឹកនាំ និងរៀនសូត្រ

*បើធ្វើកិច្ចការដដែលៗ អ្នកនឹងបានអ្វីដែលដដែលៗ បើអ្នកធ្វើកិច្ចការថ្មីៗ និងតាមរបៀបថ្មី អ្នកនឹងបាននូវអ្វីដែលថ្មីៗ បើចង់ធ្វើការតាមរបៀបថ្មី អ្នកត្រូវតែរៀនសូត្រ បើពុំនោះទេ អ្នកបានត្រឹមតែនិយាយប៉ុណ្ណោះ បើអញ្ចឹងតើអ្នករៀនសូត្រ ឬ មិនរៀន?*

តើពាក្យរៀនសូត្រមានន័យយ៉ាងណា?

**ជាដំណើរនៃការទទួលបាននូវ ការយល់ដឹង ចំណេះដឹង ចរិយា បំណិន គុណតម្លៃ អត្តចរិត និងចំណង់ចំណូលចិត្តថ្មីៗ។ ការសិក្សារបស់មនុស្សគឺចាប់កើតមានតាំងពីកំណើត (ហើយអាចមានចាប់ពីមុនកំណើត) រហូតដល់ស្លាប់ដោយសារវាជាផលដែលកើតចេញពីការប្រាស្រ័យទាក់ទង ជាប់ជាបន្តរវាងមនុស្ស និងបរិស្ថានជុំវិញគេ។**

ក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយមន្ត្រីទាំងអស់បានពង្រីកបរិមាណសាលារៀនពី0 នៅឆ្នាំ១៩៧៩មកដល់ជាង១៣០០០ នៅឆ្នាំ២០២១ និងថែរក្សាសាលារៀនទាំងនេះឱ្យមានដំណើរការ បើទោះបីជាមានការរំខានពីជំងឺកូវីដ-១៩យ៉ាងណាក៏ដោយ។ អ្វីដែលក្រសួងអប់រំ យុវជន និងកីឡានឹងត្រូវផ្តោតថាមពលទាំងអស់គឺ គុណភាពសិក្សារៀនសូត្ររបស់សិស្ស។ ដើម្បីអាចឈានទៅធ្វើកិច្ចការតាមបរិបទថ្មីក្នុងគន្លងកម្មវិធីកំណែទម្រង់អប់រំ មន្ត្រីអប់រំត្រូវតែរៀនសូត្ររហូតដើម្បីអាចធ្វើកិច្ចការកំណែទម្រង់បាន។

ឧបសគ្គរបស់មន្ត្រីម្នាក់ៗដែលនាំរំខានដល់ការរៀនសូត្រគឺ អត្តចរិតមិនរវល់ធ្វើដឹង (Denial)។ អត្តចរិតមិនរវល់ធ្វើដឹងនេះ ជាឧបសគ្គដែលនាំឱ្យមន្ត្រីបន្តធ្វើកិច្ចការដដែលៗ បើទោះជាមិនទទួលបាននូវលទ្ធផលក៏ដោយ។ អត្តចរិត

នេះមិនមែនជាកំហុសរបស់បុគ្គលជាមន្ត្រីម្នាក់ៗនោះទេ តែជាការទទួលនូវការប៉ះទង្គិចអារម្មណ៍ក្នុងរយៈកាលមានសង្គ្រាមនិងក្រោយសង្គ្រាម។

ដូចនេះនៅក្នុងយុទ្ធសាស្ត្រសហគមន៍សាលារៀន និងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀននិងគណៈគ្រប់គ្រងសាលារៀន បានបង្ហាញផ្លូវជាគន្លឹះក្នុងការជួយគ្រូបង្រៀននិងគណៈគ្រប់គ្រងសាលារៀនប្រែក្លាយជាមនុស្សថ្មី។ ល្បិចក្នុងការកែប្រែអត្តចរិត មិនរល់ធ្វើដឹងនេះគឺ ការចាប់ផ្ដើមជួយបុគ្គលម្នាក់ៗធ្វើអំពើល្អមួយ និងបន្តបន្ទាប់ ព្រមទាំងរកវិធីជួយគេឱ្យមានលំហក្នុងការរស់នៅជាមួយជីវិតរីករាយ តាមរយៈការធ្វើកិច្ចការមួយទទួលបានលទ្ធផលមួយ និងព្រមពេលជាមួយអាចបង្កើនការរកចំណូលបន្ថែមសម្រាប់ជីវិត។ ល្បិចទាំងនេះក៏នឹងត្រូវអនុវត្តផងដែរសម្រាប់មន្ត្រីនៅថ្នាក់ជាតិ និងក្រោមជាតិ ដោយការផ្សារភ្ជាប់គ្នារវាងការគ្រប់គ្រងការអនុវត្តការងាររបស់មន្ត្រី រួមជាមួយនឹងការតំឡើងឋានៈនិងការផ្ដល់រង្វាន់ ដែលមានចែងក្នុងផែនការសកម្មភាពកសាងសមត្ថភាពមន្ត្រីអប់រំមធ្យមសិក្សា។

មន្ត្រីអប់រំគប្បីយល់ថាមនុស្សតែម្នាក់គត់ក្នុងលោកដែលធ្វើឱ្យជីវិតអ្នករីករាយគឺខ្លួនអ្នកហ្នឹងហើយ ហើយតែមនុស្សម្នាក់គត់ក្នុងលោកដែលធ្វើឱ្យជីវិតអ្នកវេទនា គឺខ្លួនអ្នកហ្នឹងហើយ។ ដូចនេះបើអ្នកសិក្សាពីជីវិតមន្ត្រី ជីវិតសិស្សនឹងនាំឱ្យអ្នកបណ្ដុះបាននូវចិត្តអាណិតសិស្ស និងមន្ត្រី។ បើអ្នកខឹងនិងគុំគួនមន្ត្រី និងសិស្សនោះអ្នកមិនអាចជួយមន្ត្រីនិងសិស្សបានឡើយ។ បើអ្នកផ្ដើមមានចិត្តអាណិតមន្ត្រី សិស្ស និងជួយមន្ត្រីនិងសិស្សបាន អ្នកនឹងបណ្ដុះបាននូវសុជីវធម៌វិជ្ជាជីវៈ ដែលនាំឱ្យសេវាសាធារណៈមានគុណភាពដោយសារអំពើល្អរបស់អ្នក។ ដោយសារចិត្តអាណិតសិស្សនិងការប្រឹងប្រែងជួយសិស្សនាំឱ្យអ្នកដឹងថាអ្វីដែលខ្លួនចេះនិងមិនចេះ ហើយអ្នកនឹងប្រឹងប្រែងរៀនសូត្រពេញមួយជីវិតអ្នក។

បើអ្នកជាអ្នកដឹកនាំបន្តធ្វើកិច្ចការតាមរបៀបខាងលើ អ្នកនឹងជួយគ្រូបង្រៀន និងនាយកសាលារៀន កសាងបាននូវគុណតម្លៃ និងភាពថ្លៃថ្នូរជាគ្រូបង្រៀននឹងនាយកសាលារៀន ដូចដែលមាននៅទសវត្សរ៍៦០។ តើអ្នកចង់ជួយគ្រូបង្រៀន និងនាយកសាលារៀនទទួលបាននូវគុណតម្លៃ និងភាពថ្លៃថ្នូរនេះឬទេ? បើអ្នកជួយគ្រូបង្រៀន និងនាយកសាលារៀនបាន នេះហើយជាអ្វីដែលជាការសម្រេចចិត្តរបស់អ្នក ហើយអ្នកនឹងមានការរស់នៅជាមួយជីវិត និងការងារដែលរីករាយ។

## សុជីវធម៌សេវាសាធារណៈ និងការរស់នៅជាមួយ ជីវិតធម្មតា

សុជីវធម៌សេវាសាធារណៈមានន័យថា ជាសំណុំបញ្ញត្តិដែលណែនាំមន្ត្រីសាធារណៈនូវការប្រព្រឹត្តសេវាសាធារណៈសម្រាប់អតិថិជនរបស់គេ ដែលជាការសម្រេចចិត្តរបស់មន្ត្រីជំនួសឱ្យអតិថិជន។ មូលដ្ឋាននៃគោលគំនិតសុជីវធម៌សេវាសាធារណៈ ជាការយល់ដឹងពីការសម្រេចចិត្តនិងអំពើរបស់ខ្លួនដែលមានមូលដ្ឋានផ្អែកលើការផ្ដល់ការបម្រើប្រសើរបំផុតសម្រាប់ប្រយោជន៍សាធារណៈ ឬ អតិថិជន ដែលវាប្រឆាំងនឹងប្រយោជន៍មន្ត្រី (មានទាំងហិរញ្ញវត្ថុ) និង ប្រយោជន៍នយោបាយ។

តើអ្វីទៅជាសុជីវធម៌? ជាបញ្ញត្តិសីលធម៌ដឹកនាំចរិយាបុគ្គលស្គាល់ខ្លួនឯង ដោយសារការយល់ដឹងពីអ្វីដែលល្អនិងអាក្រក់ ផ្អែកលើការយល់ពីអ្វីដែលល្អនាំបុគ្គលធ្វើតែអ្វីដែលត្រូវ និងផ្អែកលើការយល់ពីអ្វីដែលអាក្រក់នាំបុគ្គលមិនធ្វើអ្វីដែលខុស។ បន្ថែមលើសុជីវធម៌សេវាសាធារណៈ និងសុជីវធម៌ទូទៅ ជាអ្នកដឹកនាំអ្នកគប្បីផ្ដោតការងាររបស់អ្នក ដើម្បីក្លាយខ្លួនជាអ្នកដឹកនាំផ្អែកលើលទ្ធផល ដូចមានរៀបរាប់ខាងក្រោម។

១០ ជំហានក្លាយជាអ្នកដឹកនាំ

១០ យុទ្ធសាស្រ្តនេះបានសម្របពី ការដឹកនាំមានមូលដ្ឋានលើលទ្ធផល *(Harvard Business School Press, Boston, www.hbsp.harvard.edu).*

ការដឹកនាំវាច្រើនជាងបញ្ជីនៃអត្តចរិត។ វាច្រើនជាងការដឹងពីរបៀបប្រឈមជាមួយមនុស្ស។ វាច្រើនជាងការដឹងពីទស្សនៈវិស័យរបស់អង្គភាព។ វាច្រើនជាងទំនាក់ទំនងដែលប្រសើរ ការគ្រប់គ្រងការផ្លាស់ប្តូរ ការបណ្តុះនូវសុចរិតភាពធ្វើឱ្យអ្នកដទៃមានសមត្ថភាពនិងអំណាច កសាងក្រុមការងារ ការពង្រីកជម្រើសច្រើនមុខ ការពង្រីកការប្រើបច្ចេកវិទ្យា ឬមានភាពអត់ធ្មត់លើកិច្ចការនៅនឹងដៃ។ ការដឹកនាំដែលពិត ការដឹកនាំដែលមានប្រសិទ្ធភាពព្រោះគឺជាការផ្សារភ្ជាប់គ្នានូវអត្តចរិតទាំងអស់នេះ (និងអ្វីជាច្រើនផ្សេងទៀត) សម្រាប់សម្រេចបាននូវលទ្ធផលដែលប៉ងប្រាថ្នា។ អ្នកដឹកនាំធ្វើឱ្យកិច្ចការត្រូវធ្វើត្រូវបានអនុវត្ត។

**១. ផ្តោតលើលទ្ធផលចង់បាន**

លទ្ធផលត្រូវចាត់ទុកជាអាទិភាពលើអ្វីទាំងអស់ លើកលែងតែភក្តីភាពចំពោះអង្គភាព និងសុជីវធម៌ និងគុណតម្លៃបុគ្គល។ ដូចនេះលទ្ធផលត្រូវតែបានកំណត់ន័យឱ្យច្បាស់ និងត្រូវបានយល់ដឹងដូចគ្នានៃគ្រប់មន្ត្រីម្នាក់ៗនៅក្នុងអង្គភាព។ អ្នកដឹកនាំអង្គភាព និងអ្នកគ្រប់គ្រងថ្នាក់ខ្ពស់មិនអាចកែប្រែក្រុមគោលដៅលទ្ធផលជាប់រហូតនៅពេលណាដែលលទ្ធផលនៅទ្រឹងឬជិតសម្រេចនោះទេ។

**២. ជាអ្នកដឹកនាំ អ្នកត្រូវទទួលខុសត្រូវទាំងស្រុងចំពោះលទ្ធផល**

បរាជ័យក្នុងការទទួលខុសត្រូវនេះ នាំឱ្យមានភាពខ្សោយនៃសីលធម៌ និងបាត់បង់នូវឱកាសសម្រាប់ការផ្លាស់ប្តូរនិងកែលម្អឱ្យមានការរីកចម្រើន។ អ្នកដឹកនាំដែលបរាជ័យក្នុងការទទួលខុសត្រូវ ឬអន់ជាងនេះទៅទៀត គឺបោះមន្ត្រីចោលចូលក្រោមឡានក្រុង នឹងមិននៅជាអ្នកដឹកនាំសម្រាប់រយៈពេលយូរអង្វែងទេ។ នេះមិនមែនជាការដឹកនាំទេ តែជាលទ្ធិផ្តាច់ការនិយមហើយ។

**៣. ត្រូវមានទំនាក់ទំនងច្បាស់លាស់នូវលទ្ធផលរំពឹងទុក និងក្រុមគោលដៅទៅអ្នកគ្រប់គ្រង និងមន្ត្រី**

ការផ្តោតលើលទ្ធផលចង់បានគឺ ត្រូវកំណត់បានដោយ គោលបំណង និងក្រុមគោលដៅច្បាស់លាស់ ដល់គ្រប់មន្ត្រី ដូចនេះអាទិភាពត្រូវបានលាតត្រដាងច្បាស់លាស់ ហើយមន្ត្រីគ្រប់រូបអាចធ្វើការងារឆ្ពោះទៅទីចុងបញ្ចប់ដែលចង់បាន។

តើប៉ុន្មានដងហើយដែលអ្នកធ្វើកិច្ចការគម្រោង និងបានធ្វើឱ្យមានការរីកចម្រើននៅតែលើអ្វីដែលបានដឹងថាអ្នកដឹកនាំចង់បានអ្វីដែលផ្សេងពីនេះ? អ្នកដែលធ្វើឱ្យពេលវេលាខាតបង់ត្រូវបានបំផ្លាញនូវសីលធម៌ហើយ។ ជានិច្ចកាលអ្នកត្រូវតែច្បាស់ថា អ្វីប្រាកដដែលជាសេចក្តីសង្ឃឹម ឬ លទ្ធផលចង់បាន។

## ៤. កំណត់នូវកិច្ចការដែលអ្នកត្រូវធ្វើដោយបុគ្គលខ្លួនឯងដើម្បីសម្រេចលទ្ធផល

ភាពជោគជ័យរបស់អ្នកនឹងត្រូវផ្អែកលើ តើអ្នកអនុវត្តកិច្ចការទាំងនេះដូចម្ដេច បើទោះបីជាដំណើរអនុវត្តការងារ ឬការសម្រេចចិត្តរបស់មន្ត្រីផ្សេងនាំរំខានដល់កិច្ចការក៏ដោយ។ ការប្ដេជ្ញាចិត្តរបស់អ្នកដើម្បីកែលម្អខ្លួននឹងកែលម្អស្មារតីរបស់មន្ត្រីអ្នក និងធ្វើឱ្យទំនាក់ទំនងទៅខាងលើ បង្ហាញថាអ្នកជាអ្នកដឹកនាំតាមរយៈរយៈធ្វើជាគំរូដល់មន្ត្រី។ ការដឹកនាំមិនជាអ្វីដែលត្រូវត្រួតត្រាអ្នកដ៏ទៃនោះទេ តែជាអ្វីដែលអ្នកត្រូវត្រួតត្រាខ្លួនអ្នក។

## ៥. ចូលរួមក្នុងសកម្មភាពដែលនឹងជួយអ្នកផលិតលទ្ធផលបានប្រសើរ

ភាពបន្ទាន់ជាវិធានការដំបូងត្រូវប្រើសម្រាប់សកម្មភាពអភិវឌ្ឍបុគ្គលឬអ្វីទាំងអស់។ វិធីគិតគឺ ខ្ញុំនឹងធ្វើកិច្ចការនេះ _______ ដូចនេះលទ្ធផលនេះ _______ នឹងត្រូវសម្រេច។ អនុវត្តតែកិច្ចការណាដែលផលិតនូវផលសម្រេចដែលចង់បាន ផលសម្រេចដែលអាចវាស់វែងបាន បានហើយ។ អនុវត្តសកម្មភាពផ្សេងទៀតជាការនាំឱ្យខាតបង់ពេលវេលាហើយ ហើយវានឹងមិននាំឱ្យអ្នកសម្រេចបាននូវគោលបំណង និងវត្ថុបំណងគោលយោបាយបានឡើយ។

## ៦. យល់ដឹង និងប្រើសមត្ថភាពអង្គភាពអ្នក

អ្នកដឹកនាំសម្រេចលទ្ធផលត្រូវតែដឹងភាពខ្លាំង និងខ្សោយនៃមន្ត្រីគ្រប់រូបនៅក្នុងអង្គភាព ដែលនាំឱ្យអាចយកចំណេញពីអ្វីដែលកំពុងមាន និង លុបចោលនូវអ្វីខ្សោយ។ នេះមានរួមបញ្ចូលដៃរនូវអ្នកលក់ អ្នកផ្ដល់សេវា និង អ្នកទិញសេវា។ អ្នកត្រូវតែដឹង ដឹងនូវអ្វីដែលកំពុងកើតមានលើទិដ្ឋភាពមានជីវិតនៃមុខជំនួញ និងការងាររបស់អ្នក។

## ៧. វាស់វែងឱ្យត្រូវ និងញឹកញាប់

សារស្នូលនៃសៀវភៅ៖ ផលសម្រេចគឺសំខាន់ ហើយអ្នកត្រូវវាស់វែងវា។ ប៉ុន្តែមុននឹងវាស់វែងវា អ្នកត្រូវតែយល់ថា អ្វីដែលអ្នកត្រូវវាស់វែង និងវិធីប្រសើរបំផុតអ្វីដែលត្រូវអនុវត្តសម្រាប់វាស់វែង។ ប្រព័ន្ធគ្រប់គ្រងព័ត៌មានអាចឱ្យអ្នកសរសេររបាយការណ៍ តែវាមិនមានន័យថា វាមានតម្លៃច្រើនជាងអ្វីដែលជាក្រដាសបោះពុម្ពនោះទេ។ របាយការណ៍មិននាំឱ្យអ្នកក្លាយជាអ្នកដឹកនាំល្អនោះទេ។ តែអ្វីដែលអ្នកធ្វើ ជាមួយនឹងព័ត៌មានដែលនឹងជួយអ្នកដឹកនាំក្រុមរបស់អ្នកបានដើម្បីផលិតផលសម្រេចដែលចង់បាន នោះទើបអ្នកជាអ្នកដឹកនាំដែលល្អ ដែលផលិតនូវរបាយការណ៍ជួយអ្នកឱ្យដឹកនាំបាន។

## ៨. ត្រូវធ្វើសកម្មភាពជាប់ជាបន្ត

អ្នកដឹកនាំសម្រេចលទ្ធផលត្រូវតែរៀបចំចាត់ចែង ទំនាក់ទំនង និងផ្ដោតលើឱកាស ជាប់ជាប្រចាំ លើអ្វីដែលអង្គភាពត្រូវធ្វើ ជាជាងលើអ្វីដែលធ្វើមិនបាន។ អ្នកត្រូវលើកទឹកចិត្តមន្ត្រីផលិតលទ្ធផលតាមរបៀបនេះ។ បណ្ដុះការចូលចិត្តសម្រាប់អនុវត្តសកម្មភាព។ អ្នកត្រូវតែជាអ្នកដែលបានទទួលស្គាល់ថាជាមនុស្ស ដែលនាំការងារសម្រេចបានការងារដែលត្រូវធ្វើ និងធ្វើតាមរបៀបដែលត្រូវ។

## ៩. ស្វែងរកព័ត៌មានមានត្រឡប់

គេថាព័ត៌មានមានត្រឡប់ជាអាហារពេលព្រឹករបស់អ្នកពូកែ ។ សាកសួរអ្នកគ្រប់គ្រង និងមន្ត្រីពីអ្វីដែលអ្នកកំពុងធ្វើ។ តើអ្វីដែលគេចង់បានដែលមិនត្រូវបានផ្តល់ឱ្យ? តើការផ្លាស់ប្តូរអ្វីដែលគេចង់ឃើញ? តើអ្វីដែលអ្នកកំពុងធ្វើមានដំណើរការល្អនៅក្នុងក្រសែភ្នែករបស់គេ? តើឧបករណ៍អ្វីដែលមន្ត្រីត្រូវការដើម្បីសម្រេចបាននូវលទ្ធផលចង់បាន? អ្នកដឹកនាំមានប្រសិទ្ធភាព ចង់បានព័ត៌មានមានពិតនិងត្រង់ ហើយយកព័ត៌មានមាននេះប្រើសម្រាប់កែលម្អការងារ។

## ១០. ចៀសវាងទស្សនៈថាមានប្រយោជន៍សម្រាប់បុគ្គល

សំណួរត្រូវសួរ៖ តើអ្វីជាកេរ្តិ៍ដំណែលរបស់ខ្ញុំសម្រាប់អង្គភាព? អ្វីទាំងអស់កំពុងធ្វើ ត្រូវបានមើលឃើញថាមានប្រយោជន៍អ្វីសម្រាប់អង្គភាព ហើយមិនមែនជាប្រយោជន៍របស់អ្នក។ មានប្រយោជន៍សម្រាប់បុគ្គល គឺ អ្នកប្រើទ្រព្យសម្បត្តិ ឬឧបករណ៍របស់អង្គភាពសម្រាប់ប្រយោជន៍បុគ្គលខ្លួន។

## វប្បធម៌ទំនាក់ទំនង

ដើម្បីប្តូរបាននូវអត្តចរិតនិងចរិយា ជាការប្រសើរដែលមន្ត្រីត្រូវប្តូរវប្បធម៌ទំនាក់ទំនងបច្ចុប្បន្នទៅជាវប្បធម៌ទំនាក់ទំនងដែលមន្ត្រីគ្រប់គ្នាចង់បាន ជាមួយនឹងការសម្រេចចិត្តថា តើមន្ត្រីម្នាក់ៗចង់នៅជាមនុស្សអតីតកាល ឬចង់ក្លាយជាមនុស្សបច្ចុប្បន្នកាល។ ខ្លឹមសារមានរៀបរាប់ដូចខាងក្រោម៖

### *វប្បធម៌ទំនាក់ទំនងបច្ចុប្បន្ន*

- ស្វែងរកកំហុស និងស្តីបន្ទោស
- ទំនាក់ទំនងចោទលើបុគ្គលធ្វើកិច្ចការខុស ឬ មានកំហុស
- ចៀសវាងនិយាយការពិត ដោយខ្លាចការបន្ទោស
- គិត និងពិចារណារហូតដើម្បីនិយាយឱ្យពិរោះស្តាប់
- បំភ្លេចអតីតកាល ឬបើរំលឹកវិញ គឺនិយាយអវិជ្ជមានពីអតីតកាល
- ការគិតគឺតាមបែបអវិជ្ជមាន ហើយបន្តនូវកំហុសដដែលៗព្រោះមិនបានរៀនសូត្រពីបរាជ័យនៃអតីតកាល ដោយមិនរវល់ថាប្រទេសជាតិចង់បានអ្វីនៅអនាគត

### *វប្បធម៌ទំនាក់ទំនងដែលចង់បាន*

- មិនស្វែងរកកំហុស
- សូមកុំគិតថាបញ្ហាជារបស់បុគ្គល តែជារបស់យើងទាំងអស់គ្នា
- និយាយត្រង់ និយាយពិត
- ស្តាប់ គិត និងពិចារណា ជាការរៀនសូត្ររហូត
- ប្រើអតីតកាលជាពិសោធន៍ តែគប្បីចៀសវាងកុំគិតនិងនិយាយអវិជ្ជមានពីអតីតកាល
- ព្យាយាមគិតវិជ្ជមាន ហើយចាប់ផ្តើមធ្វើអ្វីត្រូវថ្ងៃនេះ ដើម្បីទទួលបាននូវអ្វីយើងនិងប្រទេសជាតិចង់បាននៅអនាគត

ដោយសារសង្គ្រាមនិងក្រោយសង្គ្រាម មន្ត្រីជាច្រើនមិនបានឆ្លងកាត់ដំណាក់អភិវឌ្ឍនិងការថែទាំបានត្រឹមត្រូវ ដូចនេះខ្លឹមសារខាងក្រោមអាចជាខ្លឹមសារសំខាន់ដែលមន្ត្រីម្នាក់គប្បីយល់ថា «ហេតុអ្វីកុមារគិតត្រូវ ចុះអ្នកវិញ»? កុមារមានការអភិវឌ្ឍបីដំណាក់កាល ដែលមានប្រាំមួយជំហាន ដូចខាងក្រោម៖

**ដំណាក់មុនអភិវឌ្ឍ**

- **ជំហានទី១៖** មិនមានហេតុផលឱ្យធ្វើត្រូវជាងការភ័យខ្លាចទទួលទណ្ឌកម្ម ឬការគោរពអ្នកមានអំណាច។
- **ជំហានទី២៖** ការកើនឡើងនូវភាពបុគ្គលនិយម និងការយល់ពីការរំលែកប្រយោជន៍ឱ្យមានភាពស្មើគ្នា ឬភាពស្មើភាពគ្នា។ ការយល់បែបនេះមានមូលដ្ឋានលើការជឿជាក់ថា ប្រយោជន៍របស់ម្នាក់ៗត្រូវបានផ្តល់ឱ្យស្មើគ្នា។

**ដំណាក់កំពុងអភិវឌ្ឍ ជាដំណាក់យកចិត្តទុកដាក់ដល់អ្នកដទៃ**

- **ជំហានទី៣៖** កុមារចំណាយការយកចិត្តទុកដាក់ពិសេសដល់អ្នកជុំវិញ ដែលចាត់ទុកថាជាចរិយាល្អឬចរិយាមានគុណតម្លៃ។ ចរិយាមានគុណតម្លៃទាំងនេះមាន ការទុកចិត្ត ភក្តីភាព ការគោរព និងកតវេទិតា (ការដឹងគុណ)។
- **ជំហានទី៤៖** ការទទួលស្គាល់ជាដំបូងនូវប្រព័ន្ធសីលធម៌ទូទៅដែលកំណត់ដោយក្បួនច្បាប់ និងតួនាទី ហើយគេត្រូវប្រឹងប្រែងបំពេញនូវកតព្វកិច្ចរបស់គេ។ ដើម្បីរក្សាកុំឱ្យមានការបែកបាក់ គេបានប្រកាន់ខ្ជាប់ថា ប្រសិនបើអ្នកណាម្នាក់ធ្វើសកម្មភាពអ្វីមួយដែលខុស នេះគឺជាកំហុសរបស់អ្នកទាំងអស់គ្នា។ ចរិយាបែបនេះនាំឱ្យកុមារមានចរិយាមិនចាត់ទុកបញ្ហាណាមួយជារបស់បុគ្គលទេ ដូចនេះនាំឱ្យគេហាននិយាយពីបញ្ហា ព្រោះថាការសម្រេចចិត្តគឺបានធ្វើជាក្រុម ហើយការអនុវត្តការសម្រេចចិត្តជាការអនុវត្តដោយក្រុម ការកសាងសមត្ថភាពម្នាក់ៗគឺមកពីចរិយារួម បើទោះជាសកម្មភាពមួយឬបញ្ហាមួយជារបស់បុគ្គលក៏ដោយ។

**ដំណាក់អភិវឌ្ឍពេញលេញ ឬដំណាក់ការគោរពគោលការណ៍ ជាដំណាក់ឆ្ពោះទៅរកច្បាប់សីលធម៌សកល**

- **ជំហានទី៥៖** បើទោះជាយល់ថាគុណតម្លៃឬតម្លៃជាមនុស្សជាគោលការណ៍ដែលទទួលស្គាល់ដោយមនុស្សមួយក្រុម យ៉ាងណាក៏ដោយ កុមារទុកគុណតម្លៃនេះមួយឡែកពីកិច្ចសន្យាសង្គម ដែលតម្រូវឱ្យមានការស្តាប់បង្គាប់តាមច្បាប់រួម គ្នាជាសកល។ ដូចនេះត្រូវសួរថា អ្វីដែលត្រូវ (what is right) នោះនាំឱ្យគេគិតពិចារណាថា តើអ្វីដែលនាំមកនូវប្រយោជន៍ល្អសម្រាប់មនុស្សច្រើនគ្នា ជាជាងគិតពីប្រយោជន៍មនុស្សមួយក្រុម។
- **ជំហានទី៦៖** ជាការអភិវឌ្ឍចរិយាដែលលើសពីការគ្រាន់តែគិតពីប្រយោជន៍ តែជាការអភិវឌ្ឍនូវការប្តេជ្ញាចិត្តរបស់បុគ្គលលើគោលការណ៍សីលធម៌សកលគឺ យុត្តិធម៌ សិទ្ធិមនុស្សស្មើភាពគ្នា និង**សេចក្តីថ្លៃថ្នូរ**របស់បុគ្គល។ ក្នុងដំណាក់ការនេះគឺ បុគ្គលមានមូលហេតុត្រូវតែដឹងថា មនុស្សមិនមែនមានន័យថាគិតតែពីប្រយោជន៍នោះទេ

តែត្រូវរស់នៅជាមួយគ្នាដោយការយកចិត្តទុកដាក់ថែទាំគ្នាទៅវិញទៅមក។ ចរិយានេះហើយជាការស្រឡាញ់ បើអ្នកធ្វើបាន នោះហើយគឺអ្វីដែលខ្ញុំធ្លាប់បាននិយាយថា ជាមនុស្សដែលមានជីវិតរីករាយពិត។

**អាចជាការមានប្រយោជន៍ដែលមន្ត្រីម្នាក់ៗស្វែងយល់ពីបុគ្គលដែលសម្រេចចិត្តថាធ្វើខុសតាមរបៀបបីយ៉ាង៖**

**១. ការបំពានច្បាប់ ៖** ជាក់ហុសហើយនៅពេលយករបស់គេមិនឱ្យលុយ កាប់ដើមឈើជាសម្បត្តិរដ្ឋឬអ្នកជិតខាង ហើយកាន់តែធ្ងន់ទៀតគឺផ្តល់ឬយកសំណូក មិនបង់ថ្លៃជួលផ្ទះ ឬ មានហិង្សា ឬ វាយប្រពន្ធ ឬ ធ្វើខុសវិជ្ជាជីវៈ។ ការបំពានទាំងនេះកើតឡើងដោយការមិនដឹង ការធ្វើមិនដឹង ឬបំពានច្បាប់តែម្តង។

ដូចនេះស្ថាប័នតម្រូវឱ្យអ្នកគ្រប់គ្រង និងមន្ត្រីយល់ដឹងពីច្បាប់ និងមិនត្រូវធ្វើខុសឡើយ។ ស្ថាប័នក៏ត្រូវមានមន្ត្រីជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តក្រមសីលធម៌ដែរ។ អ្នកទាំងពីរត្រូវធ្វើការសហការណ៍គ្នា។

**២. ការចាកចេញពីការពិត៖** សាលាមានសិស្សចូលរៀន១៥៥នាក់ តែប្រាប់ថ្នាក់លើថា២០០នាក់។ បង្រៀនសិស្សមិនបានទទួលចំណេះដឹងនិងបំណិនដែលគេត្រូវការសម្រាប់ការងារ ឬមុខជំនាញដែលទីផ្សារមិនត្រូវការ។ តើអ្វីដែលសកលលោកត្រូវធ្វើសម្រាប់ការធ្វើខុសទាំងនេះ។ ភាគច្រើនថា បង្រៀនសីលធម៌ទៅ ហើយពាក្យអប់រំគេថាការអប់រំចរិយាឬក្រមសីលធម៌ដែលត្រូវបញ្ជ្រាបចូលក្នុងកម្មវិធីសិក្សាពីជីវិតសិក្សា ឬត្រូវបញ្ជ្រាបចូលក្នុងការអនុវត្តការងារប្រចាំថ្ងៃរបស់អ្នកដឹកនាំនិងមន្ត្រី។

**៣. ការងាកចេញពីវិចារណញ្ញាណ (ភាពត្រឹមត្រូវ)៖** ដាក់តម្លៃក្នុងវិក្កយបត្រខុសពីតម្លៃទិញ ប្រើសម្ភារៈសំណង់មិនត្រូវឬមិនគ្រប់ យក ឬ ស្រឡាញ់របស់គេ ឬ ទ្រព្យគេ មិនបង់ពន្ធ និយាយហួសព្រំដែនតួនាទី ជេរគេដោយគេមិនហៅកិត្តិនាមរបស់ខ្លួន បានតែនិយាយតែមិនធ្វើ មិនមានវិន័យ មិនទទួលខុសត្រូវ។ល។ ប្រសិនបើត្រីវិស័យសីលធម៌ (ធ្វើតែចរិយាដែលអ្នកចង់ឱ្យអ្នកដ៏ទៃធ្វើមកលើខ្លួន) ខាងក្នុងខ្លួនវាខ្វះខាតហើយនោះ ឬ មួយថាក្នុងខ្លួនវាប្រហោងទទេដោយមិនមានតម្លៃដែលជាមនុស្សនោះ នោះមនុស្សនោះមិនដែលអាចនឹងទទួលស្គាល់ថាសកម្មភាពរបស់ខ្លួនគឺខុសឡើយ។

ជារួមអ្នកដឹកនាំត្រូវនាំអ្នកដើរតាមឱ្យធ្វើកិច្ចការតាមទិសកំណត់ជាក់លាក់ ដោយមានការប្តេជ្ញាចិត្ត ស្ម័គ្រចិត្តតាមបរិបទថ្មី ដែលមានិរន្តរភាព និងអនុវត្តជាមួយគ្នានូវគុណតម្លៃ និងវប្បធម៌អង្គភាពដែលបានព្រមព្រៀងគ្នា។ ដើម្បីអាចដឹកនាំបាន អ្នកដឹកនាំត្រូវស្តាប់អ្នកដើរតាម នោះអ្នកដឹកនាំអាចសម្របសម្រួលមន្ត្រីពិភាក្សាគ្នាបាន បើអាចសម្របសម្រួលមន្ត្រីពិភាក្សាគ្នាបាន អ្នកដឹកនាំអាចសម្របសម្រួលមន្ត្រីឱ្យធ្វើការជាមួយគ្នាបាន បើអ្នកដឹកនាំអាចសម្របសម្រួលឱ្យមនុស្សធ្វើការជាមួយគ្នាបាន អ្នកដឹកនាំអាចដឹកនាំបាន។ បើអ្នកដឹកនាំអាចបង្រៀនមន្ត្រីបាន អ្នកអាចដឹកនាំអាចដឹកនាំបានហើយ។ ដូចនេះគ្រឹះនៃការដឹកនាំ គឺ ការស្តាប់ តែភាគច្រើនជាបញ្ហាគឺ អ្នកដឹកនាំមិនស្តាប់តែម្តង។ ម្យ៉ាងវិញទៀត អ្នកដឹកនាំអាចបង្រៀនបានលុះណាអ្នកដឹកនាំជាមនុស្សគំរូ ដូចនេះអ្នកដឹកនាំត្រូវរៀនរស់នៅជាមនុស្សគំរូ៖ ចាប់ផ្តើមពីអ្នកត្រូវរៀនស្គាល់ការពិតខ្លួនឯង Self actualization បន្ទាប់អ្នកត្រូវរៀនផ្តល់តម្លៃដោយខ្លួនឯង

Self esteem អ្នកគប្បីស្រឡាញ់តែអ្វីដែលជារបស់ខ្លួនបានហើយ Love belongingness អ្នកគប្បីរៀនរស់ប្រកបដោយសុវត្ថិភាព Live with safety និងអ្នកគប្បីរៀនសូត្ររហូត និងរស់ជាមនុស្សសាមញ្ញ Learning and live a normal life។

អ្នកជាមនុស្ស ដូចនេះអ្នកធ្វើតែអ្វីដែលអាចធ្វើបានតែប៉ុណ្ណោះ គ្រប់ការផ្លាស់ប្តូរគឺចាប់ផ្តើមពីមួយ មិនអាចលោភបានទេ។ ការផ្លាស់ប្តូរមួយនាំឱ្យមនុស្សចូលរួមកាន់តែច្រើន តែមនុស្សមានចិត្តបិសាច (Evil or Darkness) ឬគិតអវិជ្ជមានរហូតនៅតែមិនចូលរួម តែបើអ្នកអាចជួយមនុស្សមានចិត្តបិសាចម្នាក់បាន អ្នកអាចជួយមនុស្សគ្រប់ប្រភេទបាន។ ជួយមនុស្សបិសាចបានលុះណា អ្នកប្រាកដថាមានការអត់ធ្មត់ មានពេលវេលាគ្រប់គ្រាន់ និងរៀនដោះស្រាយបញ្ហាដោយឆ្លាតវៃបំផុត និងផ្តល់ឱកាសឱ្យគេដើម្បីធ្វើកិច្ចការល្អ និងទទួលបានលទ្ធផល។

**ធាតុនិរន្តរភាពអាចឆ្លើយសំណួរដឹកនាំទាំង៨**

និរន្តរភាពអនុវិស័យគឺស្ថិតនៅលើចំណុចទាំងបួនខាងក្រោម៖

១. **ស្ថាប័ន៖** យន្តការអង្គភាព (ប្រព័ន្ធផ្តល់លទ្ធភាពអនុវត្ត) និង យន្តការប្រតិបត្តិ (ប្រព័ន្ធផ្តល់អំណាច) ត្រូវមានដំណើរការឥតខ្ចោះ ក្នុងការអនុវត្តយុទ្ធសាស្ត្រអនុវិស័យ។ យុទ្ធសាស្ត្រមានការពិនិត្យ និងកែសម្រួលឡើងវិញទៀងទាត់។

២. **សមត្ថភាពមន្ត្រី៖** មន្ត្រីមានចំណេះដឹងនិងបំណិនសព្វគ្រប់ បំពេញការងាររបស់ខ្លួន និងបង្ហាញគណនេយ្យភាពក្នុងការសម្រេចលទ្ធផល(ប្រព័ន្ធផ្តល់ថាមពលធ្វើការងារ)។

៣. **ហិរញ្ញវត្ថុ៖** មានគ្រប់គ្រាន់សម្រាប់អនុវត្តនិងគ្រប់គ្រងកម្មវិធីវិនិយោគ ជ្រើសរើសនិងថែរក្សាមន្ត្រីមានសមត្ថភាពឱ្យនៅធ្វើការងារពេញពេល និងសម្រាប់ការពង្រីកវិសាលភាពសេវាគ្របដណ្តប់ដែលអាចឆ្លើយតបនឹងតម្រូវការប្រទេសជាតិ។

៤. **សុជីវធម៌៖** រក្សាខ្ជាប់ខ្ជួននូវការគោរពនិងអនុវត្តវប្បធម៌ និងគុណតម្លៃរបស់ស្ថាប័ន ដើម្បីកសាងកេរ្តិ៍ឈ្មោះអនុវិស័យគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ សាលារៀន និងគ្រូបង្រៀន។